ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្របខ័ណ្ឌយុទ្ធសាស្ត្រ
# សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា
# ២០០៨ - ២០១២

រៀបចំដោយ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD)
ដោយមានការពិគ្រោះយោបល់ជាមួយក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (TWG-FSN)

រាជធានីភ្នំពេញ, ខែឧសភា ឆ្នាំ២០០៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ក្របខ័ណ្ឌយុទ្ធសាស្ត្រ សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ២០០៨ – ២០១២

រៀបចំដោយ ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD)
ដោយមានការពិគ្រោះយោបល់ជាមួយក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (TWG-FSN)

United Nations unicef Children's Fund

រាជធានីភ្នំពេញ, ខែឧសភា ឆ្នាំ២០០៨

# បុព្វកថា

ការកែលំអសន្តិសុខស្បៀងនិងអាហារូបត្ថម្ភគឺជាអាទិភាពអភិវឌ្ឍន៍ដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយមានសារសំខាន់យ៉ាងខ្លាំងក្នុងការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។សន្តិសុខស្បៀងមានចែងយ៉ាងច្បាស់នៅក្នុងគោលដៅទី១នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាថា: **"លុបបំបាត់ភាពក្រីក្រ និងភាពស្រេកឃ្លាន"** ហើយសន្តិសុខស្បៀងក៏មាន សារសំខាន់ផងដែរក្នុងការសម្រេចឱ្យបាននូវគោលដៅផ្សេងទៀតនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ២០០៦-២០១០ ចែងថា: សន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺជាគោលដៅគន្លឹះដើម្បីធានាឱ្យបានថា **"ត្រឹមឆ្នាំ២០១០ ប្រជាពលរដ្ឋកម្ពុជាក្រីក្រ និងអសន្តិសុខស្បៀងនឹងមានលទ្ធភាពល្អប្រសើរច្រើន ទាំងផ្នែករូបវន្តនិងផ្នែកសេដ្ឋកិច្ច ក្នុងការទទួលបានស្បៀងអាហារមានសុវត្ថិភាព និងមានជីវជាតិគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការរបបអាហារ និងចំណង់ចំណូលចិត្តនៅគ្រប់ពេលវេលាទាំងអស់សម្រាប់ជីវិតរស់នៅយ៉ាងសកម្ម និងមានសុខភាពមាំមួន"**។ សន្តិសុខស្បៀងក៏ត្រូវបានទទួលស្គាល់ និងចាត់ទុកថាជាសិទ្ធិមូលដ្ឋានរបស់បុគ្គលម្នាក់ៗ ស្ថិតក្រោមសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស និងសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច-សង្គម និង វប្បធម៌ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន។

ក្នុងអំឡុងទសវត្សចុងក្រោយ ប្រទេសកម្ពុជាមានស្បៀងអាហារគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ខ្លួនឯង ហើយមាននៅសល់ស្បៀងសម្រាប់នាំចេញទៀតផង ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ សន្តិសុខស្បៀងតែងតែមានការប្រែប្រួលពីតំបន់មួយទៅតំបន់មួយ ហើយភាពមានស្បៀងនៅតាមមូលដ្ឋាននៅតែងាយរងគ្រោះដោយសារឥទ្ធិពលនៃគ្រោះធម្មជាតិ ។ ការរីករាលដាលនៃភាពក្រីក្រនៅតាមជនបទនៅតែជាឧបសគ្គរារាំងដល់ភាពទទួលបានស្បៀងគ្រប់គ្រាន់សម្រាប់គ្រួសារភាពច្រើន។ នៅឆ្នាំ២០០៤ ប្រជាជនកម្ពុជាប្រមាណ២៣ភាគរយបានប្រើប្រាស់ស្បៀងតិចជាងតម្រូវការថាមពលអាហារអប្បបរមា (១៧១៥ គីឡូកាឡូរីក្នុងម្នាក់ក្នុងមួយថ្ងៃ) ។ ការកើនឡើងនៃតម្លៃស្បៀងគឺជាបញ្ហាប្រឈមបន្ថែមទៀតសម្រាប់ប្រជាពលរដ្ឋកម្ពុជាក្រីក្រក្នុងការទទួលបានស្បៀងគ្រប់គ្រាន់សម្រាប់បរិភោគ ដោយហេតុថា ជាមធ្យមពួកគាត់ចំណាយប្រមាណជាង៧០ភាគរយនៃប្រាក់ចំណូលសម្រាប់ទិញស្បៀងអាហារ។

កង្វះរបបអាហារ និងវិធីសមស្របក្នុងការចិញ្ចឹមកុមារ កង្វះអនាម័យ និងកង្វះលទ្ធភាពក្នុងការទទួលបានសេវាកម្មថែទាំសុខភាពដែលមានគុណភាព គឺជាកត្តារួមចំណែកដល់កង្វះអាហារូបត្ថម្ភរបស់ប្រជាពលរដ្ឋកម្ពុជាមួយចំនួន ។ ស្ថានភាពអាហារូបត្ថម្ភនៃកុមារនិងស្ត្រីដែលជាសូចនាករលទ្ធផលរួមនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ មានភាពល្អប្រសើរឡើងយ៉ាងច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ក៏ប៉ុន្តែនៅមានតម្រូវការវិនិយោគឱ្យចំគោលដៅបន្ថែមទៀត ដើម្បីធានានិរន្តរភាព និងជំរុញនូវសមិទ្ធផលទាំងអស់នេះ ។ ការខាតបង់ផ្នែកសេដ្ឋកិច្ច-សង្គមដោយសារតែបញ្ហាកង្វះអាហារូបត្ថម្ភរបស់ប្រជាជនកម្ពុជាមានទំហំធំធេងគួរឱ្យកត់សំគាល់ ហើយការវិនិយោគក្នុងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភត្រូវបានបង្ហាញឱ្យឃើញថាបានផ្តល់សារប្រយោជន៍ និងមានផលចំណេញខ្ពស់ដល់ការអភិវឌ្ឍន៍ សង្គមជាតិ។

ក៏ដូចជាបញ្ហាអន្តរវិស័យផ្សេងទៀតដែរ សន្តិសុខស្បៀង និងអាហារូបត្ថម្ភមានការពាក់ពន្ធ័នឹងវិស័យមួយចំនួនទៀត និងត្រូវបញ្ជ្រាបទៅក្នុងគោលនយោបាយវិស័យយុទ្ធសាស្ត្រនិងផែនការនានាដើម្បីធានាឱ្យបាននូវភាពមានស្បៀង ភាពទទួលបានស្បៀង និងការប្រើប្រាស់ស្បៀងគ្រប់គ្រាន់នៅកម្រិតថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់គ្រួសារ។ ឯកសារក្របខណ្ឌ័យុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០០៨-២០១២ នឹងត្រូវបានប្រើប្រាស់ជាឯកសារយោងយ៉ាងសំខាន់ សម្រាប់ធ្វើការពិចារណាឱ្យកាន់តែជិតដល់ និងមានលក្ខណៈជាប្រពន្ធ័ ក្នុងការរៀបចំយុទ្ធសាស្ត្រជាតិ និងគោលនយោបាយតាមវិស័យនានា។

ក្របខណ្ឌ័យុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដោយមានការពិភាក្សាយ៉ាងទូលំទូលាយ និងស៊ីជម្រៅជាមួយក្រសួង-ស្ថាប័នរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ពន្ធ័ និងជាពិសេសជាមួយក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលមានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងក្រសួងផែនការជាសហប្រធាន ហើយមានអង្គការកម្មវិធីស្បៀងអាហារពិភពលោក និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិជាអ្នកសម្របសម្រួលរួម ។ នៅឆ្នាំ២០០៨ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រុមប្រឹក្សាជាតិសម្រាប់អាហារូបត្ថម្ភដែលមានក្រសួងផែនការជាប្រធាននឹងរៀបចំកសាងផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជាថ្មី(២០០៨-២០១២) ដើម្បីបន្តអនុវត្តសកម្មភាពជាអាទិភាពមួយចំនួនដែលមានលើកឡើងនៅក្នុងឯកសារនេះ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការកែលំអសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅប្រទេសកម្ពុជាមានវឌ្ឍនភាពគួឱ្យកត់សំគាល់ ក៏ប៉ុន្តែនៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ ដើម្បីធានាបាននូវសន្តិសុខស្បៀង និងលុបបំបាត់កង្វះអាហារូបត្ថម្ភនៅប្រទេសកម្ពុជា។ ក្នុងន័យនេះ ក្របខណ្ឌ័យុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភនឹងជួយធ្វើជាមគ្គុទ្ទេសក៍សម្រាប់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានាក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន។

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០០៨

ឯកឧត្តម បណ្ឌិត តាវ សេងហួរ

ទេសរដ្ឋមន្ត្រីទទួលបន្ទុកជាប្រធានអាជ្ញាធរអាងទន្លេសាប និងជា

អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

# មាតិកា


| មាតិកា | ទំព័រ |
|---|---|
| **អក្សរកាត់** | ៤ |
| **សេចក្តីសង្ខេប** | ៧ |
| **១. សេចក្តីផ្តើម** | ១១ |
| ១.១. សារសំខាន់នៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា | ១១ |
| ១.២. ប្រវត្តិគោលនយោបាយសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា | ១៣ |
| **២. ការវិភាគស្ថានភាពទូទៅនៃសន្តិសុខស្បៀង និងបរិស្ថានគោលនយោបាយ** | ១៦ |
| ២.១. ការវិភាគស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា-*វឌ្ឍនភាព និងនិន្នាការ* | ១៦ |
| ២.១.១. កង្វះអាហារូបត្ថម្ភ និងមរណភាព | ១៦ |
| ២.១.២. ទិដ្ឋភាពទូទៅនៃមូលហេតុបណ្តាលឱ្យមានអសន្តិសុខស្បៀង | ២១ |
| ២.២. បរិបទស្ថាប័ន និងគោលនយោបាយនៃក្របខ័ណ្ឌសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅកម្ពុជា | ២៥ |
| **៣. ទស្សនវិស័យ គោលដៅ និងគោលបំណងនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** | ៣៣ |
| **៤. ក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០០៨-២០១២-*គោលបំណង និងសកម្មភាពជាអាទិភាព*** | ៣៥ |
| ៤.១. ការបង្កើនភាពមានស្បៀង | ៣៥ |
| ៤.១.១. ការកែលម្អផលិតភាពកសិកម្ម និងពិពិធកម្មកសិកម្ម | ៣៦ |
| ៤.១.២. ការកែលម្អការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ | ៤០ |
| ៤.១.៣. ការជំរុញកំណែទម្រង់ជលផល | ៤១ |
| ៤.១.៤. ការជំរុញកំណែទម្រង់ព្រៃឈើ | ៤៣ |
| ៤.២. ការបង្កើនភាពទទួលបានស្បៀង | ៤៥ |
| ៤.២.១. ការបង្កើនកាលានុវត្តភាពការងាររកកម្រៃ | ៤៧ |
| ៤.២.២. ការបង្កើនកាលានុវត្តភាពធុរកិច្ចមីសហគ្រាសខ្នាតតូច | ៤៩ |
| ៤.២.៣. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទីផ្សារ | ៥១ |
| ៤.២.៤. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដឹកជញ្ជូន | ៥២ |

| | |
|---|---|
| ៤.៣. ការកែលម្អការប្រើប្រាស់ និងការបឺតស្រូបស្បៀង | ៥៣ |
| ៤.៣.១. ការកាត់បន្ថយមរណភាពរបស់មាតា និងកុមារ | ៥៤ |
| ៤.៣.២. ការកែលម្អការផ្គត់ផ្គង់ទឹកស្អាតនៅតាមមូលដ្ឋាន និងរបៀបអនុវត្តអនាម័យ | ៦០ |
| ៤.៣.៣. ការកែលម្អសុវត្ថិភាពស្បៀង និងការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារ | ៦២ |
| ៤.៤. ការបង្កើនស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀង | ៦៣ |
| ៤.៤.១. ការកែលម្អបណ្តាញសុវត្ថិភាពសម្រាប់គ្រប់គ្រងគ្រោះធម្មជាតិ | ៦៣ |
| ៤.៤.២. ការបង្កើតបណ្តាញសុវត្ថិភាពសង្គមសម្រាប់ក្រុមជនងាយរងគ្រោះ | ៦៦ |
| ៤.៥. ការកែលម្អបរិស្ថានគោលនយោបាយ និងស្ថាប័នសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ | ៦៩ |
| ៤.៥.១. ការពង្រឹងសមត្ថភាព និងការកែលម្អការសម្របសម្រួលសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ | ៦៩ |
| ៤.៥.២. ការបញ្ជ្រាបបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភទៅក្នុងដំណើរការរៀបចំផែនការវិមជ្ឈការ | ៧១ |
| ៤.៥.៣. ការកែលម្អការគ្រប់គ្រងព័ត៌មានពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការកំណត់គោលដៅអន្តរាគមន៍ | ៧៣ |
| **៥. ការត្រួតពិនិត្យ និងវាយតម្លៃ** | ៧៧ |
| **ឧបសម្ព័ន្ធ ១: ឯកសារយោង** | ៨១ |
| **ឧបសម្ព័ន្ធ ២: ផែនទីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា** | ៨៣ |

# អក្សរកាត់

| | |
|---|---|
| CARD | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ |
| CDHS | ការអង្កេតប្រជាសាស្ត្រ និងសុខភាព |
| CMDGs | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| CPR | ធនធានធម្មជាតិ |
| CSES | ការអង្កេតសេដ្ឋកិច្ចសង្គម |
| FAO | អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ |
| FIVIMS | ប្រព័ន្ធព័ត៌មាន និងផែនទីតំបន់អសន្តិសុខស្បៀង និងភាពងាយរងគ្រោះ |
| FNPP | កម្មវិធីភាពជាដៃគូរវាងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ និងប្រទេសហូឡង់ |
| FSN | សន្តិសុខស្បៀង និងអាហារូបត្ថម្ភ |
| FSNIS | ប្រព័ន្ធព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ |
| GAP | ផែនការអភិបាលកិច្ច |
| GTZ | អង្គការសហប្រតិបត្តិការបច្ចេកទេសរបស់ប្រទេសអាល្លឺម៉ង់ |
| IO | អង្គការអន្តរជាតិ |
| IPM | វិធានការចម្រុះគ្រប់គ្រងដំណាំ |
| LMAP | គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MDGs | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| MEF | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| MIME | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MoC | ក្រសួងពាណិជ្ជកម្ម |
| MoE | ក្រសួងបរិស្ថាន |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | ក្រសួងសុខាភិបាល |
| MoI | ក្រសួងមហាផ្ទៃ |
| MLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoSAVYR | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |

| | |
|---|---|
| MoP | ក្រសួងផែនការ |
| MoWA | ក្រសួងកិច្ចការនារី |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| MPWT | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NAPA | កម្មវិធីជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ |
| NCDM | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| NPFSPR | កម្មវិធីជាតិសម្រាប់សន្តិសុខស្បៀងតាមគ្រួសារ និងការកាត់បន្ថយភាពក្រីក្រ |
| PNCC | គណៈកម្មាធិការសម្របសម្រួលអាហារូបត្ថម្ភខេត្ត |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RS | យុទ្ធសាស្ត្រចតុកោណ |
| SAW | យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក |
| TWGAW | ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក |
| TWG-FSN | ក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ |
| WFP | អង្គការកម្មវិធីស្បៀងអាហារពិភពលោក |
| WHO | អង្គការសុខភាពពិភពលោក |

**តារាង**


| | | |
|---|---|---|
| តារាង ១: | អត្រាកង្វះថាមពលប្រូតេអ៊ីនរបស់កុមារនៅកម្ពុជា ឆ្នាំ ២០០០ និង ២០០៥ | ១៦ |
| តារាង ២: | អត្រាកង្វះមីក្រូសារជាតិរបស់កុមារនៅកម្ពុជា ឆ្នាំ ២០០០ និង ២០០៥ | ១៧ |
| តារាង ៣: | អត្រាមរណភាពរបស់ទារក និងកុមារអាយុក្រោម ៥ ឆ្នាំ នៅកម្ពុជា ឆ្នាំ ២០០០ និង ២០០៥ | ១៨ |
| តារាង ៤: | ការប្រៀបធៀបអត្រាមរណភាពរបស់កុមារនៅកម្ពុជា ឆ្នាំ ២០០៥ ជាមួយប្រទេសជិតខាងក្នុងតំបន់ | ១៨ |
| តារាង ៥: | ចំនួនប៉ាន់ស្មាននៃកុមារទទួលរងផលប៉ះពាល់ ដោយសារកង្វះអាហារូបត្ថម្ភ និងមរណភាពនៅកម្ពុជា ឆ្នាំ ២០០០ និង ២០០៥ | ១៩ |
| តារាង ៦: | សមាសធាតុសាមញ្ញៗនៃអសន្តិសុខស្បៀង | ២២ |
| តារាង ៧: | តួនាទីក្នុងការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា | ២៧ |
| តារាង ៨: | គោលនយោបាយ/យុទ្ធសាស្ត្រពហុវិស័យ និងស្ថាប័នពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | ២៩ |
| តារាង ៩: | គោលនយោបាយ/យុទ្ធសាស្ត្រសំខាន់ៗតាមវិស័យនានា និងក្រសួងដែលពាក់ព័ន្ធនឹងសន្តិសុខស្បៀង និង អាហារូបត្ថម្ភ | ៣០ |
| តារាង ១០: | ប្រភពទិន្នន័យសម្រាប់ការត្រួតពិនិត្យយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ | ៧៨ |
| តារាង ១១: | ក្របខ័ណ្ឌសម្រាប់ត្រួតពិនិត្យយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ | ៧៩ |


**រូបភាព**


| | | |
|---|---|---|
| រូបភាព ១: | គោលគំនិតនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ | ២១ |


**ផែនទី**


| | |
|---|---|
| ផែនទី ១: | អត្រាក្រិនរបស់កុមារអាយុក្រោម៥ឆ្នាំ: *ភាគរយគិតតាមខេត្តនីមួយៗ នៅឆ្នាំ ២០០៥* |
| ផែនទី ២: | អត្រាទម្ងន់ស្រាលរបស់កុមារអាយុក្រោម៥ឆ្នាំ: *ភាគរយគិតតាមខេត្តនីមួយៗ នៅឆ្នាំ ២០០៥* |
| ផែនទី ៣: | អត្រាភាពស្គមស្គាំងរបស់កុមារអាយុក្រោម៥ឆ្នាំ: *ភាគរយគិតតាមខេត្តនីមួយៗ នៅឆ្នាំ ២០០៥* |
| ផែនទី ៤: | អត្រាមរណភាពរបស់កុមារអាយុក្រោម៥ឆ្នាំ: *ភាគរយគិតតាមខេត្តនីមួយៗ នៅឆ្នាំ ២០០៥* |
| ផែនទី ៥: | ការវិភាគចំណាត់ថ្នាក់សម្រាប់ការងារសន្តិសុខស្បៀង និងជំនួយមនុស្សធម៌នៅកម្ពុជា (IPC) របស់ អង្គការកម្មវិធីស្បៀងអាហារពិភពលោក (WFP) (២៦ កុម្ភៈ ២០០៧) |

## សេចក្តីសង្ខេប


ក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ២០០៨-២០១២ គឺជាឯកសារយោងស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភដែលជាបញ្ហាពហុវិស័យ។ ឯកសារនេះត្រូវបានរៀបចំតាក់តែងឡើង នៅឆ្នាំ ២០០៧ ដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដោយសហការជាមួយក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺជាអាទិភាពសម្រាប់អភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិ រួមមានៈ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា យុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០។ លើសពីនេះទៀត វាគឺជាអាទិភាពមួយដែលត្រូវបានទទួលស្គាល់នៅក្នុងគោលនយោបាយតាមវិស័យរបស់រដ្ឋាភិបាលជាច្រើន រួមមានៈ វិស័យកសិកម្ម ធនធានទឹក អប់រំ សុខាភិបាល ការអភិវឌ្ឍន៍សេដ្ឋកិច្ច ។ល។

វិស័យអាទិភាពសម្រាប់អភិវឌ្ឍន៍ទាំងអស់នេះបានឆ្លុះបញ្ចាំងពីកង្វល់ទាំងឡាយ ដែលប្រជាពលរដ្ឋកម្ពុជាជាច្រើនប្រឈមមុខនឹងកង្វះអាហារូបត្ថម្ភនិងអសន្តិសុខស្បៀងនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ ទោះបីជាប្រទេសកម្ពុជាអាចផលិតស្រូវគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់នៅកម្រិតថ្នាក់ជាតិ និងទោះបីជាស្ថានភាពទូទៅនៃអាហារូបត្ថម្ភមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក៏ដោយ។

នៅឆ្នាំ ២០០៤ ប្រជាពលរដ្ឋកម្ពុជា ៣៤,៧ភាគរយ រស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ហើយ៩០ភាគរយនៃប្រជាពលរដ្ឋក្រីក្រទាំងនេះរស់នៅជនបទ។ នៅឆ្នាំ២០០៣-២០០៤ នៅទូទាំងប្រទេស ប្រជាពលរដ្ឋចំនួន២៣ភាគរយ ឬស្មើនឹង៣លាន នាក់ មានស្បៀងបរិភោគមិនគ្រប់គ្រាន់ គឺថា ពួកគាត់បរិភោគបានតិចជាងតម្រូវការថាមពលអាហារអប្បបរមា (១៧១៥ គីឡូកាឡូរីក្នុងម្នាក់ក្នុងមួយថ្ងៃ)។ នៅឆ្នាំ ២០០៥ មានកុមារអាយុក្រោម៥ឆ្នាំ ប្រមាណ ៣៧ភាគរយ ឬចំនួនច្រើនជាង ៦៣០.០០០នាក់ រងគ្រោះដោយបញ្ហាកង្វះថាមពល ប្រូតេអ៊ីនរ៉ាំរ៉ៃ (ក្រិន) ហើយមានកុមារអាយុក្រោម៥ឆ្នាំ ចំនួន៧ភាគរយ មានបញ្ហាកង្វះអាហារូបត្ថម្ភយ៉ាងធ្ងន់ធ្ងរ (ស្គមរីងរៃ)។ ម្យ៉ាងវិញទៀត កុមារអាយុក្រោម២ឆ្នាំចំនួន៦០ភាគរយទទួលរងគ្រោះដោយសារបញ្ហាស្លេកស្លាំង (ជំងឺខ្វះឈាមក្រហម)។ បញ្ហាកង្វះអាហារូបត្ថម្ភ គឺជាមូលហេតុដ៏ចម្បងដែលបណ្តាលឱ្យអត្រាមរណភាពរបស់កុមារ និងមាតាមានកម្រិតខ្ពស់ ។

ប្រជាពលរដ្ឋក្រីក្រ និងអសន្តិសុខស្បៀងប្រឈមមុខនឹងឧបសគ្គជាច្រើនក្នុងការកែលម្អសន្តិសុខស្បៀងរបស់ពួកគាត់ ។ ការវិភាគស្ថានភាពនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនេះបានបញ្ជាក់អំពីឧបសគ្គដែលមាននៅក្នុងវិស័យកសិកម្ម ព្រៃឈើ ជលផល និងកង្វះប្រាក់ចំណូលក្នុងគ្រួសារ សុខភាពមាតា ការអនុវត្តរបៀបគាំពារមាតានិងទារក លទ្ធភាពក្នុងការទទួលបានសេវាសុខភាពដែលមានគុណភាព ទឹកស្អាត និងអនាម័យ ព្រមទាំងអស្ថេរភាពក្នុងការផ្គត់ផ្គង់ស្បៀង ដែលបណ្តាលមកពីគ្រោះមហន្តរាយផ្សេងៗ ដូចជាៈ ទឹកជំនន់ គ្រោះរាំងស្ងួត និងភាពងាយរងគ្រោះខាងផ្នែកសេដ្ឋកិច្ច-សង្គម ។ ការកើនឡើងនៃតម្លៃស្បៀងគឺជាបញ្ហាប្រឈម

បន្ថែមទៀតសម្រាប់ប្រជាពលរដ្ឋកម្ពុជក្រីក្រ ក្នុងការទទួលបានស្បៀងគ្រប់គ្រាន់សម្រាប់បរិភោគ ដោយហេតុថាជាមធ្យមពួកគាត់ចំណាយប្រមាណជាង៧០ភាគរយនៃប្រាក់ចំណូលសម្រាប់ទិញស្បៀងអាហារ។

ការបង់ខាតផ្នែកសេដ្ឋកិច្ច និងសង្គមទៅលើបញ្ហាកង្វះអាហារូបត្ថម្ភនៅកម្ពុជាមានកម្រិតខ្ពស់ ។ ទន្ទឹមនឹងនេះ ការវិនិយោគលើការកែលម្អស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលប៉ាន់ស្មានថាទទួលបានអនុបាតនៃតម្លៃ(អត្រាផលប្រយោជន៍ខាងតម្លៃ)ចំនួន១:៨ ពិតជាអាចទទួលបានផលប្រយោជន៍ត្រឡប់មកវិញយ៉ាងច្រើនសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិ ។ ការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅប្រទេសកម្ពុជាតម្រូវឱ្យមានសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ និងមានយន្តការសម្របសម្រួលដ៏មានប្រសិទ្ធភាពដើម្បីផ្សារភ្ជាប់ទំនាក់ទំនងរវាងអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងជួររដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នានា។ នៅក្នុងបរិបទនេះ ក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ២០០៨-២០១២ គឺមានទិសដៅបម្រើសេវាកម្មជាក្របខ័ណ្ឌយោងរួមមួយ ដែលមានលក្ខណៈពហុវិស័យសម្រាប់ការរៀបចំ និងពិនិត្យមើលឡើងវិញនូវយុទ្ធសាស្ត្រតាមវិស័យ និងដើម្បីណែនាំដល់ការរៀបចំកម្មវិធី និងគម្រោងនានាសម្រាប់កែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា។

ក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ឆ្នាំ២០០៨-២០១២ រួមមាន: ទស្សនវិស័យ គោលដៅ និងគោលបំណង ចំនួន៥ ។

**ទស្សនវិស័យរយៈពេលវែងនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** គឺការសម្រេចបានសន្តិសុខស្បៀង និងអាហារូបត្ថម្ភគ្រប់គ្រាន់សម្រាប់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ។ ទស្សនវិស័យនេះស្របទៅនឹងទិសដៅជាសកលនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍និងស្របតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ដូច្នេះ ទស្សនវិស័យនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺ :

***"ប្រជាពលរដ្ឋកម្ពុជាក្រីក្រ និងអសន្តិសុខស្បៀងទាំងអស់ នឹងមានលទ្ធភាពល្អប្រសើរទាំងផ្នែករូបវ័ន្ត និងផ្នែកសេដ្ឋកិច្ចក្នុងការទទួលបានស្បៀងអាហារមានសុវត្ថិភាព និងមានជីវជាតិគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការរបបអាហារ និងចំណង់ចំណូលចិត្តនៅគ្រប់ពេលវេលាទាំងអស់ សម្រាប់ជីវិតរស់នៅយ៉ាងសកម្ម និងមានសុខភាពមាំមួន"*** ។

**គោលដៅនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** គឺផ្តោតលើការសម្រេចបាននូវវឌ្ឍនភាពក្នុងការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ។ គោលដៅនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភត្រូវបានបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០០៦-២០១០ ហើយស្របតាមវឌ្ឍនភាពក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាក្នុងរយៈពេលមធ្យម ។ ដូច្នេះ គោលដៅនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺ :

***"ត្រឹមឆ្នាំ២០១២ ប្រជាពលរដ្ឋកម្ពុជាក្រីក្រ និងអសន្តិសុខស្បៀងនឹងមានលទ្ធភាពល្អប្រសើរច្រើនទាំងផ្នែករូបវ័ន្ត និងផ្នែកសេដ្ឋកិច្ច ក្នុងការទទួលបានស្បៀងអាហារមានសុវត្ថិភាព និងមានជីវជាតិគ្រប់គ្រាន់ ដើម្បី***

***បំពេញតម្រូវការរបបអាហារ និងចំណង់ចំណូលចិត្តនៅគ្រប់ពេលវេលាទាំងអស់ សម្រាប់ជីវិតរស់នៅយ៉ាងសកម្ម និងមានសុខភាពមាំមួន" ។***

**គោលបំណងនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០០៨-២០១២**

ក្របខ័ណ្ឌយុទ្ធសាស្ត្រ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០០៨-២០១២ មានគោលបំណងចំនួនប្រាំ។ គោលបំណងនីមួយៗ បានកំណត់វិស័យជាច្រើនសម្រាប់ធ្វើអន្តរាគមន៍ និងមានសកម្មភាពជាអាទិភាពជាក់លាក់ជាច្រើនដែលត្រូវអនុវត្ត។ គោលបំណងនីមួយៗនឹងតម្រូវឱ្យមានការវិនិយោគលើសេវាកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងការកសាងសមត្ថភាពក្នុងវិស័យនានាជាច្រើនរបស់ក្រសួង និងស្ថាប័នសម្របសម្រួលរបស់រដ្ឋាភិបាល ។

**គោលបំណងទី១:** ក្រុមគ្រួសារអសន្តិសុខស្បៀង**បង្កើនភាពមានស្បៀង**តាមរយៈផលិតកម្មកសិកម្ម និងបសុសត្វ និងតាមរយៈធនធានជលផល និងអនុផលព្រៃឈើ ។

**គោលបំណងទី២:** ក្រុមគ្រួសារអសន្តិសុខស្បៀង**បង្កើនភាពទទួលបានស្បៀង**តាមរយៈការបង្កើនប្រាក់ចំណូលក្នុងគ្រួសារ ។

**គោលបំណងទី៣:** ក្រុមគ្រួសារអសន្តិសុខស្បៀង**កែលម្អការប្រើប្រាស់និងការបឺតស្រូបស្បៀង** ដើម្បីកាត់បន្ថយបញ្ហាកង្វះអាហារូបត្ថម្ភ ជំងឺដង្កាត់ និងមរណភាព ជាពិសេសក្នុងចំណោមស្ត្រី និងកុមារ ។

**គោលបំណងទី៤ :** កែលម្អបណ្តាញសុវត្ថិភាពសង្គម និងលើកកម្ពស់សមត្ថភាពរបស់ក្រុមគ្រួសារអសន្តិសុខស្បៀងក្នុងការដោះស្រាយហានិភ័យផ្សេងៗ នឹងជួយ**បង្កើនស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀង**។

**គោលបំណងទី៥:** **កែលម្អបរិស្ថានគោលនយោបាយ និងស្ថាប័ន** ដើម្បីសម្រេចបានការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា។

មាតិកានៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០០៨-២០១២ ត្រូវបានរៀបចំជាប្រាំផ្នែក ។

**<u>ផ្នែកទី១</u>** ណែនាំ និងអត្ថាធិប្បាយដោយសង្ខេបអំពីសារសំខាន់នៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជាបច្ចុប្បន្ន និងបង្ហាញពីប្រវត្តិគោលនយោបាយសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។ **<u>ផ្នែកទី២</u>** ផ្តល់ជូននូវការវិភាគស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភទូទៅនាពេលបច្ចុប្បន្នដែលបង្ហាញពីលទ្ធផលសន្តិ-សុខស្បៀង និងអាហារូបត្ថម្ភ រួមមានៈ កង្វះអាហារូបត្ថម្ភនិងមរណភាព និងការពិនិត្យសិក្សាអំពីបរិបទស្ថាប័ន និងគោលនយោបាយ ។ **<u>ផ្នែកទី៣</u>** បង្ហាញយ៉ាងពិស្តារអំពីទស្សនវិស័យ គោលដៅ និងគោលបំណងនៃឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។ **<u>ផ្នែកទី៤</u>** ផ្តល់សេចក្តីអត្ថាធិប្បាយអំពីគោលបំណងទាំងប្រាំ។ សេចក្តីអត្ថាធិប្បាយទាំងនេះ រួមមានៈ ការវិភាគស្ថានភាពជាក់ស្តែងតាមវិស័យនីមួយៗដែលជាបុព្វហេតុ

បណ្តាលឱ្យមានបញ្ហាកង្វះអាហារូបត្ថម្ភ និងអសន្តិសុខស្បៀង ហើយបង្ហាញពីសន្និទានភាពសម្រាប់សកម្មភាពជាអាទិភាពជាក់ស្តែងតាមវិស័យនីមួយៗ ។ ផ្នែកនេះបង្ហាញអំពីទំនាក់ទំនងដោយផ្ទាល់រវាងឧបសគ្គ និងសកម្មភាពតាមវិស័យនីមួយៗ។ **<u>ផ្នែកទី៥</u>** គូសបញ្ជាក់អំពីក្របខ័ណ្ឌត្រួតពិនិត្យ ដើម្បីតាមដានវឌ្ឍនភាពក្នុងការសម្រេចគោលបំណងនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។

ទោះបីជាមានវឌ្ឍនភាពជាក់ស្តែងក្នុងការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ ក៏នៅមានកិច្ចការជាច្រើនដែលត្រូវធ្វើដើម្បីជំនះរាល់ទុក្ខវេទនាទាំងឡាយដែលបណ្តាលមកពីបញ្ហាកង្វះស្បៀងអាហារក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកម្ពុជា ។ ម្យ៉ាងវិញទៀត ថ្វីបើមានបញ្ហាប្រឈមជាច្រើនក៏ដោយ ក៏ត្រឹមឆ្នាំ២០១២ យើងនឹងអាចសម្រេចគោលដៅក្នុងការកែលម្អសន្តិសុខស្បៀងនិងអាហារូបត្ថម្ភប្រកបដោយនិរន្តរភាពសម្រាប់ប្រជាពលរដ្ឋកម្ពុជាក្រីក្រ និងអសន្តិសុខស្បៀង តាមរយៈការខិតខំប្រឹងប្រែងរួមគ្នាដើម្បីសម្រេចគោលបំណងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទាំងប្រាំ ។

## ១. សេចក្តីផ្តើម

### ១.១. សារសំខាន់នៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា

សន្តិសុខស្បៀង និងអាហារូបត្ថម្ភត្រូវបានទទួលស្គាល់ជាទូទៅ ថាជាសមាសធាតុគន្លឹះយ៉ាងសំខាន់ក្នុងការអភិវឌ្ឍជាតិ អភិបាលកិច្ចល្អ និងសិទ្ធិមនុស្សជាមូលដ្ឋាន។ និយមន័យនៃសន្តិសុខស្បៀងដែលគេទទួលស្គាល់ជាទូទៅគឺ: ***"សន្តិសុខស្បៀងកើតមាននៅពេលដែលប្រជាពលរដ្ឋគ្រប់រូបមានលទ្ធភាពទាំងផ្នែករូបវ័ន្ត និងផ្នែកសេដ្ឋកិច្ចក្នុងការទទួលបានស្បៀងអាហារមានសុវត្ថិភាព និងមានជីវជាតិគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការរបបអាហារ និងចំណង់ចំណូលចិត្តនៅគ្រប់ពេលវេលាទាំងអស់សម្រាប់ជីវិតរស់នៅយ៉ាងសកម្ម និងមានសុខភាពមាំមួន"***[១] ។

សន្តិសុខស្បៀង និងអាហារូបត្ថម្ភត្រូវបានទទួលស្គាល់និងចាត់ទុកថាជាសិទ្ធិមនុស្សជាមូលដ្ឋាន ក្រោមច្បាប់អន្តរជាតិ ។ ពិសេសជាងនេះទៅទៀត អនុសញ្ញាស្តីពីសិទ្ធិទទួលបានស្បៀង គឺស្ថិតនៅក្រោមយុត្តាធិការរបស់ស្នងការជាន់ខ្ពស់នៃអង្គការសហប្រជាជាតិសម្រាប់សិទ្ធិមនុស្ស ។ សិទ្ធិទទួលបានស្បៀងក៏ត្រូវបានទទួលស្គាល់ផងដែរក្នុងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស និងសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច-សង្គម និងប្រពៃណី[២] ។

សារសំខាន់ក្នុងការសម្រេចបានសន្តិសុខស្បៀងត្រូវបានឆ្លុះបញ្ចាំងយ៉ាងច្បាស់នៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ជាសកល ២០០០-២០១៥ របស់អង្គការសហប្រជាជាតិ ហើយជាពិសេស គោលដៅទី១នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ចែងថាៈ **"លុបបំបាត់ភាពក្រីក្រ និងភាពស្រេកឃ្លាន"**។ ម្យ៉ាងវិញទៀត គោលដៅទី១នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដែលបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា នៅឆ្នាំ២០០៣ ក៏បានចែងថាៈ **"លុបបំបាត់ភាពក្រីក្រ និងភាពស្រេកឃ្លាន"**។ ជាងនេះទៅទៀត ការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភគឺពិតជាមានសារសំខាន់យ៉ាងខ្លាំងក្នុងការសម្រេចគោលដៅផ្សេងៗទៀតនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។ ក្នុងន័យនេះ តួនាទីនៃការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបានបង្ហាញនៅក្នុងផ្នែកទី២នៃតារាង ៧ ។

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ចាំបាច់ត្រូវសម្រេចឱ្យបានតាមរយៈយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា[៣] ដែលត្រូវដាក់ឱ្យដំណើរការអនុវត្តក្នុងក្របខ័ណ្ឌ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ ។ គោលនយោបាយយុទ្ធសាស្ត្រ និងផែនការតាមវិស័យនានាចាំបាច់គួរតែស្របជាមួយនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាទូទៅរបស់រាជរដ្ឋាភិបាល ។ ដូចដែលបានបញ្ជាក់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដែលថា **"ការកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់រហ័សតាមដែលធ្វើទៅបាន គឺជាអាទិភាពដំបូងគេបំផុតរបស់រាជរដ្ឋាភិបាលកម្ពុជា"**[៤] ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិពិតជាទទួលស្គាល់ និងបង្ហាញយ៉ាងច្បាស់

---

[១] កិច្ចប្រជុំកំពូលស្បៀងអាហារពិភពលោកស្តីពីផែនការសកម្មភាព (ទីក្រុងរ៉ូម ប្រទេសអ៊ីតាលី ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ ១៩៩៦)

[២] របាយការណ៍ ឆ្នាំ ២០០២ ស្តីពីសិទ្ធិទទួលបានអាហារ ដោយ Mary Robinson ឧត្តមស្នងការរបស់អង្គការសហប្រជាតិសម្រាប់សិទ្ធិមនុស្សក្នុងកិច្ចប្រជុំកំពូលស្តីពីស្បៀងអាហារពិភពលោក (វិបសាយ http://www.righttofood.org);

[៣] យុទ្ធសាស្ត្រចតុកោណ ឆ្នាំ ២០០៤ របស់រាជរដ្ឋាភិបាលកម្ពុជា

[៤] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦ របស់រាជរដ្ឋាភិបាលកម្ពុជា ទំព័រទី ២៩

ថា តម្រូវការក្នុងការជំរុញវឌ្ឍនភាពបន្ថែមទៀតក្នុងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺជាសកម្មភាពចម្បង សម្រាប់សម្រេចគោលដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ[៥] ។

កង្វល់នេះឆ្លុះបញ្ចាំងឱ្យឃើញពីស្ថានភាពដែលប្រជាពលរដ្ឋកម្ពុជាជាច្រើនកំពុងជួបប្រទះនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ គឺស្ថានភាពក្រីក្រនិងភាពស្រេកឃ្លាន ។ ទោះបីជាមានការរីកចម្រើនគួរឱ្យកត់សំគាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយក៏ដោយ ក៏បញ្ហាកង្វះអាហារូបត្ថម្ភ និងអសន្តិសុខស្បៀងនៅតែកើតមាននៅក្នុងប្រទេសកម្ពុជានៅឡើយ ។

នៅឆ្នាំ ២០០៤ មានប្រជាពលរដ្ឋកម្ពុជាក្រីក្រចំនួន ៣៤.៧ភាគរយ ដែលក្នុងចំនួននេះ មាន ៩០ភាគរយ រស់នៅតាមទីជនបទ[៦] ។ នៅឆ្នាំ២០០៥ មានកុមារដែលមានអាយុក្រោម ៥ឆ្នាំ ជាង ៦៣០.០០០ ស្មើនឹង ៣៧ភាគរយ រងគ្រោះដោយសារបញ្ហាកង្វះថាមពលប្រូតេអ៊ីនរ៉ាំរ៉ៃ (ក្រិន) ។ អត្រាកង្វះមីក្រូសារជាតិក៏មានកម្រិតខ្ពស់ផងដែរ បើប្រៀបទៅនឹងប្រទេសជិតខាង ។ ៥៤ភាគរយនៃការស្លាប់មុនអាយុរបស់កុមារកម្ពុជា (មួយភាគប្រាំបីនៃកុមារកម្ពុជាបានស្លាប់នៅអាយុក្រោម៥ឆ្នាំ)[៧] មានជាប់ពាក់ព័ន្ធនឹងបញ្ហាកង្វះអាហារូបត្ថម្ភ ។

នៅឆ្នាំ២០០៣-២០០៤ នៅទូទាំងប្រទេស ប្រជាពលរដ្ឋចំនួន២៣ភាគរយ ឬស្មើនឹង ៣លាននាក់មានស្បៀងបរិភោគមិនគ្រប់គ្រាន់ គឺថា ពួកគាត់បរិភោគបានតិចជាងតម្រូវការថាមពលអាហារអប្បបរមា ១៧១៥គីឡូកាឡូរីក្នុងម្នាក់ក្នុងមួយថ្ងៃ ចំណែកឯ៨០ភាគរយទៀតមិនមានតុល្យភាពរបបអាហារ ។ នៅទូទាំងប្រទេស អត្រាប្រេវ៉ាឡង់នៃភាពក្រីក្រស្បៀងអាហារកម្រិតធ្ងន់(សំដៅលើសមាមាត្រនៃប្រជាពលរដ្ឋដែលចំណាយតិចជាងតម្លៃនៃតុល្យភាពរបបអាហារសម្រាប់បំពេញតម្រូវការថាមពលអប្បបរមាប្រចាំថ្ងៃ) មានចំនួនប្រមាណ ២១.៤ភាគរយ[៨] ។

ការខាតបង់ផ្នែកសេដ្ឋកិច្ច និងសង្គមទៅលើបញ្ហាកង្វះអាហារូបត្ថម្ភនៅកម្ពុជាមានកម្រិតខ្ពស់ ។ ការខាតបង់ផ្នែកសង្គមរួមមានៈ សុខភាពរបស់បុគ្គលម្នាក់ៗនិងសក្តានុពលនៃការវិវត្តន៍សរីរវិទ្យាមានកម្រិត ទុក្ខវេទនានិងការឈឺចាប់មានកម្រិតខ្ពស់ ភាពទន់ខ្សោយ និងការស្លាប់មុនអាយុក្នុងចំណោមអ្នកមានបញ្ហាកង្វះអាហារូបត្ថម្ភ ។ ការខាតបង់ផ្នែកសេដ្ឋកិច្ចរួមមានៈ ឧបសគ្គក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ដោយសារការអប់រំមាន កម្រិតទាប ការចំណាយខ្ពស់លើការថែទាំសុខភាព គុណភាពកម្លាំងពលកម្មទាប និងការកើនឡើងនៃភាពងាយ រងគ្រោះដោយសារផលប៉ះពាល់នៃគ្រោះធម្មជាតិ ។

ទន្ទឹមនឹងនេះ ការវិនិយោគក្នុងការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបានបង្ហាញឱ្យឃើញយ៉ាងច្បាស់អំពីការទទួលផលប្រយោជន៍ត្រឡប់មកវិញសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិ ។ ផលប្រយោជន៍ទាំងនេះរួមមានៈ ការទទួលបានសុខភាពល្អ និងការអប់រំបានល្អប្រសើរ ធ្វើឱ្យកម្លាំងពលកម្មមានគុណភាពល្អ ដែល

---

[៥] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦ របស់រាជរដ្ឋាភិបាលកម្ពុជា ទំព័រទី៤៧ ផ្នែក៤.៤៦

[៦] ការអង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជា ឆ្នាំ ២០០៤ របស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ

[៧] ការអង្កេតប្រជាសាស្ត្រ និងសុខភាព កម្ពុជា ឆ្នាំ ២០០៥ និង កម្រងផែនទីសន្តិសុខស្បៀង របស់អង្គការកម្មវិធីស្បៀងអាហារពិភពលោក វគ្គ ១.០

[៨] របាយការណ៍សង្ខេបស្តីពីការវាយតម្លៃអសន្តិសុខស្បៀងនៅកម្ពុជា ដោយវិទ្យាស្ថានជាតិស្ថិតិ សហការជាមួយអង្គការ FAO និង EU ឆ្នាំ ២០០៧

ជាសក្តានុពលយ៉ាងប្រសើរសម្រាប់ការអភិវឌ្ឍ[៩] ។ ការវិយោគក្នុងការកែលម្អស្ថានភាពសន្តិសុខស្បៀង និងអាហា-រូបត្ថម្ភត្រូវបានធ្វើការប៉ាន់ស្មានថាទទួលបានអនុបាតនៃតម្លៃ (អត្រាផលប្រយោជន៍ខាងតម្លៃ) ចំនួន ១:៨ [១០] ។ ចំណែកផលប្រយោជន៍សង្គមមួយចំនួនទៀត រួមមានៈ ការជួយជំរុញវឌ្ឍនភាពផ្ទៃក សមភាពយែនឌ័រ ការកាត់បន្ថយចំណាកស្រុកពីជនបទមកទីក្រុង ការកែលម្អនិរន្តរភាពបរិស្ថាន និងជីវភាពរស់ នៅរបស់យុវជនកាន់តែល្អប្រសើរឡើង [១១] ។

នៅកម្ពុជាក៏ដូចជានៅលើសកលលោកមានការទទួលស្គាល់ថា ដើម្បីកែលម្អសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ យើងត្រូវចាត់ទុកថា សន្តិសុខស្បៀង និងអាហារូបត្ថម្ភជាបញ្ហាពហុវិស័យ បើនិយាយអំពីការធ្វើអន្តរាគមន៍លើផ្នែកគោលនយោបាយ និងកម្មវិធី ។ នេះក៏ដោយសារថា លទ្ធផលនៃអសន្តិសុខស្បៀង (កង្វះអាហារូបត្ថម្ភ និងជំងឺដង្កាត់) បណ្តាលមកពីកត្តាអន្តរសកម្មផ្សេងៗជាច្រើន ។ កត្តាដែលបណ្តាលឱ្យមានបញ្ហាអសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភរួមមានៈ អសមត្ថភាពក្នុងការផលិតស្បៀងអាហារឱ្យបានគ្រប់គ្រាន់ ចំណូលមិនគ្រប់គ្រាន់សម្រាប់ទិញស្បៀងនៅទីផ្សារ និងកង្វះចំណេះដឹង ឬសេវាកម្មសម្រាប់ការគាំទ្រសុខភាព និងអាហារូបត្ថម្ភ ។ កត្តាមួយទៀត គឺអស្ថេរភាពក្នុងការផ្គត់ផ្គង់ និងទទួលបានស្បៀងសម្រាប់ធានាឱ្យមានអាហារូបត្ថម្ភគ្រប់គ្រាន់ដោយសារតែគ្រោះមហន្តរាយផ្សេងៗដែលជាហេតុបណ្តាលឱ្យមានបម្រែបម្រួលចំណូលឬតម្លៃស្បៀង ។

យើងក៏ទទួលស្គាល់ផងដែរថា លទ្ធផលល្អប្រសើរនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភមិនមែនបានមកដោយស្វ័យប្រវត្តិពីការកាត់បន្ថយភាពក្រីក្រ នោះទេ ប៉ុន្តែវាទាមទាឱ្យមានការរៀបចំធ្វើគម្រោងអន្តរាគមន៍ ជាពិសេសដើម្បីបំពេញបន្ថែមយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ [១២] ។

## ១.២. ប្រវត្តិគោលនយោបាយសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

រដ្ឋាភិបាលខ្មែរក្រហមពីឆ្នាំ១៩៧៥-១៩៧៩ បណ្តាលឱ្យកើតមានបញ្ហាកង្វះអាហារូបត្ថម្ភនិងភាពក្រីក្រទូទាំងប្រទេស ។ បន្ទាប់ពីមានការបង្កើតរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៩៣ ក្របខ័ណ្ឌគោលនយោបាយជាតិថ្មីៗជាច្រើនត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ ។ ក្របខ័ណ្ឌគោលនយោបាយទាំងនេះរួមមានៈ កម្មវិធីជាតិនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ឆ្នាំ១៩៩៤ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម៥ឆ្នាំលើកទី១ (១៩៩៦-២០០០) ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមទី២ (២០០១-២០០៥) និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (២០០៣-២០០៥) ។

ក្របខ័ណ្ឌគោលនយោបាយជាតិទាំងអស់សុទ្ធតែមានសង្គតិភាព (ភាពត្រូវគ្នា) តែមួយ គឺផ្តល់អាទិភាពខ្ពស់ក្នុងការកាត់បន្ថយភាពក្រីក្រ និងភាពស្រេកឃ្លាន ។

---

៩ ផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា ២០០៣-២០០៧ របស់ក្រសួងផែនការ និង ឯកសាររបស់ធនាគារពិភពលោកឆ្នាំ២០០៦ ស្តីពីយុទ្ធសាស្ត្រសម្រាប់សកម្មភាពទ្រង់ទ្រាយធំ ។

១០ ផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា ២០០៣-២០០៧

១១ គោលនយោបាយប្រជាពលរដ្ឋឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាលកម្ពុជា

១២ ឯកសាររបស់ធនាគារពិភពលោកឆ្នាំ២០០៦ ស្តីពីយុទ្ធសាស្ត្រសម្រាប់សកម្មភាពទ្រង់ទ្រាយធំ

នៅក្នុងដំណាក់កាលនេះ រដ្ឋាភិបាលបានផ្តួចផ្តើមគំនិត រៀបចំគោលនយោបាយពហុវិស័យសំខាន់ៗមួយចំនួនទៀត រួមមានៈ ការចេញសារាចរពីរស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅឆ្នាំ១៩៩៩ និងឆ្នាំ ២០០៣[១៣] ។ សារាចរទាំងពីរនេះបានលើកឡើងពីសារសំខាន់នៃការកែលម្អសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ហើយបញ្ជាក់យ៉ាងច្បាស់ពីវិធានការនានា ដែលអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវតែអនុវត្តដើម្បីសម្រេចឱ្យបានជោគជ័យក្នុងការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ ជាងនេះទៅទៀត ដោយមានមហិច្ឆិតាចង់បានកំណែទម្រង់អភិបាលកិច្ចល្អ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តផែនការសកម្មភាពអភិបាលកិច្ចរបស់ខ្លួន ដែលក្នុងនោះ ផែនការសកម្មភាពអភិបាលកិច្ចទី១ត្រូវបានអនុម័តនៅខែមីនា ឆ្នាំ២០០១ និងផែនការសកម្មភាពអភិបាល-កិច្ចទី២ (២០០៥-២០០៨) ត្រូវបានអនុម័តនៅឆ្នាំ២០០៦។ ផែនការសកម្មភាពអភិបាលកិច្ចទី២គ្របដណ្តប់លើវិស័យអភិបាលកិច្ចសំខាន់ៗពាក់ព័ន្ធគ្នាចំនួន៩ ដែលមានឥទ្ធិពលដោយផ្ទាល់ទៅលើការកាត់បន្ថយភាពក្រីក្រ និងសន្តិសុខស្បៀង[១៤] ។

ទោះបីជាក្របខ័ណ្ឌគោលនយោបាយទាំងនេះ ជាសមិទ្ធផលយ៉ាងធំធេងរបស់រាជរដ្ឋាភិបាលក៏ដោយ ក៏ការអនុវត្តតែងតែជួបប្រទះការលំបាកជាច្រើនដោយសារមានបញ្ហាក្នុងការសម្របសម្រួល និងសមត្ថភាពរបស់ស្ថាប័ននៅមានកម្រិត។ បើនិយាយពីបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ឥទ្ធិពលរបស់វានៅមានកម្រិតដោយសារតែគ្មានការបញ្ជាក់ឱ្យបានច្បាស់អំពីមូលហេតុ និងអត្រានៃអសន្តិសុខស្បៀងនិងកង្វះអាហារូបត្ថម្ភ និងដោយសារកង្វះខាតយុទ្ធសាស្ត្រទូលំទូលាយសម្រាប់ដោះស្រាយបញ្ហាទាំងនេះ ។

យើងគួរតែទទួលស្គាល់ផងដែរថា ស្របពេលដែលក្របខ័ណ្ឌគោលនយោបាយជាតិ និងគោលនយោបាយតាមវិស័យពាក់ព័ន្ធនានា[១៥] កំពុងត្រូវបានរៀបចំឡើង កម្មវិធីមួយចំនួនដែលមានគោលដៅបង្កើនសន្តិសុខស្បៀងបានចាប់ផ្តើមរួចជាស្រេចហើយ ដែលក្នុងនោះមានកម្មវិធីមួយចំនួនបានចាប់ផ្តើមតាំងពីទសវត្សឆ្នាំ១៩៨០[១៦] ។

---

១៣ រាជរដ្ឋាភិបាលកម្ពុជាចេញសារាចរទី១ លេខ ០៥ ស.រ ចេញនៅឆ្នាំ ១៩៩៩ និងសារាចរទី២ លេខ ០៣ ស.រ ចេញនៅឆ្នាំ ២០០៣

១៤ ដោយបានចូលរួមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្នុងឆ្នាំ ២០០៥ ក្រុមការងារបច្ចេកទេស សន្តិសុខស្បៀង និងអាហារូបត្ថម្ភ តាមរយៈក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទក៏បានផ្តល់ ឯកសារបច្ចុប្បន្នភាព សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទៅក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដើម្បីបញ្ចូលទៅក្នុងផែនការអភិបាលកិច្ចទី ២

១៥ បើនិយាយអំពីភាពមានស្បៀង គោលនយោបាយកសិកម្មជាបន្តបន្ទាប់ បានបញ្ជាក់យ៉ាងច្បាស់ថា ការកែលម្អសន្តិសុខស្បៀងគឺជាអាទិភាពគន្លឹះក្នុងការអភិវឌ្ឍវិស័យកសិកម្ម ។ ឯកសារគោលនយោបាយស្តីពី ធនធានធម្មជាតិរួម( ព្រៃឈើ និងជលផល) បានទទួលស្គាល់ពីសារសំខាន់នៃតួនាទីរបស់រាជរដ្ឋាភិបាលក្នុងការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ បើនិយាយអំពីលទ្ធភាពទទួលបានស្បៀង គោលនយោបាយតាមវិស័យស្ទើរតែទាំងអស់សុទ្ធតែបានទទួលស្គាល់អំពីកង្វះប្រាក់ចំណូលនិងតម្រូវការក្នុងការបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋក្រីក្រដើម្បីឱ្យគាត់អាចបំពេញតម្រូវការជាមូលដ្ឋានដែលរួមមានៈ ស្បៀងអាហារផងដែរ ។ បើនិយាយអំពីការប្រើប្រាស់ និងការបឺតស្រូបស្បៀង ផែនការសកម្មភាពអាហារូបត្ថម្ភលើកទី១ត្រូវបានអនុវត្តក្នុងឆ្នាំ១៩៩៥-១៩៩៦ ហើយកម្មវិធីជាតិអាហារូបត្ថម្ភដែលទទួលបន្ទុកក្នុងការរៀបចំនិងអនុវត្តគោលនយោបាយនិងកម្មវិធី ជាតិអាហារូបត្ថម្ភបាន និងកំពុងដំណើរការនៅក្រោមក្រសួងសុខាភិបាល។ ផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជាលើកទី១ ត្រូវបានអនុវត្តក្នុងឆ្នាំ ១៩៩៨-២០០២ ប៉ុន្តែខ្វះមូលនិធិ ចំណែកឯផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជាជាលើកទី២ត្រូវបានអនុវត្តសម្រាប់ចន្លោះ ឆ្នាំ២០០៣-២០០៧ ។

១៦ គួរកត់សំគាល់ថា ក្នុងចំណោមនេះមានសកម្មភាពជំនួយសង្គ្រោះបន្ទាន់របស់អង្គការ ICRC, WFP, UNICEF និង អង្គការមិនមែនរដ្ឋាភិបាលជាច្រើនទៀត ។ ចាប់តាំងពីទសវត្សឆ្នាំ ១៩៨០មក កម្មវិធីទាំងអស់នេះមានលក្ខណៈជាប្រតិបត្តិការកូនកាត់ ដោយធ្វើការលើផ្នែកអសន្តិសុខស្បៀងធ្ងន់ធ្ងរផង និងការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ជនបទផង ។ ចាប់តាំងពីដើមទសវត្សឆ្នាំ ១៩៩០ មក មានគម្រោងជាច្រើនទៀត រួមមានៈ គម្រោងរបស់អង្គការ UNOPS និង អង្គការ CARERE ដែលប្រតិបត្តិការនៅក្នុងខេត្តនានានៅពាយព្យ ។ គម្រោងគួរឱ្យកត់សំគាល់ មួយទៀតគឺ គម្រោង IRRI របស់ប្រទេសអូស្ត្រាលី នៅកម្ពុជា ដែលធ្វើការពាក់ព័ន្ធនឹងការកែលម្អផលិតកម្មកសិកម្មនិងការអភិវឌ្ឍវិស័យកសិកម្ម ហើយដែលធ្វើការជាដៃគូជាមួយនាយកដ្ឋានក្សេត្រសាស្ត្រនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចាប់តាំងពីពាក់កណ្តាលទសវត្សឆ្នាំ ១៩៨០។

កម្មវិធីទ្រង់ទ្រាយធំជាច្រើនទៀតដែលមានគោលបំណងនិងសកម្មភាពពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ១៩៩៦[១៧] មក។ ទោះបីជាយ៉ាងណាក៏ដោយ កម្មវិធីទាំងនេះខ្វះការគាំទ្រផ្នែកក្របខ័ណ្ឌយុទ្ធសាស្ត្រទូលំទូលាយសម្រាប់អនុវត្ត។ ដូច្នេះ ក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០០៨-២០១២ នេះ នឹងអាចបំពេញកង្វះខាតទាំងនោះបាន។

ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើកទី២ (២០០១-២០០៥) និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (២០០៣-២០០៥) បានលើកឡើងយ៉ាងច្បាស់អំពីបញ្ហាពហុវិស័យនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការបញ្ជ្រាបបញ្ហានេះទៅក្នុងយុទ្ធសាស្ត្រជាតិ និងយុទ្ធសាស្ត្រតាមវិស័យនានា។ គម្រោងជាច្រើនដែលផ្តោតទៅលើការគាំទ្រគោលនយោបាយ ការអភិវឌ្ឍន៍ចំណេះដឹង ការកែលម្អការគ្រប់គ្រងព័ត៌មាន និងការបង្កើតឬពង្រឹងរចនាសម្ព័ន្ធសហប្រតិបត្តិការ[១៨] ត្រូវបានបង្កើតឡើង។ នៅចុងឆ្នាំ២០០៤ ក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភដែលមានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងក្រសួងផែនការជាសហប្រធាន ហើយអង្គការកម្មវិធីស្បៀងអាហារពិភពលោក (WFP) និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) ជាអ្នកសម្របសម្រួលរួម បានចូលរួមនៅក្នុងដំណើរការពិគ្រោះយោបល់ និងរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០០៦-២០១០ ដោយបានរៀបចំ និងផ្តល់ឯកសារពាក់ព័ន្ធនឹងបញ្ហាពហុវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ជូនលេខាធិការដ្ឋានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ឯកសារយុទ្ធសាស្ត្រ[១៩] ដែលជាមូលដ្ឋានសម្រាប់ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភត្រូវបានតាក់តែងឡើងក្នុងឆ្នាំ ២០០៦ ។

---

[១៧] គម្រោងទាំងនេះរួមមានៈ កម្មវិធីអភិវឌ្ឍន៍ជនបទទ្រង់ទ្រាយធំដែលបានបញ្ចូលការកែលម្អ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទៅក្នុងគោលបំណង និងសកម្មភាពរបស់គេ (ឧ. គម្រោងអភិវឌ្ឍន៍ជនបទ PRASAC របស់សហគមន៍អឺរ៉ុបនៅខេត្តតាកែវ និងគម្រោងអភិវឌ្ឍន៍ជនបទទ្រង់ទ្រាយតូចរបស់អង្គការមិនមែនរដ្ឋាភិបាលជាច្រើនទៀត (ឧ. គម្រោងភាពជាដៃគូសម្រាប់ការអភិវឌ្ឍន៍ដែលឧបត្ថម្ភថវិកា ដោយអង្គការ USAID នៅខេត្តឥសាន គម្រោងសន្តិសុខស្បៀងចំរុះរបស់អង្គការ GTZ នៅខេត្តកំពត កម្មវិធី CASD របស់អង្គការ UNICEF ជាដើម)។ ចំពោះគម្រោងមួយចំនួនទៀត សូមមើលឯកសារផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា ២០០៣-២០០៧ ។

[១៨] គម្រោងគាំទ្រគោលនយោបាយ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ របស់អង្គការ GTZ (២០០៣-២០០៥)នៅក្រសួងផែនការ និងគម្រោងកម្មវិធីភាពជាដៃគូរវាងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ និងប្រទេសហូឡង់ (២០០៦-២០០៧) នៅក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

[១៩] ឯកសារយុទ្ធសាស្ត្រ សម្រាប់កែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០។ ក្រុមការងារបច្ចេកទេស សន្តិសុខស្បៀង និងអាហារូបត្ថម្ភ តាមរយៈក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទបានដាក់ជូនលេខាធិការដ្ឋានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នៅឆ្នាំ ២០០៥ ។

## ២. ការវិភាគស្ថានភាពទូទៅនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងបរិស្ថានគោលនយោបាយ

### ២.១. ស្ថានភាពទូទៅនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា: វឌ្ឍនភាព និងនិន្នាការ

### ២.១.១. កង្វះអាហារូបត្ថម្ភ និងមរណភាព

ស្ថានភាពអាហារូបត្ថម្ភ ជាពិសេសសម្រាប់កុមារអាយុក្រោម៥ឆ្នាំ គឺជាសូចនាករស្តែងចេញជារូមសម្រាប់ស្ថានភាពអសន្តិសុខស្បៀងនៅកម្រិតថ្នាក់ជាតិ ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋាន ។

ដោយហេតុថាកុមារដែលមានបញ្ហាកង្វះអាហារូបត្ថម្ភជួបប្រទះនឹងគ្រោះថ្នាក់នៃការឆ្លងជំងឺ ៥៤ភាគរយនៃការស្លាប់មុនអាយុរបស់កុមារកម្ពុជាអាយុក្រោម៥ឆ្នាំជាប់ពាក់ព័ន្ធនឹងកង្វះអាហារូបត្ថម្ភ[២០] ។ បញ្ហាកង្វះអាហារូបត្ថម្ភក៏មានផលប៉ះពាល់អវិជ្ជមានផងដែរទៅលើការលូតលាស់ផ្នែករាងកាយនិងសតិស្មារតី និងការចម្រើនវ័យរបស់កុមារ ហើយដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់សក្តានុពលធនធានមនុស្សរបស់ពួកគាត់ ។

ការអង្កេតប្រជាសាស្ត្រ និងសុខភាពទាំងពីរលើកបានបង្ហាញពីនិន្នាការនានានៃបញ្ហាកង្វះអាហារូបត្ថម្ភរបស់កុមារ (អាយុក្រោម៥ឆ្នាំ) ក្នុងចន្លោះឆ្នាំ ២០០០ និង២០០៥ ។ និន្នាការទាំងនេះរួមមាន: អត្រានៃកង្វះថាមពលប្រូតេអ៊ីន និងកង្វះមីក្រូសារជាតិ ។

អត្រានៃជំងឺក្រិន (កម្ពស់ទាបធៀបនឹងអាយុ) បញ្ជាក់បង្ហាញឱ្យឃើញពីសមមាត្រនៃកុមារដែលមានបញ្ហាកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃរយៈពេលយូរ ។ អត្រាទម្ងន់ស្រាល (ទម្ងន់ទាបធៀបនឹងអាយុ) បញ្ជាក់អំពីសមមាត្រនៃកុមារដែលមានបញ្ហាកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ និងរ៉ាំរ៉ៃ ។ អត្រានៃភាពស្គមស្គាំង (ទម្ងន់ទាបធៀបនឹងកម្ពស់) បញ្ជាក់អំពីសមមាត្រនៃកុមារដែលមានបញ្ហាកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ ។ លទ្ធផលទាំងឡាយនៃបញ្ហាកង្វះអាហារូបត្ថម្ភសម្រាប់ឆ្នាំ២០០០ និង២០០៥ ត្រូវបានបង្ហាញឱ្យឃើញ ដោយធ្វើការប្រៀបធៀបជាមួយនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា សម្រាប់ឆ្នាំ២០១៥ ក្នុងតារាង ១ ខាងក្រោម ។

**តារាង ១: អត្រាកង្វះថាមពលប្រូតេអ៊ីនរបស់កុមារនៅកម្ពុជា ឆ្នាំ ២០០០ និង ២០០៥**

| សូចនាករ | ការអង្កេតប្រជាសាស្ត្រនិងសុខភាព | | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
|---|---|---|---|
| (អាយុក្រោម ៥ ឆ្នាំ) | ២០០០ (%) | ២០០៥ (%) | ២០១៥ (%) |
| កុមារក្រិន | ៤៥ | ៣៧ | ២២ |
| កុមារមានទម្ងន់ស្រាល | ៤៥ | ៣៦ | ២២ |
| កុមារស្គមស្គាំង | ១៥ | ៧ | ៩ |

***ប្រភព:*** *របាយការណ៍ការអង្កេតប្រជាសាស្ត្រនិងសុខភាព ឆ្នាំ ២០០៥ និង របាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ២០០៣*

[២០] របាយការណ៍ឆ្នាំ ២០០៥របស់កម្មវិធីជាតិអាហារូបត្ថម្ភនៃមជ្ឈមណ្ឌលគាំពារមាតានិងទារក, ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក

តារាងនេះបង្ហាញឱ្យឃើញថា នៅក្នុងឆ្នាំ ២០០០ កុមារកម្ពុជាស្ទើរតែពាក់កណ្តាលប្រឈមមុខនឹងកង្វះថាមពលប្រូតេអ៊ីនរ៉ាំរ៉ៃ ឬកង្វះថាមពលប្រូតេអ៊ីនធ្ងន់ធ្ងរ និងរ៉ាំរ៉ៃ ។ នៅឆ្នាំ២០០៥ ស្ថានភាពបានល្អប្រសើរគួរឱ្យកត់សំគាល់ គឺថា អត្រានៃកុមារដែលប្រឈមមុខនឹងកង្វះអាហារូបត្ថម្ភមានការថយចុះជាងពាក់កណ្តាល ។ ទោះបីជាយ៉ាងណាក៏ដោយ យើងគួរតែកត់សម្គាល់ថា អត្រាក្រិនតែងតែមានការប្រែប្រួល និងផ្លាស់ប្តូរទៅតាមស្ថានភាពអាហារូបត្ថម្ភរបស់កុមារ។ ជាទូទៅ លទ្ធផលនេះបង្ហាញឱ្យឃើញពីវឌ្ឍនភាពយ៉ាងសំខាន់ក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាសម្រាប់ឆ្នាំ ២០១៥ ។

តារាង២ បង្ហាញឱ្យឃើញពីអត្រាខ្ពស់នៃកង្វះមីក្រូសារជាតិ។ ទោះបីជាយ៉ាងនេះក្តី ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានការរីកចម្រើននិងភាពល្អប្រសើយ៉ាងខ្លាំងក្នុងការប្រើប្រាស់អំបិលអ៊ីយ៉ូដ ហើយក៏មានភាពល្អប្រសើរគួរសមក្នុងការផ្តល់គ្រាប់ថ្នាំជីវជាតិអា។ ក៏ប៉ុន្តែ ក្នុងចំណោមកុមារកម្ពុជាដែលមានអាយុពី ៦ដល់៥៩ខែ មានកុមារ៦២ភាគរយនៅតែប្រឈមមុខនឹងបញ្ហាស្លេកស្លាំង (២៩ភាគរយមានកម្រិតស្រាល ៣២ភាគរយមានកម្រិតធ្ងន់គួរសម និង១ភាគរយមានកម្រិតធ្ងន់ធ្ងរ) ។ អត្រាបញ្ហាស្លេកស្លាំងដោយសារកង្វះជាតិដែកនៅតែមានកម្រិតស្មើនឹងឆ្នាំ២០០០ ដដែល ហើយអត្រាបច្ចុប្បន្ននេះបង្ហាញឱ្យឃើញអំពីបញ្ហាសុខភាពសាធារណៈយ៉ាងធ្ងន់ធ្ងរនៅក្នុងប្រទេសកម្ពុជា ។

**តារាង ២: អត្រាកង្វះមីក្រូសារជាតិរបស់កុមារនៅកម្ពុជា ឆ្នាំ ២០០០ និង២០០៥**

| **សូចនាករ** | **ការអង្កេតប្រជាសាស្ត្រនិងសុខភាព** | | **គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា** |
|---|---|---|---|
| | **២០០០ (%)** | **២០០៥ (%)** | **២០១៥ (%)** |
| បញ្ហាស្លេកស្លាំងដោយសារកង្វះជាតិដែកនៃកុមារ អាយុ ពី ៦-៥៩ ខែ | ៦៣ | ៦២ | - |
| កុមារ អាយុ ពី ៦-៥៩ ខែ ដែលបានទទួលគ្រាប់ថ្នាំ ជីវជាតិអា | ២៨ | ៣៥ | ៩០ |
| ក្រុមគ្រួសារដែលប្រើប្រាស់អំបិលអ៊ីយ៉ូដ | ១២ | ៧៣ | ៩០ |

***ប្រភព :*** *របាយការណ៍ការអង្កេតប្រជាសាស្ត្រនិងសុខភាព ឆ្នាំ ២០០៥ និង របាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ២០០៣*

.ទន្ទឹមនឹងនេះ ការអង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០០៥បានបង្ហាញឱ្យឃើញពីការរីកចម្រើន និងភាពល្អប្រសើរយ៉ាងជាក់ច្បាស់អំពីការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់រហូតដល់ទារកមានអាយុ៦ខែ ។ អត្រាបំបៅកូនដោយទឹកដោះម្តាយតែមួយមុខបានកើនឡើងពី ៥ភាគរយនៅឆ្នាំ២០០០ ទៅ៣១ភាគរយ នៅឆ្នាំ២០០៥[២១] ។

---

[២១] នៅក្នុងរបាយការណ៍នៃការអង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ ២០០៥ បានបញ្ជាក់ថា អត្រានៃការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខមានចំនួន ៦០ភាគរយ ។ ក៏ប៉ុន្តែ ក្រោយមកតួលេខនេះត្រូវបានកែតម្រូវឡើងវិញដោយកម្មវិធីអាហារូបត្ថម្ភជាតិនៃក្រសួងសុខាភិបាល (សូមមើលយុទ្ធសាស្ត្រជាតិអាហារូបត្ថម្ភ ២០០៨-២០១៥) ។

តារាង៣ ខាងក្រោមបង្ហាញឱ្យឃើញពីវឌ្ឍនភាពយ៉ាងសំខាន់ក្នុងការកាត់បន្ថយមរណភាពរបស់ទារក និងកុមារអាយុក្រោម៥ឆ្នាំ។ អត្រាមរណភាពរបស់ទារក និងកុមារអាយុក្រោម៥ឆ្នាំបានធ្លាក់ចុះមកត្រឹម ៣០ភាគរយ ក្នុងចន្លោះ ឆ្នាំ២០០០ និង២០០៥ ។ ថ្វីបើទទួលបានសមិទ្ធផលដ៏ត្រចះត្រចង់យ៉ាងនេះក្តី ក៏ប៉ុន្តែ នៅក្នុងឆ្នាំ២០០៥ នេះ មានកុមារកម្ពុជាម្នាក់ក្នុងចំណោម១២ ស្លាប់មុនអាយុ ៥ឆ្នាំ ។

**តារាង ៣: អត្រាមរណភាពរបស់ទារកនិងកុមារអាយុក្រោម ៥ ឆ្នាំ នៅកម្ពុជា ឆ្នាំ ២០០០ និង ២០០៥**

| សូចនាករ | ការអង្កេតប្រជាសាស្ត្រនិងសុខភាព | | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
|---|---|---|---|
| | ២០០០ (%) | ២០០៥ (%) | ២០១៥ (%) |
| អត្រាមរណភាពរបស់ទារក (ក្នុង១០០០ នាក់ ចាប់តាំងពីពេលកើតរហូតដល់អាយុ ១១ ខែ) | ៩៥ | ៦៦ | ៥០ |
| អត្រាមរណភាពរបស់ទារកនិងកុមារអាយុក្រោម៥ឆ្នាំ (ក្នុង១០០០ នាក់ ចាប់តាំងពីពេលកើតរហូតដល់អាយុ៥៩ខែ) | ១២៤ | ៨៣ | ៦៥ |

***ប្រភព :*** *របាយការណ៍ការអង្កេតប្រជាសាស្ត្រនិងសុខភាព ឆ្នាំ ២០០៥ និង របាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ២០០៣*

បើប្រៀបធៀបជាមួយប្រទេសជិតខាង អត្រាកង្វះអាហារូបត្ថម្ភ និងមរណភាពរបស់កុមារនៅកម្ពុជាក្នុងឆ្នាំ២០០៥ នៅតែមានកម្រិតខ្ពស់ជាងប្រទេសជិតខាងរបស់ខ្លួន លើកលែងតែប្រទេសឡាវ និងភូមា ដូចដែលបានបង្ហាញឱ្យឃើញនៅក្នុងតារាង ៤ ខាងក្រោម។

**តារាង ៤: ការប្រៀបធៀបអត្រាមរណភាពរបស់កុមារ នៅកម្ពុជា ឆ្នាំ ២០០៥ ជាមួយប្រទេសជិតខាងក្នុងតំបន់**

| ប្រទេស | អត្រាក្រិន | អត្រាទម្ងន់ស្រាល | អត្រាស្គមស្គាំង | អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ |
|---|---|---|---|---|
| ***កម្ពុជា ឆ្នាំ ២០០៥*** | ***៣៧*** | ***៣៦*** | ***៧*** | ***៨៣*** |
| *ចិន* | *១៤* | *៨* | - | *៣១* |
| ឥណ្ឌូនេស៊ី | - | *២៨* | - | *៣៨* |
| ឡាវ | *៤២* | *៤០* | *១៥* | *៨៣* |
| ម៉ាឡេស៊ី | - | *១១* | - | *១២* |
| ភូមា | - | - | - | *១០៦* |
| ហ្វីលីពីន | *៣០* | *២៨* | *៦* | *៣៤* |
| សិង្ហបុរី | *១១* | *១៤* | *៤* | *៣* |
| ថៃ | *១៦* | *១៩* | *៦* | *២១* |
| វៀតណាម | *៣២* | *២៨* | *៧* | *២៣* |

***ប្រភព :*** *របាយការណ៍ស្តីពីស្ថានភាពកុមារពិភពលោក ឆ្នាំ ២០០៦ របស់អង្គការ UNICEF ។ អត្រាសម្រាប់ប្រទេសដទៃក្រៅពីកម្ពុជាគឺជាអត្រាដែលមានចុងក្រោយបង្អស់ នៅក្នុងកំឡុងឆ្នាំ ១៩៩៨-២០០៤ ។*

សមាសធាតុនៃស្ថានភាព សន្តិសុខស្បៀង និងអាហារូបត្ថម្ភ មួយទៀតនៅកម្ពុជា គឺការសិក្សារកឱ្យឃើញអំពីចំនួនពិតប្រាកដនៃកុមារកម្ពុជាដែលកំពុងតែទទួលរងផលប៉ះពាល់ដោយសារតែកង្វះអាហារូបត្ថម្ភ និងមរណ-

ភាព ។ ចំនួនសរុបនៃកុមារមានអាយុក្រោម៥ឆ្នាំ នៅកម្ពុជា នៅក្នុងឆ្នាំ២០០៥ ត្រូវបានប៉ាន់ស្មាន ថាមានចំនួន តិចជាង១,៧លាននាក់[២២] ។ តារាង១ (ក្នុងតួលេខពិត) ពន្យល់បង្ហាញយ៉ាងច្បាស់អំពីវឌ្ឍនភាព ក៏ប៉ុន្តែបានគូស បញ្ជាក់ទំហំនៃបញ្ហាដូចដែលបានបង្ហាញនៅក្នុងតារាង ៥ ខាងក្រោម ។

**តារាង ៥: ចំនួនប៉ាន់ស្មាននៃកុមារទទួលផលប៉ះពាល់ ដោយសារកង្វះអាហារូបត្ថម្ភ និងមរណភាពនៅកម្ពុជា ឆ្នាំ ២០០០ និង២០០៥**

| សូចនាករ | ចំនួនប៉ាន់ស្មាននៃកុមារទទួលផលប៉ះពាល់ ក្នុងឆ្នាំ ២០០០ | ចំនួនប៉ាន់ស្មាននៃកុមារទទួលផលប៉ះពាល់ ក្នុងឆ្នាំ ២០០៥ |
|---|---|---|
| កុមារក្រិន (% អាយុក្រោម៥ឆ្នាំ) | ៧៦១.៥៩១ | ៦៣១.០០០ |
| កុមារមានទម្ងន់ស្រាល (% អាយុក្រោម៥ឆ្នាំ) | ៧៧៥.៨១៥ | ៦០៣.០០០ |
| កុមារស្គមស្គាំង(% អាយុក្រោម៥ឆ្នាំ) | ២៦២.៧៥៦ | ១២៤.០០០ |
| មរណភាពក្រោមអាយុ៥ឆ្នាំ (ក្នុង១០០០ នាក់ ចាប់តាំងពីពេលកើតរហូតដល់អាយុ៥៩ខែ) | ២០៨.១៥៤ (ក្នុងរយៈពេល៥ឆ្នាំ) | ១៨៥.០០០ (ក្នុងរយៈពេល៥ឆ្នាំ) |

***ប្រភព*** *: របាយការណ៍ការអង្កេតប្រជាសាស្ត្រនិងសុខភាព ឆ្នាំ២០០៥ ។ ចំនួនប៉ាន់ស្មាននេះបានមកពីកម្រងផែនទីសន្តិសុខស្បៀង របស់អង្គការកម្មវិធីស្បៀងអាហារពិភពលោក ឆ្នាំ ២០០៦ ដោយផ្អែកលើ របាយការណ៍ការអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ ២០០៥ និងវិទ្យាស្ថានជាតិស្ថិតិឆ្នាំ ២០០៤ (ចំនួនកុមារអាយុក្រោម ៥ឆ្នាំ សរុប នៅឆ្នាំ ២០០៥ = ១.៦៩៤.៩៥០ នាក់)*

ចរិកលក្ខណៈសំខាន់មួយទៀតនៃអត្រាកង្វះអាហារូបត្ថម្ភនិងមរណភាពរបស់កុមារនៅកម្ពុជា គឺថា វាមានការប្រែប្រួលយ៉ាងខ្លាំងទៅតាមតំបន់ភូមិសាស្ត្រ និងក្រុមសង្គមនៅក្នុងប្រទេសកម្ពុជា ។ បម្រែបម្រួលនេះគូសបញ្ជាក់អំពីតម្រូវការជាចាំបាច់ក្នុងការកំណត់អត្តសញ្ញាណនិងកំណត់គោលដៅក្រុមគ្រួសារអសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភតាមតំបន់ និងក្រុមសង្គម ដើម្បីផ្តល់ជំនួយប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត ។ បម្រែបម្រួលតាមភូមិសាស្ត្រខេត្តនីមួយៗ ត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងផែនទីដែលមានភ្ជាប់មកជាមួយនៅក្នុងឧបសម្ព័ន្ធទី២[២៣] ។ ជាឧទាហរណ៍ អត្រាក្រិននៃកុមារអាយុក្រោម៥ឆ្នាំ នៅឆ្នាំ ២០០៥ នៅកម្រិតថ្នាក់ជាតិ មាន៣៧ភាគរយ ប៉ុន្តែនៅក្រុងភ្នំពេញមាន២២ភាគរយ នៅខេត្តពោធិសាត់មាន៦២ភាគរយ ហើយនៅសៀមរាប និងនៅមណ្ឌលគិរី ឬរតនគិរីមាន៥៣ភាគរយ ។ លើសពីនេះទៅទៀត នៅកម្រិតថ្នាក់ឃុំ អត្រាក្រិននៃកុមារអាយុក្រោម៥ឆ្នាំ មានការប្រែប្រួលគ្រប់ឃុំទាំងអស់នៅតាមខេត្តនីមួយៗ ។ នៅឆ្នាំ២០០០ នៅកម្រិតថ្នាក់ឃុំ អត្រាក្រិននៃកុមារអាយុក្រោម៥ឆ្នាំមាន ការប្រែប្រួលពី១៧ភាគរយ ទៅ៧៥ភាគរយ ។

---

២២ ការសិក្សាឡើងវិញ អំពីការឆ្លុះបញ្ចាំងអំពីចំនួនប្រជាពលរដ្ឋកម្ពុជា ១៩៩៨-២០២០ ដោយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ឆ្នាំ ២០០៤

២៣ បម្រែបម្រួលតាមតំបន់នៃអត្រាកង្វះអាហារូបត្ថម្ភ សម្រាប់ខេត្ត-ក្រុងទាំងអស់អាចស្វែងយល់តាមរយៈគេហទំព័រកម្រងផែនទីសន្តិសុខស្បៀងនៅកម្ពុជា និងតាមរយៈការធ្វើភាគចំណាត់ថ្នាក់សម្រាប់សន្តិសុខស្បៀងនិងជំនួយមនុស្សធម៌នៅកម្ពុជា (IPC) របស់អង្គការកម្មវិធីស្បៀងអាហារពិភពលោកដែលបាន ដាក់បញ្ចូលទៅក្នុងវិបសាយ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ (http://www.foodsecurity.gov.kh) ។ ការប៉ាន់ស្មាននៅថ្នាក់ ឃុំ-សង្កាត់ នៅឆ្នាំ ២០០០ ផ្អែកទៅលើការប៉ាន់ស្មានភាពក្រីក្រនៅថ្នាក់ឃុំ-សង្កាត់ របស់ អង្គការ WFP និង Tomoko Fuji ឆ្នាំ ២០០៣ ។

ចំនួនពិតនៃកុមារដែលរងផលប៉ះពាល់ដោយសារភាពក្រិនក៏មានការប្រែប្រួលយ៉ាងខ្លាំងផងដែរដោយសារតែដង់ស៊ីតេប្រជាពលរដ្ឋខុសៗគ្នា (ចាប់ពីតិចជាង ២.០០០នាក់ នៅក្នុងក្រុងកែប និងក្រុងប៉ៃលិន ទៅច្រើនជាង ៦០.០០០នាក់ នៅខេត្តសៀមរាប និងខេត្តកំពង់ចាម) ។

អត្រាកង្វះអាហារូបត្ថម្ភរបស់កុមារមានបម្រែបម្រួលយ៉ាងខ្លាំងស្រដៀងគ្នានេះដែរ ក្នុងចំណោមក្រុមសេដ្ឋកិច្ច-សង្គមនៅកម្ពុជា។ អត្រាក្រិននៃកុមារអាយុក្រោម៥ឆ្នាំ នៅឆ្នាំ២០០៥ មានការប្រែប្រួលពី២២ភាគរយក្នុងចំណោមកុមារដែលមាតារបស់គេមានកម្រិតអប់រំយ៉ាងទាបត្រឹមមធ្យមសិក្សា ទៅ៤៦ភាគរយសម្រាប់កុមារដែលមាតារបស់គេពុំមានការអប់រំ។ អត្រាមរណភាពរបស់កុមារអាយុក្រោម៥ឆ្នាំ ក៏ប្រែប្រួលចាប់ពី៥៣នាក់ (ក្នុង ១០០០នាក់) សម្រាប់កុមារដែលមាតារបស់គេមានកម្រិតអប់រំយ៉ាងទាបត្រឹមមធ្យមសិក្សា ទៅ១៣៦នាក់ សម្រាប់កុមារដែលមាតារបស់គេពុំមានការអប់រំ ។ បើនិយាយអំពីភាពខុសគ្នាខាងទ្រព្យធន កុមារដែលមានមាតាស្ថិតក្នុង**ត្រីមាស**ទ្រព្យធនទាបបំផុតប្រឈមមុខនឹងហានិភ័យនៃមរណភាពមុនអាយុ៥ឆ្នាំ បីដងខ្ពស់ជាងកុមារដែលមានមាតាស្ថិតក្នុង**ត្រីមាស**ទ្រព្យធនខ្ពស់បំផុត[២៤] ។ ទៅទៀតជាងនេះទៅទៀត ការសិក្សាផ្នែកសេដ្ឋកិច្ច-សង្គមជាច្រើនទៀតបានបញ្ជាក់ឱ្យឃើញថា ក្រុមសេដ្ឋកិច្ច-សង្គមមួយចំនួនមានកម្រិតអសន្តិសុខស្បៀង និងភាពងាយរងគ្រោះខ្ពស់។ ក្រុមសង្គមទាំងនេះរួមមានៈ ស្ត្រី កសិករតូចតាចដែលប្រកបរបរចិញ្ចឹមជីវិតពឹងផ្អែកលើធនធានធម្មជាតិរួម និងក្រុមជនងាយរងគ្រោះក្នុងសង្គម[២៥] ។

ក្នុងពេលថ្មីៗនេះ មានការវាយតម្លៃយ៉ាងសំខាន់មួយអំពីអសន្តិសុខស្បៀងនៅកម្ពុជាដោយផ្អែកលើការវិភាគថ្មីនៃទិន្នន័យការបរិភោគស្បៀងដែលបានមកពីការអង្កេតប្រជាសាស្ត្រនិងសុខភាព ឆ្នាំ២០០៤[២៦] ។ នៅទូទាំងប្រទេស នៅក្នុងឆ្នាំ២០០៣-២០០៤ ប្រជាពលរដ្ឋ២៣ភាគរយ ឬប្រមាណ ៣លាន នាក់ មានស្បៀងបរិភោគមិនគ្រប់គ្រាន់ គឺថា ពួកគាត់បរិភោគបានតិចជាងតម្រូវការថាមពលអាហារអប្បបរមា ១៧១៥ គីឡូកាឡូរីក្នុងម្នាក់ក្នុងមួយថ្ងៃ[២៧] ក៏ប៉ុន្តែ ៦៩ភាគរយនៃប្រជាពលរដ្ឋស្ថិតក្នុង**ត្រីមាស**ទ្រព្យធនទាបបំផុត ត្រូវបានគិតថាមានស្បៀងបរិភោគមិនគ្រប់គ្រាន់ ។ ប្រជាពលរដ្ឋដែលមានស្បៀងបរិភោគមិនគ្រប់គ្រាន់ចាំបាច់គួរតែបង្កើនការបរិភោគឱ្យបាន ២៨០កាឡូរីក្នុងម្នាក់ក្នុងមួយថ្ងៃ បន្ថែមទៀត ដើម្បីទទួលបានកម្រិតមធ្យមនៃតម្រូវការថាមពលរបបអាហារ ។

នៅប្រទេសកម្ពុជា មានតែប្រជាពលរដ្ឋស្ថិតក្នុងត្រីមាសទី៥ (មានទ្រព្យធនច្រើនជាងគេបំផុត)ទេ ដែលបរិភោគអាហារមានតុល្យភាព គឺមានសមមាត្រនៃជាតិប្រូតេអ៊ីន ជាតិខ្លាញ់ និងសារជាតិកាបូហៃដ្រាតគ្រប់គ្រាន់ទៅតាមគោលការណ៍ណែនាំរបស់អង្គការសុខភាពពិភពលោក និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ។

---

[២៤] ការអង្កេតប្រជាសាស្ត្រនិងសុខភាព ឆ្នាំ ២០០៥

[២៥] ក្រុមសេដ្ឋកិច្ច-សង្គមទាំងនេះត្រូវបានពិភាក្សាពិស្តារបន្ថែមទៀតនៅក្នុងផ្នែកទី ៤ នៃការវិភាគស្ថានភាពតាមវិស័យ ក្នុងឯកសារនេះ

[២៦] របាយការណ៍សង្ខេបស្តីពីការវាយតម្លៃអសន្តិសុខស្បៀងនៅកម្ពុជា ដោយវិទ្យាស្ថានជាតិស្ថិតិ សហការជាមួយអង្គការ FAO និង EU ឆ្នាំ ២០០៧

[២៧] តម្រូវការថាមពលប្រចាំថ្ងៃអប្បបរមា ត្រូវបានកំណត់និយមន័យថាជាតម្រូវការថមពលនៃរបបអាហារប្រចាំថ្ងៃដើម្បីទ្រទ្រង់រាងកាយឱ្យបានមាំមួនដោយមានការធ្វើសកម្មភាពបន្ទាប់បន្សំផ្សេងៗទៀត ។

ចំណែកឯប្រជាពលរដ្ឋប្រមាណ៨០ភាគរយទៀតមិនមានគុណភាពខាងរបបអាហារទេ  គឺថាពួកគាត់បរិភោគអាហារមានជាតិខ្លាញ់និងប្រូតេអ៊ីនទាប តែមានសារជាតិកាបូហៃដ្រាតខ្ពស់ដែលសារជាតិកាបូហៃដ្រាតនេះមានប្រភពមកពីធញ្ញជាតិ ជាពិសេសអង្ករ ។

### ២.១.២. ទិដ្ឋភាពទូទៅនៃមូលហេតុបណ្តាលឱ្យមានអសន្តិសុខស្បៀង

កង្វះអាហារូបត្ថម្ភ និងអសន្តិសុខស្បៀងគឺបណ្តាលមកពីអន្តរសកម្មដ៏សាំញ៉ាំនៃកត្តាជាច្រើន។ គោលគំនិតនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភបង្ហាញឱ្យបានស្គាល់អំពីសមាសធាតុសាមញ្ញនៃអសន្តិសុខស្បៀងចំនួន៤ (ភាពមានស្បៀង ភាពទទួលបានស្បៀង ការប្រើប្រាស់និងបឺតស្រូបស្បៀង និងស្ថេរភាពស្បៀង) ដើម្បីជួយដោះស្រាយភាពសាំញ៉ាំនេះ[២៨]។ សមាសធាតុសាមញ្ញនៃអសន្តិសុខស្បៀងទាំង៤នេះ ត្រូវបានអត្ថាធិប្បាយបន្ថែមទៀតនៅក្នុងតារាង ៦ ក្នុងទំព័របន្ទាប់ ។

**រូបភាព ១:** គោលគំនិតនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ




---

[២៨] សូមមើលឯកសាររៀបរៀងដោយ  Rainer Gross, Hans Schoeneberger, Hans Pfeifer, Hans-Joachim A. Preuss និង សមាសធាតុទាំងបួននៃ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ: និយមន័យនិងគោលគំនិត ឯកសាររបស់ អង្គការ GTZ នៅឆ្នាំ ២០០០ ដែលមាននៅក្នុង វិបសាយសន្តិសុខស្បៀង និងអាហារូបត្ថម្ភ របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ (www.foodsecurity.gov.kh)

## តារាង ៦: សមាសធាតុសាមញ្ញៗ នៃអសន្តិសុខស្បៀង

**សមាសធាតុសាមញ្ញៗ នៃអសន្តិសុខស្បៀង**

**១. ភាពមានស្បៀង:**

ប្រជាពលរដ្ឋខ្វះខាតលទ្ធភាពក្នុងការផលិតស្បៀងដោយផ្ទាល់ឱ្យបានគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការអាហារូបត្ថម្ភ តាមរយៈការខិតខំប្រឹងប្រែងផ្ទាល់ខ្លួនក្នុងផលិតកម្មកសិកម្ម និងបសុសត្វ និងតាមរយៈការប្រមូលធនធានធម្មជាតិ រួមមាន: ធនធានជលផល និងអនុផលព្រៃឈើ ។

**២. ភាពទទួលបានស្បៀង:**

ប្រជាពលរដ្ឋមិនមានប្រាក់ចំណូលគ្រប់គ្រាន់ក្នុងការទិញស្បៀងពីទីផ្សារឱ្យបានគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការ ។ ចំណែកឯទីផ្សារវិញអាចខ្វះខាតហេដ្ឋារចនាសម្ព័ន្ធ សេវាកម្ម និងមូលធនសម្រាប់ទិញស្បៀងស្តុកទុកឱ្យបានគ្រប់គ្រាន់ ដើម្បី ឆ្លើយតបនឹងតម្រូវការស្បៀងអប្បបរមាអប្បបរមា ។ ជាងនេះទៅទៀត ពុំមានបណ្តាញជំនួយសង្គ្រោះ ឬបណ្តាញសុវត្ថិភាពសង្គមគ្រប់គ្រាន់សម្រាប់ ប្រជាពលរដ្ឋដែលមិនមានលទ្ធភាពផលិត ឬ ទិញស្បៀងសម្រាប់បំពេញតម្រូវការ ។

**៣. ការប្រើប្រាស់ និងការបឺតស្រូបស្បៀង:**

ប្រជាពលរដ្ឋអាចប្រឈមមុខនឹងបញ្ហាក្នុងការប្រើប្រាស់និងបឺតស្រូបស្បៀងដើម្បីទទួលបានអាហារូបត្ថម្ភគ្រប់គ្រាន់ ។ស្ត្រីមានផ្ទៃពោះឬកំពុងបំបៅកូន ខ្លួនឯងមានបញ្ហាកង្វះអាហារូបត្ថម្ភ ដែលជាហេតុធ្វើឱ្យទារកមិនអាចទទួលបានអាហារូបត្ថម្ភគ្រប់គ្រាន់ ។ ការគាំពារមាតា និងទារកអាចមិនមានលក្ខណៈសមស្របសម្រាប់សុខភាព និងអាហារូបត្ថម្ភរបស់កុមារ ។ អត្រាខ្ពស់នៃការឆ្លងជំងឺ ដូចជា: ជំងឺរាគរូស និងកង្វះសេវាសុខភាពមាតានិងទារកមានចំណែកយ៉ាងធំក្នុងការកាត់បន្ថយអាហារូបត្ថម្ភ និងសុខភាពមាតា និងទារក ។ ចំណែកឯកង្វះទឹកស្អាត និងអនាម័យជាមូលហេតុបណ្តាលឱ្យអត្រាឆ្លងជំងឺមានការកើនឡើង ហើយអាហារូបត្ថម្ភ និងសុខភាពមានការថយចុះ ។

**៤. ស្ថេរភាពស្បៀង:**

ប្រជាពលរដ្ឋត្រូវការឱ្យមានការផ្គត់ផ្គង់ស្បៀងអាហារដែលមានជីវជាតិ និង ទឹកស្អាតគ្រប់គ្រាន់ប្រចាំថ្ងៃ ដើម្បីទទួលបានអាហារូបត្ថម្ភ និងសន្តិសុខស្បៀងគ្រប់គ្រាន់ ។ អស្ថេរភាពក្នុងការផ្គត់ផ្គង់ស្បៀងអាហារ និង ទឹកស្អាតគ្រប់គ្រាន់ជាប្រចាំជាមូលហេតុបណ្តាលឱ្យមានបញ្ហាកង្វះអាហារូបត្ថម្ភ និងអសន្តិសុខស្បៀង ។ មូលហេតុនៃអស្ថេរភាពអាចបណ្តាលមកពីទឹកជំនន់ និងគ្រោះរាំងស្ងួតដែលប៉ះពាល់ដល់កសិកម្ម ការបំផ្លាញបរិស្ថាន បម្រែបម្រួលក្នុងការទទួលផលពីធនធានធម្មជាតិ និងបម្រែបម្រួលខាងលទ្ធភាពទិញស្បៀងពីទីផ្សារ ហើយអស្ថេរភាពនយោបាយរួមមាន: សង្គ្រាម និងជម្លោះផ្សេងៗ ។ សហគមន៍មួយចំនួនប្រហែលជាធ្លាប់ឆ្លងកាត់ដោយផ្ទាល់នូវអស្ថេរភាពយ៉ាងខ្លាំងក្នុងពេលណាមួយ ហើយសហគមន៍មួយចំនួនធំអាចងាយរងគ្រោះដោយសារតែឥទ្ធិពលនៃអស្ថេរភាពក្នុងពេលអនាគត ។

ផ្នែកនេះបង្ហាញពីទិដ្ឋភាពទូទៅនៃសមាសធាតុសាមញ្ញនៃសន្តិសុខស្បៀងនៅប្រទេសកម្ពុជា ។ ការអត្ថាធិប្បាយពិស្តារអំពីសមាសធាតុទាំងនេះមាននៅក្នុងផ្នែកវិភាគស្ថានភាពតាមវិស័យនីមួយៗ ដាច់ដោយឡែកៗសម្រាប់គោលបំណងសន្តិសុខស្បៀង និងអាហារូបត្ថម្ភទាំងអស់ ដែលមានរៀបរាប់នៅក្នុងផ្នែកទី៤ ខាងក្រោម ។

### ភាពមានស្បៀង :

ប្រជាពលរដ្ឋប្រមាណជាង៨០ភាគរយរស់នៅតាមតំបន់ជនបទ ហើយតាមធម្មតា ពួកគាត់ផលិតស្បៀងអាហារមួយផ្នែកធំសម្រាប់បំពេញតម្រូវការប្រចាំថ្ងៃ ។ សមិទ្ធផលសំខាន់ៗក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះបានបង្ហាឱ្យឃើញថាប្រទេសកម្ពុជាមានសមត្ថភាពផលិតស្រូវគ្រប់គ្រាន់ដោយខ្លួនឯងដើម្បីបំពេញតម្រូវការស្បៀង

អប្បបរមាសម្រាប់ប្រជាពលរដ្ឋទាំងអស់[២៩] ។ ទោះបីជាយ៉ាងនេះក្តី នៅថ្នាក់មូលដ្ឋាននៅតែមិនទាន់មានតុល្យភាពស្បៀង (ខ្វះស្បៀង) គឺអាស្រ័យទៅតាមតំបន់ភូមិសាស្ត្រ និងក្រុមសេដ្ឋកិច្ច-សង្គម ។ ទិន្នផលស្រូវជាមធ្យមកើនពី ១,៣១ ត/ហ.ត នៅឆ្នាំ១៩៩៣ ទៅ ២,៦២១ ត/ហ.ត នៅឆ្នាំ ២០០៧-២០០៨ ក៏ប៉ុន្តែទិន្នផលនេះនៅតែទាបជាងទិន្នផលស្រូវដែលប្រទេសជិតខាងទទួលបាន[៣០] ។ នៅតំបន់ខ្លះ និងក្រុមសេដ្ឋកិច្ច-សង្គមនៅតាមជនបទមួយចំនួន ផលិតស្រូវគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការ ឬថែមទាំងអាចផលិតបានសល់សម្រាប់ទុកលក់ទៀតផង រីឯនៅតំបន់និងក្រុមសេដ្ឋកិច្ច-សង្គមខ្លះទៀតមិនអាចផលិតស្រូវបានគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការស្បៀងអប្បបរមាទេ ។ បើនិយាយពីផលិតកម្មស្បៀងផ្សេងៗទៀតក្រៅពីស្រូវសម្រាប់បំពេញរបបអាហារឱ្យបានគ្រប់គ្រាន់ នៅពុំមានតួរលេខណាមួយបង្ហាញអំពីតុល្យភាពស្បៀងនៅកម្រិតថ្នាក់ជាតិទេ ក៏ប៉ុន្តែនៅមានបម្រែបម្រួលយ៉ាងខ្លាំងក្នុងការបរិភោគស្បៀងអាហារផ្សេងៗក្រៅពីស្រូវ ដូចដែលបានបញ្ជាក់ឱ្យឃើញតាមរយៈអត្រាប្រែប្រួលនៃកង្វះថាមពលប្រូតេអ៊ីន និងកង្វះមីក្រូសារជាតិ នៅក្នុងផ្នែក ២.១ ។

បច្ចុប្បន្ននេះ យើងទទួលស្គាល់ថា ប្រជាពលរដ្ឋកម្ពុជានៅតាមទីជនបទ ជាពិសេសកសិករតូចតាច និងគ្មានដីធ្លីកំពុងប្រឈមមុខនឹងឧបសគ្គជាច្រើនក្នុងការខិតខំប្រឹងប្រែងផលិតស្បៀង តាមរយៈការដាំដំណាំកសិកម្ម ការចិញ្ចឹមសត្វ និងការប្រមូលអនុផលព្រៃឈើ និងជលផល ។ ប្រជាពលរដ្ឋតាមទីជនបទ ជាពិសេស កសិករតូចតាចខ្វះខាតធនធានក្នុងការផលិតស្បៀង ហើយពួកគាត់តែងតែទទួលបានផលិតភាពទាបនិងជួបប្រទះហានិភ័យផលិតកម្មខ្ពស់ ។ បើនិយាយអំពីការដាំដំណាំកសិកម្ម មានឧបសគ្គចម្បងៗជាច្រើន រួមមានៈ ផ្ទៃដីដាំដុះតូច ការពឹងផ្អែកខ្លាំងពេកទៅលើទឹកភ្លៀង អត្រានៃអ្នកអត់ដីធ្លីចេះតែកើនឡើង ទិន្នផលទាប ហានិភ័យផលិតកម្មខ្ពស់ និងកង្វះខាតខាងផ្នែកពិពិធកម្មដំណាំ ។ ការចិញ្ចឹមសត្វក៏មានឧបសគ្គផងដែរ ដោយសារតែអត្រាស្លាប់និងអត្រាមានជំងឺរបស់សត្វមានកម្រិតខ្ពស់ ហើយការសត្វចិញ្ចឹមតាមគ្រួសារនីមួយៗមានចំនួនតិច[៣១] ។

ធនធានធម្មជាតិរួម ដូចជាៈ ព្រៃឈើ ជលផល និងតំបន់កសិកម្ម ក៏ជាប្រភពស្បៀងអាហារដ៏សំខាន់ផងដែរសម្រាប់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសប្រជាពលរដ្ឋក្រីក្រនៅតាមជនបទ[៣២] ។ ចំណែកឯការផលិតស្បៀងតាមរយៈការប្រមូលធនធានធម្មជាតិរួមក៏មានកម្រិតផងដែរ ដោយសារកត្តាជាច្រើន រួមមានៈ ការបំផ្លាញធនធានធម្មជាតិដោយសារការធ្វើអាជីវកម្មលក្ខណៈឧស្សាហកម្ម ការទន្ទ្រានកាន់កាប់ដើម្បីផលប្រយោជន៍ឯកជន ដែលជាឧបសគ្គ

---

[២៩] ចាប់តាំងពីឆ្នាំ ១៩៩៧រហូតមកដល់ឆ្នាំ ២០០៦ ប្រទេសកម្ពុជាមាននៅសល់អង្ករ រវាងពី ៣០.០៧០ តោន (នៅឆ្នាំ ១៩៩៨) ទៅ ១.៤៣៣.៨៨០ តោន (នៅឆ្នំ ២០០៦) ដែលគិតជាមធ្យមសល់អង្ករប្រមាណ ៤៨៦.២២៤តោន/ឆ្នាំ ។ ស្ថិតិកសិកម្ម ឆ្នាំ ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

[៣០] ស្ថិតិកសិកម្ម ឆ្នាំ ២០០៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

[៣១] របាយការណ៍វិភាគវិស័យកសិកម្មកម្ពុជា រៀបចំសម្រាប់អង្គការ AusAID ដោយក្រុមហ៊ុន Agrifood Consulting International/ CamConsult ឆ្នាំ ២០០៦. ស្ថិតិកសិកម្ម ឆ្នាំ ២០០៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ. កាត់បន្ថយអត្រាភាពក្រីក្រឱ្យបានពាក់កណ្តាល ត្រឹមឆ្នាំ ២០១៥ៈ ការវាយតម្លៃលើភាពក្រីក្រនៅកម្ពុជា ដោយធនាគារពិភពលោក ឆ្នាំ ២០០៦ និងការអង្កេតសេដ្ឋកិច្ច-សង្គម ឆ្នាំ ២០០៤

[៣២] សម្រាប់ទស្សនៈទូលំទូលាយនៃការសិក្សាសំខាន់ៗភាគច្រើនអំពីការប្រកបរបរចិញ្ចឹមជីវិតនៅកម្ពុជា ចាប់តាំងពីឆ្នាំ ១៩៩៤ មក និងការរកឃើញ ផ្សេងៗទៀត សូមមើលរបាយការណ៍របស់ធនាគារពិភពលោកឆ្នាំ ២០០៤ ស្តីពីការសិក្សាពីប្រភពចំណូលនិងយុទ្ធសាស្ត្រប្រកបរបរចិញ្ចឹមជីវិត សរសេរដោយ Helmers, Gibson និង Wallgren ។ ឯកសារ ស្តីពី បញ្ហាប្រឈមក្នុងការប្រកបរបរចិញ្ចឹមជីវិតនៅជនបទ ៖ ទស្សនៈវិស័យមួយដែល បានមកពីភូមិ ៩ នៅកម្ពុជា សរសេរដោយ Chan និង Acharya វិទ្យាស្ថានធនធានអភិវឌ្ឍន៍កម្ពុជា (CDRI) ។

ក្នុងការទទួលផលពីធនធានធម្មជាតិរួម ហើយដែលបង្កឱ្យមានបញ្ហាប្រឈមជាច្រើន ក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព[៣៣] ។

**ភាពទទួលបានស្បៀង :**

ប្រជាពលរដ្ឋកម្ពុជានៅតាមទីជនបទ តាមធម្មតាជាអ្នកផលិតស្បៀង ដែលប្រឡូកដោយផ្ទាល់ក្នុងវិស័យកសិកម្ម ក៏ប៉ុន្តែពួកគាត់តែងតែពឹងផ្អែកយ៉ាងខ្លាំងទៅលើការទិញស្បៀងមួយចំនួន (រួមមានអង្ករផងដែរ) សម្រាប់រយៈពេលកំណត់មួយ ជារៀងរាល់ឆ្នាំ ។ ប្រជាពលរដ្ឋជាច្រើនអាចផលិតស្បៀងបានតែមួយផ្នែកសម្រាប់បំពេញតម្រូវការជាមូលដ្ឋានរបស់ពួកគាត់ ហេតុដូច្នេះហើយបានជាសន្តិសុខស្បៀងសម្រាប់ពួកគាត់គឺពឹងផ្អែកទៅលើការទិញស្បៀងពីទីផ្សារ ។

នៅក្នុងប្រទេសកម្ពុជា លទ្ធភាពទិញស្បៀងនៅលើទីផ្សារតែងតែមានកម្រិត ហើយក្រុមគ្រួសារក្រីក្រនៅតាមជនបទជាច្រើនខ្វះខាតទ្រព្យធនផលិតកម្ម(ដូចជា: ដី និងសត្វ) ដើម្បីរកប្រាក់ចំណូល ។ ប្រជាពលរដ្ឋប្រមាណ ៣៥ភាគរយរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ហើយប្រមាណ២០ភាគរយរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រស្បៀងអាហារ[៣៤] ។ ការកើនឡើងយ៉ាងឆាប់រហ័សនៃតម្លៃស្បៀងធ្វើឱ្យប្រជាពលរដ្ឋក្រីក្រនិងអសន្តិសុខស្បៀងកាន់តែជួបប្រទះការលំបាកបន្ថែមទៀតក្នុងការទិញស្បៀងឱ្យបានគ្រប់គ្រាន់សម្រាប់បរិភោគដែលជាហេតុនាំឱ្យពួកគាត់អាចផ្លាស់ប្តូរទៅទិញស្បៀងអាហារណាដែលមានតម្លៃថោក មានអាហារូបត្ថម្ភទាប និងមិនមានមីក្រូសារជាតិគ្រប់គ្រាន់ ។

ប្រភពនៃការរកប្រាក់ចំណូល ជារឿយៗ មានលក្ខណៈមិនទៀងទាត់ ហើយជាសកម្មភាពសេដ្ឋកិច្ចមិនមានសុវត្ថិភាព ដែលតែងតែកើតឡើងនៅតាមវិស័យសេដ្ឋកិច្ចឯកជន[៣៥] ។ ប្រព័ន្ធទីផ្សារនៅប្រទេសកម្ពុជា រួមទាំងទីផ្សារសម្រាប់ស្បៀងអាហារ ទាមទាឱ្យមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សេវាកម្ម និងមូលធន ដើម្បីផ្តល់លទ្ធភាពឱ្យបានល្អប្រសើរដល់ប្រជាពលរដ្ឋនៅមូលដ្ឋានក្នុងការទទួលបានស្បៀង ។

**ការប្រើប្រាស់ និងការបឺតស្រូបស្បៀង :**

ការប្រើប្រាស់ និងការបឺតស្រូបស្បៀងមិនបានសមស្របជាចំណែកយ៉ាងសំខាន់ក្នុងការបង្កឱ្យមានបញ្ហាកង្វះអាហារូបត្ថម្ភជាទូទៅនៅក្នុងប្រទេសកម្ពុជា។ កត្តាសាមញ្ញៗនៅទីនេះ គឺ ចំណេះដឹង និងការអនុវត្តផ្នែកអាហារូបត្ថម្ភមិនបានត្រឹមត្រូវល្អ ការទទួលសេវាកម្មថែទាំមាតាមិនគ្រប់គ្រាន់ ការអនុវត្តវិធីគាំពារមាតា និងទារកមិនបានសមស្រប និងអត្រាមានជំងឺខ្ពស់របស់កុមារ រួមមាន: ជំងឺរាគរូស ជំងឺផ្លូវដង្ហើម និងកង្វះមីក្រូសារ-ជាតិរបស់កុមារ ។ ប្រជាពលរដ្ឋក្រីក្រមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបានការថែទាំសុខភាព ដែលមាន

---

[៣៣] ឯកសារវាយតម្លៃ ស្តីពី ធនធានធម្មជាតិ និងការប្រកបរបរចិញ្ចឹមជីវិតនៅជនបទ នៅកម្ពុជា រសេរដោយ McKenney និង Tola ឆ្នាំ ២០០២ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា (CDRI) ។ ឯកសារ របស់ Baran ឆ្នាំ ២០០៣ ស្តីពី ការនេសាទនៅកម្ពុជា : ការពិត តួរលេខ និងបរិបទដោយមជ្ឈមណ្ឌលមច្ឆា ពិភពលោក និងរដ្ឋបាលជលផលនៃក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

[៣៤] *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* ឆ្នាំ ២០០៦ របស់ រាជរដ្ឋាភិបាលកម្ពុជា និង ការវាយតម្លៃភាពក្រីក្រនៅកម្ពុជា របស់ធនាគារពិភពលោក ឆ្នាំ ២០០៦ ។

[៣៥] ការវាយតម្លៃភាពក្រីក្រនៅកម្ពុជា របស់ធនាគារពិភពលោក ឆ្នាំ ២០០៦ ។ ទិដ្ឋភាពទូទៅនៃសេដ្ឋកិច្ចក្រៅផ្លូវការនៅកម្ពុជា ឆ្នាំ ២០០៥ របស់វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ( សរសេរដោយលោក Nuth )

គុណភាពខ្ពស់ដោយសារតែតម្លៃចំណាយ និងកង្វះខាតសេវាកម្ម ។ ការចំណាយទៅលើការថែទាំសុខភាពក្នុងស្ថានភាពធ្ងន់ធ្ងរសម្រាប់ប្រជាពលរដ្ឋក្រីក្រ ជាមូលហេតុចម្បងដែលបណ្តាលឱ្យមានការជំពាក់បំណុល និងការលក់ទ្រព្យសម្បត្តិនៅក្នុងផ្ទះ ហើយជាលទ្ធផលពួកគាត់នឹងប្រឈមមុខចំពោះភាពក្រីក្រ និងអសន្តិសុខស្បៀងរ៉ាំរ៉ៃនាពេលអនាគត[៣៦] ។ មូលហេតុលាក់កំបាំងសំខាន់មួយទៀតដែលបណ្តាលឱ្យកុមារមានជំងឺនៅក្នុងប្រទេសកម្ពុជា គឺថាក្រុមគ្រួសារនៅតាមជនបទពុំមានលទ្ធភាពទទួលបានអនាម័យ និងទឹកស្អាតគ្រប់គ្រាន់ ( ១៦ភាគរយមានអនាម័យគ្រប់គ្រាន់ ហើយ ៤២ ភាគរយមានទឹកស្អាតប្រើប្រាស់ ) ។

**ស្ថេរភាពស្បៀង :**

មូលហេតុចុងក្រោយនៃអសន្តិសុខស្បៀង គឺភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋកម្ពុជានៅតាមទីជនបទដោយសារតែគ្រោះធម្មជាតិដែលអាចកាត់បន្ថយការផ្គត់ផ្គង់ស្បៀង ភាពទទួលបានស្បៀង ឬការប្រើប្រាស់និងការបឺតស្រូបស្បៀងដើម្បីបំពេញតម្រូវការអប្បបរមា ។ ភាពងាយរងគ្រោះផ្នែកកសិ-បរិស្ថាន រួមមានៈ ហានិភ័យខ្ពស់នៃគ្រោះទឹកជំនន់ ឬគ្រោះរាំងស្ងួតដែលបំផ្លាញផលដំណាំ រីឯភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច-សង្គមរួមមានៈ ការពឹងផ្អែកលើប្រភពប្រាក់ចំណូលទាបនិងមិនទៀងទាត់ អនក្ខរភាព និងការអប់រំទាប ព្រមទាំងកត្តាជាច្រើនទៀតទាក់ទងនឹងសន្តិសុខ និងសិទ្ធិមនុស្ស[៣៧] ។

ក្រុមជនងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា មិនមានលទ្ធភាពផលិត ឬទិញស្បៀងសម្រាប់បំពេញតម្រូវការរបស់ពួកគាត់ជាបណ្តោះអាសន្ន ( ឧទាហរណ៍ : ដោយសារផលប៉ះពាល់ពីទឹកជំនន់ ឬគ្រោះរាំងស្ងួត ) ឬជាអចិន្ត្រៃយ៍ ( ឧទាហរណ៍ : ចាស់ជរារស់នៅតែឯង កុមារកំព្រា អ្នកមានជំងឺរ៉ាំរ៉ៃ ដូចជាៈ ជំងឺអេដស៍ឬ មេរោគអេដស៍ ទុរគតជន អ្នកអត់ការងារធ្វើ ជាដើម) ។ សមាសធាតុមួយទៀតនៃស្ថេរភាពស្បៀងដែលមិនពឹងផ្អែកលើទីផ្សារ គឺការផ្តល់ជំនួយសង្គ្រោះឱ្យបានគ្រប់គ្រាន់ ឬបណ្តាញសុវត្ថិភាពសង្គមសម្រាប់ផ្តល់ស្បៀងអាហារ និងតម្រូវការជាមូលដ្ឋានដទៃទៀតដល់ក្រុមជនងាយរងគ្រោះទាំងនោះ។ ទោះបីជាមានកម្មវិធីសំខាន់ៗជាច្រើនកំពុងដំណើរការក៏ដោយ ក៏ចាំបាច់តម្រូវឱ្យមានការបង្កើតបណ្តាញសុវត្ថិភាពសង្គម និងការកាត់បន្ថយហានិភ័យគ្រោះធម្មជាតិដើម្បីឆ្លើយតបនឹងតម្រូវការរបស់ក្រុមជនងាយរងគ្រោះនៅក្នុងសង្គម ។

### ២.២. បរិបទស្ថាប័ន និងគោលនយោបាយនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

ផ្នែកនេះពិនិត្យមើលអំពីបរិបទស្ថាប័ន និងគោលនយោបាយបច្ចុប្បន្ននៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខ-ស្បៀង និងអាហារូបត្ថម្ភ។

ក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភនេះ គឺជាដំណាក់កាលមួយទៀតនៅក្នុងដំណើរការដែលអ្នកពាក់ព័ន្ធនឹងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភតាមរយៈក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហា-

---

[៣៦] ការអង្កេតប្រជាសាស្ត្រនិងសុខភាព ឆ្នាំ ២០០៥

[៣៧] ឯកសារស្តីពីការគ្រប់គ្រងហានិភ័យ និងភាពងាយរងគ្រោះនៅកម្ពុជា របស់ធនាគារពិភពលោក ឆ្នាំ២០០៦ : ការវាយតម្លៃ និងការគាំពារពីសង្គម

រូបត្ថម្ភ[៣៨] ប្រកាន់យកដើម្បីជំរុញការបញ្ជ្រាបសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីជាតិ ព្រមទាំងទៅក្នុងដំណើការរៀបចំផែនការវិមជ្ឈការ ។ បទពិសោធន៍បានបង្ហាញឱ្យឃើញថា ការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ទាមទារឱ្យមានសហប្រតិបត្តិការយ៉ាងជិត ស្និទ្ធ និងយន្តការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពសម្រាប់ការខិតខំប្រឹងប្រែងរួមគ្នារបស់អ្នកពាក់ព័ន្ធជាច្រើនមកពីក្រសួង-ស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីសម្រេចឱ្យបានប្រសិទ្ធភាព និងលទ្ធផលជាអតិប្បរមា[៣៩] ។ ក្នុងបរិបទនេះ សន្និទានភាពនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា គឺដើម្បីផ្តល់ជូនជាឯកសារយោងយ៉ាងទូលំទូលាយសម្រាប់រៀបចំ និងពិនិត្យមើលយុទ្ធសាស្ត្រតាមវិស័យនានា និងដើម្បីណែនាំពីរបៀបរៀបចំ និងកសាងកម្មវិធី និងគម្រោងនានាសម្រាប់កែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់ប្រជាពលរដ្ឋទាំងអស់ ។

បច្ចុប្បន្ននេះ យើងត្រូវការជាចាំបាច់នូវក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ពីព្រោះថា រហូតមកដល់ពេលនេះ រដ្ឋាភិបាលមិនទាន់មាន ឬបានអនុម័តក្របខ័ណ្ឌទូលំទូលាយណាមួយសម្រាប់វិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទោះបីជាបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភតែងតែត្រូវបានលើកឡើងដដែលៗថាជាអាទិភាពយ៉ាងសំខាន់របស់រដ្ឋាភិបាលនៅក្នុងក្របខ័ណ្ឌគោលនយោបាយជាតិ និងគោលនយោ-បាយតាមវិស័យនានាដែលមានស្រាប់យ៉ាងណាក៏ដោយ ។ ម្យ៉ាងវិញទៀត កម្មវិធីអភិវឌ្ឍន៍នានាដែលកំពុងដំណើរការនៅក្នុងប្រទេសកម្ពុជាបានបញ្ជាក់អំពីការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (ឬសមាធាតុសាមញ្ញមួយចំនួន) ថាជាគោលបំណងយ៉ាងសំខាន់មួយ ក៏ប៉ុន្តែកម្មវិធីទាំងនេះខ្វះការគាំទ្រផ្នែកក្របខ័ណ្ឌយុទ្ធសាស្ត្រពហុវិស័យដែលក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភអាចផ្តល់ជូន ។

បរិស្ថានគោលនយោបាយសម្រាប់ក្របខ័ណ្ឌយុទ្ធសាស្ត្រ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដែលត្រូវបានអនុម័តកាលពីឆ្នាំ ២០០៣ ។ គោលដៅទី១ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា គឺ **"លុបបំបាត់ភាពក្រីក្រ និងភាពស្រេកឃ្លាន"**[៤០] ។ ការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក៏ដើរតួនាទីយ៉ាងសំខាន់ផងដែរក្នុងការ សម្រេចគោលដៅ៨ ផ្សេងទៀត នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដូចដែលបានបង្ហាញនៅក្នុងតារាង ៧ ។

---

[៣៨] ក្រុមការងារបច្ចេកទេស សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ជាក្រុមការងារមួយក្នុងចំណោមក្រុមការងារបច្ចេកទេសទាំង ១៩ សម្រាប់ផ្តល់យោបល់ដល់រដ្ឋាភិបាល អំពីវិស័យ មួយចំនួនតាមជំនាញរបស់ខ្លួន ។

[៣៩] ស្ថានភាពអាហារូបត្ថម្ភ និងឥរិយាបទអាហារូបត្ថម្ភនៅកម្ពុជាមានការកែលម្អគួរឱ្យកត់សំគាល់ (ឯកសាររបស់ កកជ) ។

[៤០] របាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាលកម្ពុជា ។ អ្នកអានអាចមើល របាយការណ៍ស្តីពីការសិក្សាអំពីការវាយតម្លៃ និងការធ្វើមូលដ្ឋានីយកម្ម នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ស្តីពីការកាត់បន្ថយភាពក្រីក្រ និងភាពស្រេកឃ្លាន ដែលមានការវិភាគស្ថានភាពយ៉ាងល្អ នៃ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ និង គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា សម្រាប់រយៈកាលនោះ ។

**តារាង ៧ :   តួនាទីនៃការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា**

| **គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា** | **តួនាទីនៃការកែលម្អ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ** |
|---|---|
| *១. លុបបំបាត់ភាពក្រីក្រ និងភាពស្រេកឃ្លាន* | ការកែលម្អសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ជាកត្តាផ្ទាល់សម្រាប់លុបបំបាត់ភាពអត់ឃ្លាន ហើយក៏ជាសមាសធាតុសំខាន់ក្នុងការលុបបំបាត់ភាពក្រីក្រ។ អសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភ បំផ្លាញធនធានមនុស្ស កាត់បន្ថយលទ្ធភាពក្នុងការទប់ស្កាត់គ្រោះមហន្តរាយ និងកាត់បន្ថយផលិតភាពកម្លាំងពលកម្ម ។ |
| *២. ការសម្រេចបានសកលកម្មការអប់រំ បឋមសិក្សា* | ការកែលម្អ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ នឹងជួយបង្កើនការចូលរៀន បន្ថយអត្រាបោះបង់ចោលការសិក្សា និងកែលម្អសកម្មភាពសិក្សារបស់សិស្ស ។ |
| *៣. ជម្រុញសមភាពយេនឌ័រ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រី* | នារីនិងស្ត្រីដែលមានសន្តិសុខស្បៀងនិងអាហារូបត្ថម្ភល្អ នឹងមានសុខភាពល្អ ហើយនិងមានគុណសម្បត្តិជាច្រើនក្នុងការទទួលបានការអប់រំខ្ពស់ សុខុមាលភាពសេដ្ឋកិច្ចខ្ពស់ ជម្រើសក្នុងការបន្តពូជ ថែទាំកូនចៅបានល្អ និង ការចូលរួមក្នុងការងារអភិបាលកិច្ចនៃ សង្គមស៊ីវិល ។ |
| *៤. កាត់បន្ថយមរណភាពកុមារ* | អង្គការសុខភាពពិភពលោកប៉ាន់ស្មានថា ៥៤ភាគរយនៃកុមារអាយុក្រោម៥ឆ្នាំ ដែលស្លាប់មុនអាយុ គឺបណ្តាលមកពីកង្វះអាហារូបត្ថម្ភ ហើយថា នេះគឺជាកត្តាដែលបណ្តាលឱ្យកុមារស្លាប់ជារឿយៗ ។ ការកែលម្អ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ និង អាហារូបត្ថម្ភរបស់កុមារនឹងជួយកាត់បន្ថយមរណភាពកុមារដោយផ្ទាល់ ។ |
| *៥. លើកកំពស់សុខភាពមាតា* | អសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភមានពាក់ព័ន្ធនឹងកត្តាហានិភ័យចម្បងៗជាច្រើនសម្រាប់មរណភាពមាតា។ មាតាស្ត្រីកម្ពុជាទទួលរងអត្រាខ្ពស់នៃកង្វះអាហារូបត្ថម្ភ និងជំងឺផ្សេងៗ ដែលមានឥទ្ធិពលអវិជ្ជមានដល់សុខភាពមាតានិងកុមារតូចៗ។ |
| *៦. ប្រយុទ្ធប្រឆាំងជំងឺអេដស៍/មេរោគអេដស៍ គ្រុនចាញ់ និង ជំងឺផ្សេងៗ ទៀត* | អសន្តិសុខស្បៀងជំរុញឱ្យមានការធ្វើចំណាកស្រុកដែលធ្វើការរួមភេទដោយគ្មានសុវត្ថិភាព និង/ឬពេស្យាចារដែលជាមូលហេតុបង្កើន ការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍។ អាហារូបត្ថម្ភគ្រប់គ្រាន់និងសន្តិសុខស្បៀងមានសារសំខាន់យ៉ាងខ្លាំងសម្រាប់ពន្យាជីវិតអ្នកមានមេរោគអេដស៍/ជំងឺអេដស៍ និងសម្រាប់ កាត់បន្ថយ អត្រាស្លាប់ដោយសារ ជំងឺគ្រុនចាញ់និងជំងឺផ្សេងៗទៀត ។ |
| *៧. ធានាចីរភាពបរិស្ថាន* | អសន្តិសុខស្បៀងជាមូលហេតុនៃការប្រើប្រាស់ដីព្រៃឈើ និងធនធានដទៃទៀតដោយគ្មានចីរ-ភាព។ ជនក្រីក្រនិងអសន្តិសុខស្បៀងជារឿយៗពឹងផ្អែកទៅលើព្រៃឈើ និងជលផល ដែលជាប្រភពផ្គត់ផ្គង់ស្បៀងសម្រាប់តម្រូវការរបស់ពួកគាត់ ។ ដូច្នេះការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺជាសមាសធាតុ យ៉ាងសំខាន់ក្នុងការធានាបានចីរភាពបរិស្ថាន ។ |
| *៨. បង្កើតដៃគូសកលក្នុងការអភិវឌ្ឍ* | ភាពជាដៃគូនេះចាំបាច់គួរតែមានបញ្ចូលដៃគូអភិវឌ្ឍន៍ និងស្ថាប័នអន្តរជាតិ ដែលមានជំនាញក្នុងការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។ |
| *៩. ការដោះមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនិងសង្គ្រោះជនរងគ្រោះ* | ជនក្រីក្រនិងអសន្តិសុខស្បៀងងាយរងគ្រោះនិងទទួលផលប៉ះពាល់ជាពិសេសពីមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដោយសារតែពួកគាត់ពឹងផ្អែកយ៉ាងខ្លាំងទៅលើព្រៃឈើ និងជលផល សម្រាប់ផ្គត់ផ្គង់ជីវភាព ។ |

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា អាចសម្រេចបានតាមរយៈយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋា-ភិបាលកម្ពុជា ឆ្នាំ ២០០៤ និងយន្តការអនុវត្តន៍នានា ហើយនិងតាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៦-២០១០)។

កំឡុងពេលដំណើរការពិគ្រោះយោបល់ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ បានផ្តល់អនុសាសន៍លើផ្នែកគោលនយោបាយ និងបានរៀបចំតារាងម៉ាទ្រីសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយបង្ហាញអំពីឧបសគ្គ និងសកម្មភាពនានា ហើយបាន ផ្តល់ជូនលេខាធិការដ្ឋានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនៃក្រសួងផែនការ ។

ដូចដែលបានបញ្ជាក់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលថា "**ការកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់រហ័សគឺជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា**"[៤១] ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិទទួលស្គាល់ថា សន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺជាបញ្ហាពហុវិស័យយ៉ាងសំខាន់មួយ ហើយការសម្រេចបានការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺជាអាទិភាពនៃការអភិវឌ្ឍជាតិ[៤២] ។ ផ្នែកដែលនិយាយពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ត្រូវបានដកស្រង់ដូចខាងក្រោម :

> *ផ្នែក ៤.៤៦ នៃ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* : សន្តិសុខស្បៀង និងអាហារូបត្ថម្ភ (សន្តិសុខស្បៀង និងអាហារូបត្ថម្ភ) គឺជាបញ្ហាពហុវិស័យយ៉ាងសំខាន់ ហើយការរីកចម្រើនជាក់ស្តែងក្នុងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺជាកត្តាចម្បងក្នុងការកាត់បន្ថយ អត្រាខ្ពស់នៃកង្វះអាហារូបត្ថម្ភ និងកង្វះមីក្រូសារជាតិក្នុងចំណោមស្ត្រី និងកុមារ ។ គោលដៅចម្បងគឺធានាថា "***ត្រឹមឆ្នាំ២០១០ ប្រជាជនកម្ពុជាក្រីក្រ និងស្ថិតក្នុងស្ថានភាពអសន្តិសុខស្បៀងនឹងមានលទ្ធភាពផ្នែករូបវន្ត សង្គម និងសេដ្ឋកិច្ចល្អប្រសើរច្រើនក្នុងការទទួលបានស្បៀងអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងមានជីវជាតិ ដើម្បីបំពេញសេចក្តីត្រូវការរបបអាហារ និងចំណង់ចំណូលចិត្តរបស់ពួកគេ នៅគ្រប់ពេលវេលា សម្រាប់ការរស់នៅដ៏សកម្ម និងមានសុខភាពមាំមួន***" ។ ការសម្រេចគោលដៅនេះទាមទាឱ្យមានការខិតខំប្រឹងប្រែងរួមគ្នាក្នុងវិស័យនានា ដូចដែលបានបញ្ជាក់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយផ្តោតជាសំខាន់ទៅលើសមាសធាតុដូចខាងក្រោម ជាពិសេសពាក់ព័ន្ធទៅនឹងប្រជាពលរដ្ឋក្រីក្រ និងអសន្តិសុខស្បៀង ។
>
> បង្កើន និងធានាភាពមានស្បៀង
>
> កែលម្អភាពទទួលបានស្បៀង (ពាក់ព័ន្ធនឹងប្រាក់ចំណូល និងលទ្ធភាពថវិកា)
>
> ធានាឱ្យបានការប្រើប្រាស់ និងការបឺតស្រូបស្បៀងបានយ៉ាងល្អប្រសើរ តាមរយៈការអប់រំអំពីសុខភាព និងអាហារូបត្ថម្ភ (រួមមាន: ការកែលម្អការអនុវត្តរបៀបចិញ្ចឹមកុមារ និងអាហារូបត្ថម្ភរបស់មាតា) កម្មវិធីផ្តល់បន្ថែមមីក្រូសារជាតិ និងបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារ (ជាតិដែក ជីវជាតិអា) ការជំរុញការអនុវត្តការប្រើប្រាស់អំបិលអ៊ីយ៉ូដជាសកល និងការអនុវត្តស្តង់ដាសុវត្ថិភាពស្បៀងផ្សេងៗទៀត ។ល។

លក្ខណៈពហុវិស័យនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ មានន័យថា គោលនយោបាយ និងយុទ្ធសាស្ត្រនានាតាមវិស័យនីមួយៗ ព្រមទាំងយុទ្ធសាស្ត្រ និងគោលនយោបាយពហុវិស័យដទៃទៀត មានឥទ្ធិពលខ្លាំងក្លា

---

[៤១] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ របស់រាជរដ្ឋាភិបាល ឆ្នាំ ២០០៦ ទំព័រទី ២៩

[៤២] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ របស់រាជរដ្ឋាភិបាល ឆ្នាំ ២០០៦ ទំព័រទី ៤៧ ផ្នែក ៤.៤៦

ថែមទៀតទៅលើបរិបទគោលនយោបាយសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ យុទ្ធសាស្ត្រ និងគោលនយោបាយពហុវិស័យពាក់ព័ន្ធនានា មាននៅក្នុងតារាង ៨ ខាងក្រោម ។

**តារាង ៨ : គោលនយោបាយ/យុទ្ធសាស្ត្រពហុវិស័យ និងស្ថាប័នដែលពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**

| យុទ្ធសាស្ត្រ/ គោលនយោបាយបច្ចុប្បន្ន | សមាសធាតុ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ | ស្ថាប័នសំខាន់ៗ និងស្ថានភាព នៃគោលនយោបាយ |
|---|---|---|
| *គោលនយោបាយអភិវឌ្ឍន៍មីក្រូសេដ្ឋកិច្ច* | គោលនយោបាយអភិវឌ្ឍន៍មីក្រូសេដ្ឋកិច្ចគឺជាបរិបទទូលំទូលាយមួយសម្រាប់កាត់បន្ថយភាពក្រីក្រ និងកែលម្អ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ | ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ត្រូវបានអនុម័ត |
| *គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ* | កំណែទម្រង់ស្ថាប័ន និងការកសាងសមត្ថភាពផ្នែក សន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅថ្នាក់វិមជ្ឈការ គឺថ្នាក់ខេត្តនិងថ្នាក់ឃុំ-សង្កាត់ | ក្រសួងមហាផ្ទៃបានអនុម័ត |
| *យុទ្ធសាស្ត្រចតុកោណ ឆ្នាំ២០០៤* | ការកែលម្អ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ពឹងផ្អែកលើកំណែទម្រង់អភិបាលកិច្ចល្អ | ក្រសួងទាំងអស់ |
| *គោលនយោបាយ យែនឌ័រ* | មានបញ្ហាយែនឌ័រសំខាន់ៗជាច្រើននៅក្នុងគ្រប់សមាសធាតុទាំងអស់ នៃ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ | ក្រសួងកិច្ចការនារី/ក្រសួងទាំងអស់បានអនុម័ត |
| *គោលនយោបាយគ្រប់គ្រងគ្រោះមហន្តរាយ* | ស្ថេរភាពស្បៀង (ការសម្រាលផលប៉ះពាល់ដោយសារគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតទៅលើផលិតកម្មកសិកម្ម) | គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ/យុទ្ធសាស្ត្រតាមវិស័យនៅក្នុង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* គោលនយោបាយនេះមិនទាន់រៀបចំ) |
| *គោលនយោបាយបរិស្ថាន* | ភាពមានស្បៀង (ប្រព័ន្ធកសិបរិស្ថាន ព្រៃឈើ និងជលផល) ការប្រើប្រាស់និងការបឺតស្រូបស្បៀង និងស្ថេរភាពស្បៀង (ការសម្រាលផលប៉ះពាល់ដោយសារគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួតទៅលើផលិតកម្មកសិកម្ម) | ក្រសួងបរិស្ថាន/យុទ្ធសាស្ត្រតាមវិស័យនៅក្នុង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* គោលនយោបាយនេះមិនទាន់រៀបចំ) |
| *កម្មវិធីជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA)* | ភាពមានស្បៀង (ប្រព័ន្ធកសិបរិស្ថាន ព្រៃឈើ និងជលផល) | ក្រសួងបរិស្ថាន បានអនុម័ត |
| *គោលនយោបាយជាតិប្រជាពលរដ្ឋ ឆ្នាំ ២០០៣* | ការប្រើប្រាស់ និងការបឺតស្រូបស្បៀង (សេវាថែទាំសុខភាពសុខភាពមាតានិងកុមារ) | គណៈកម្មាធិការសម្រាប់ប្រជាពលរដ្ឋ និងការអភិវឌ្ឍ បានអនុម័ត |

ប្រភេទសំខាន់ៗនៃគោលនយោបាយតាមវិស័យនានា និងក្រសួង-ស្ថាប័នរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ មាននៅក្នុងតារាង ៩ ខាងក្រោម ដែលមានបញ្ចូលសមាធាតុជាច្រើននៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងកំណត់ព្រាពន្យល់អំពីស្ថានភាពបច្ចុប្បន្ននៃគោលនយោបាយ/យុទ្ធសាស្ត្រនីមួយៗនៅក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្ន ។

## តារាង ៩: គោលនយោបាយ/យុទ្ធសាស្ត្រសំខាន់ៗតាមវិស័យនានា និងក្រសួងដែលពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

| **យុទ្ធសាស្ត្រ/ គោលនយោបាយតាមវិស័យនានា** | **សមាសធាតុសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** | **ស្ថាប័នសំខាន់ៗ និងស្ថានភាពនៃគោលនយោបាយ** |
|---|---|---|
| *យុទ្ធសាស្ត្រវិស័យកសិកម្ម និងទឹក* | ភាពមានស្បៀង( កសិកម្ម/ធារាសាស្ត្រ) ភាពទទួលបានស្បៀង (បង្កើនប្រាក់ចំណូលពីកសិកម្ម) ការបញ្ចូលកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ( កម្មវិធីជាតិសម្រាប់សន្តិសុខស្បៀង និង ការកាត់បន្ថយភាពក្រីក្រ) ការប្រើប្រាស់និងការបឺតស្រូបស្បៀង (ទឹកស្អាត) | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិងក្រសួងធនធាន-ទឹក និងឧតុនិយម បានអនុម័ត |
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ក្រសួងធនធានទឹកនិងឧតុនិយម ឆ្នាំ ២០០៦-២០១០* | ភាពទទួលបានស្បៀង (បង្កើនប្រាក់ចំណូលពីកសិកម្ម) ការបញ្ចូលកែលម្អ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ( កម្មវិធីជាតិសម្រាប់សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ) ការប្រើប្រាស់ និង ការបឺតស្រូបស្បៀង (ទឹកស្អាត) ស្ថេរភាពស្បៀង ( ការគ្រប់គ្រងធនធានទឹក រាំងស្ងួត និងទឹកជំនន់ ) | ក្រសួងធនធានទឹកនិងឧតុនិយម បានព្រាងនិងអនុម័ត |
| *គោលនយោបាយគ្រប់គ្រងដីធ្លី និង ច្បាប់ភូមិបាល ឆ្នាំ ២០០១* | ភាពមានស្បៀង ( កម្មសិទ្ធិដីកសិកម្ម សម្បទានដីសង្គមកិច្ច កំណែទម្រង់ដីធ្លី ការបោសសម្អាតមីនក្នុងដី និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ) | ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ |
| *គោលនយោបាយព្រៃឈើ* | ភាពមានស្បៀងនិងភាពទទួលបានស្បៀង (សិទ្ធិទទួលបាន, ផលិតភាព និងចីរភាពនៃធនធានព្រៃឈើសម្រាប់ស្បៀងអាហារ និង ប្រាក់ចំណូល) | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គោលនយោបាយ/ យុទ្ធ-សាស្ត្រតាមវិស័យ នៅក្នុង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* មិនទាន់បានរៀបចំ ។ សមាសធាតុនានា រួមមាន: ការគ្រប់គ្រងព្រៃសហគមន៍ និងព្រៃសម្បទានមានចែងនៅក្នុងអនុក្រឹត្យ |
| *គោលនយោបាយវិស័យជលផល និងសេចក្តីព្រាងច្បាប់ជលផល ឆ្នាំ ២០០៥* | ភាពមានស្បៀង និងភាពទទួលបានស្បៀង (សិទ្ធិទទួលបាន, ផលិតភាព និងចីរភាពធនធានជលផលសម្រាប់ស្បៀងអាហារ និង ប្រាក់ចំណូល) | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គោលនយោបាយ/ យុទ្ធសាស្ត្រតាមវិស័យ នៅក្នុង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* បានរៀបចំ ។ |
| *យុទ្ធសាស្ត្ររយៈពេល ១០ឆ្នាំ ២០០១-២០១១ស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ* | ការប្រើប្រាស់និងការបឺតស្រូបស្បៀង ( ការកែលម្អលទ្ធភាពទទួលបានទឹកស្អាតនិងអនាម័យ និងការកាត់បន្ថយកង្វះអាហារូបត្ថម្ភ ជំងឺដង្កាត់ និងមរណភាពរបស់កុមារ) | ក្រសួងអភិវឌ្ឍន៍ជនបទ បានព្រាងតាំងពីឆ្នាំ ២០០១ តែមិនទាន់បានអនុម័ត |
| *គោលនយោបាយសុវត្ថិភាពស្បៀង* | ការប្រើប្រាស់និងការបឺតស្រូបស្បៀង (ស្តង់ដារគុណភាព និង សុវត្ថិភាពស្បៀង) | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល គោលនយោបាយ/យុទ្ធសាស្ត្រតាមវិស័យ នៅក្នុង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* បានរៀបចំ |
| *ផែនការយុទ្ធសាស្ត្រវិស័យសុខា-ភិបាល ឆ្នាំ ២០០៣-២០០៧* | ការប្រើប្រាស់និងការបឺតស្រូបស្បៀង( សេវាថែទាំសុខភាព កម្មវិធីជាតិអាហារូបត្ថម្ភ សុខភាពមាតានិងកុមារ ការធានារ៉ាប់រងសុខ-ភាពសង្គម) | ក្រសួងសុខាភិបាលបានអនុម័ត និងកំពុងរៀបចំធ្វើបច្ចុប្បន្នភាព |
| *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០០៦-២០១០* | ឥទ្ធិពលវិជ្ជមានរយៈពេលវែង ទៅលើការកែលម្អ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ គ្រប់ សមាសធាតុទាំងអស់ តាមរយៈការកែលម្អការអប់រំ និងអក្ខរកម្ម ជាពិសេសសម្រាប់ ស្ត្រី | ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័ត |

បើនិយាយពីការរៀបចំគោលនយោបាយតាមវិស័យនានាពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនាពេលបច្ចុប្បន្ន ក្រុមការងារបច្ចេកទេសសន្តិសុខស្បៀងនិងអាហារូបត្ថម្ភបានផ្តល់យោបល់ និងស្នើសុំកែសម្រួលសេចក្តីព្រាងយុទ្ធសាស្ត្រកសិកម្មនិងទឹក២០០៦-២០១០។ ដោយមានការផ្តល់យោបល់ពីក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹកត្រូវបានធ្វើការកែសម្រួលដោយបានបញ្ចូលសន្តិសុខស្បៀង ជាគោលដៅ និងជាកម្មវិធីគាំទ្រដាច់ដោយឡែកនៅក្នុងយុទ្ធសាស្ត្រនេះ ។

រចនាសម្ព័ន្ធសម្របសម្រួលការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីផ្តល់ការគាំទ្រដល់ក្រសួង-ស្ថាប័នរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ក្នុងការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រត្រូវបានរៀបចំបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជារួចហើយ។រចនាសម្ព័ន្ធនេះបង្កើតបានជាផ្នែកយ៉ាងសំខាន់នៃបរិបទស្ថាប័ននិងគោលនយោបាយសម្រាប់ពេលអនាគត ។ រចនាសម្ព័ន្ធសម្របសម្រួលសន្តិសុខស្បៀង និងអាហារូបត្ថម្ភទាំងនេះទាមទាឱ្យការអភិវឌ្ឍ និងការគាំទ្របន្ថែមទៀត។

អាណត្តិទូទៅរបស់រដ្ឋាភិបាលក្នុងការសម្រួលបណ្តាញទំនាក់ទំនងអន្តរក្រសួង និងការងារសម្របសម្រួលបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺពឹងផ្អែកទៅលើក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទធ្លាប់បានរៀបចំសិក្ខាសាលាជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលពីឆ្នាំ១៩៩៩ និង២០០៣ ។ កាលពីឆ្នាំ ២០០៣ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក៏បានបង្កើតវេទិកាសន្តិសុខស្បៀងផងដែរ ដើម្បីចែករំលែកព័ត៌មាន បទពិសោធន៍ និងចំណេះដឹងពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់ ។ នៅចុងឆ្នាំ ២០០៤ រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលមានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងក្រសួងផែនការជាសហប្រធាន និងមានអង្គការកម្មវិធីស្បៀងអាហារពិភពលោក និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិជាអ្នកសម្របសម្រួលរួម ។ គោលបំណងសំខាន់នៃការបង្កើតក្រុមការងារបច្ចេកទេសនេះ គឺដើម្បីផ្តល់យោបល់ផ្នែកបច្ចេកទេសដល់រាជរដ្ឋាភិបាលក្នុងនាមអ្នកពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ជំរុញការបញ្ជ្រាបសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រនានា និងដើម្បីកែលម្អការសម្របសម្រួលរវាងអ្នកពាក់ព័ន្ធទាំងអស់ ។ លេខាធិការដ្ឋានអចិន្ត្រៃយ៍មួយសម្រាប់ក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបានបង្កើតឡើងនៅក្នុងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដើម្បីគាំទ្រនិងជួយដល់ក្រុមការងារបច្ចេកទេស ។

នៅឆ្នាំ១៩៩៦ ក្រុមប្រឹក្សាអាហារូបត្ថម្ភត្រូវបានបង្កើតឡើងនៅក្នុងក្រសួងផែនការ ។ ដោយមានការណែនាំដោយផ្ទាល់ពីក្រុមប្រឹក្សាអាហារូបត្ថម្ភ ផែនការវិនិយោគអាហារូបត្ថម្ភ(២០០៣-២០០៧) ត្រូវបានរៀបចំឡើង ហើយក្រសួងផែនការគ្រោងនឹងធ្វើបច្ចុប្បន្នភាពផែនការវិនិយោគអាហារូបត្ថម្ភ(២០០៨-២០១៣) ។ ថ្មីៗនេះ

ក្រសួងសុខាភិបាលបានរៀបចំផែនការយុទ្ធសាស្ត្រអាហារូបត្ថម្ភ (២០០៨-២០១៥) ដើម្បីគូសបញ្ជាក់អំពីយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់កម្មវិធីជាតិអាហារូបត្ថម្ភ ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រវិស័យសុខាភិបាល ។

ដើម្បីឱ្យស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រដ្ឋាភិបាល គណៈកម្មាធិការសម្របសម្រួលអាហារូបត្ថម្ភខេត្តត្រូវបានបង្កើតឡើងដោយក្រសួងផែនការនៅគ្រប់ខេត្ត-ក្រុងទាំងអស់[៤៣] ។ លើសពីនេះទៅទៀត តាមរយៈក្រសួងផែនការ និងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដោយសហការជាមួយគម្រោងអភិវឌ្ឍន៍នានា មន្ត្រីខេត្ត និងសមាជិកក្រុមប្រឹក្សាឃុំត្រូវបានបណ្តុះបណ្តាលអំពីគោលគំនិតសន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់បញ្ជ្រាបសន្តិសុខស្បៀង និងអាហារូបត្ថម្ភទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ។

នៅឆ្នាំ ២០០៤ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានបង្កើតអនុក្រុមសន្តិសុខស្បៀងនៅក្នុងក្រុមការងារនីតិសម្បទានិងជំនួយសង្គ្រោះ ដឹកនាំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដោយមានជំនួយឧបត្ថម្ភពីអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងអង្គការកម្មវិធីស្បៀងអាហារពិភពលោក។ ទោះបីជាអនុក្រុមនេះមិនសូវសកម្ម ហើយដែលចាំបាច់គួរតែធ្វើឱ្យដំណើរការសកម្មឡើងវិញក៏ដោយ ក៏ក្រុមការងារនេះពិតជាមានសក្តានុពលក្នុងការដោះស្រាយចំណុចស្នេរភាពនៃសន្តិសុខស្បៀង ដោយមានការផ្តល់យោបល់ និងការណែនាំពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងភាគីពាក់ព័ន្ធដទៃទៀត ។

ផ្នែកនេះគូសបញ្ជាក់ពីបរិបទស្ថាប័ន និងគោលនយោបាយដ៏សំខាន់នៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។ នៅក្នុងបរិបទនេះ ក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ អាចជួយលើកកម្ពស់ការសម្របសម្រួលរវាងក្រសួង និងគោលនយោបាយតាមវិស័យនានា តាមរយៈការផ្តល់ក្របខ័ណ្ឌ យ៉ាងសាមញ្ញនៃទស្សនវិស័យ គោលដៅ និងគោលបំណងជាយុទ្ធសាស្ត្រទាំងប្រាំ ដោយមានសកម្មភាពជាអាទិភាពពាក់ព័ន្ធមួយចំនួន ។

---

[៤៣] សមត្ថភាព និងដំណើរការការងាររបស់គណៈកម្មាធិការសម្របសម្រួលអាហារូបត្ថម្ភខេត្ត មានភាពខុសៗគ្នាតាមខេត្តនិមួយៗ

## ៣. ទស្សនវិស័យ គោលដៅ និងគោលបំណងនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

### ទស្សនវិស័យរយៈពេលវែងនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

ទស្សនវិស័យរយៈពេលវែងនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ គឺការសម្រេចបានសន្តិសុខស្បៀង និងអាហារូបត្ថម្ភគ្រប់គ្រាន់សម្រាប់ប្រជាពលរដ្ឋកម្ពុជា។ ទស្សនវិស័យនេះស្របទៅនឹងទិសដៅជាសកលនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ដែលបានអនុម័ត និងស្របតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ដូច្នេះ ទស្សនវិស័យនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺ :

***"ប្រជាពលរដ្ឋកម្ពុជាក្រីក្រ និងអសន្តិសុខស្បៀងទាំងអស់នឹងមានលទ្ធភាពល្អប្រសើរទាំងផ្នែករូបវ័ន្ត និងផ្នែកសេដ្ឋកិច្ចក្នុងការទទួលបានស្បៀងអាហារមានសុវត្ថិភាព និងមានជីវជាតិគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការរបបអាហារ និងចំណង់ចំណូលចិត្តនៅគ្រប់ពេលវេលាទាំងអស់ សម្រាប់ជីវិតរស់នៅយ៉ាងសកម្ម និងមានសុខភាពមាំមួន"*** ។

### គោលដៅនៃក្របខ័ណ្ឌយុទ្ធសាស្ត្រ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០០៨-២០១២

គោលដៅនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺផ្តោតលើការសម្រេចបានវឌ្ឍនភាពក្នុងការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា នៅក្នុងរយៈពេលនៃក្របខ័ណ្ឌ ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០*** បច្ចុប្បន្ន។ គោលដៅសន្តិសុខស្បៀង និងអាហារូបត្ថម្ភត្រូវបានបញ្ចូលរួចហើយទៅក្នុង***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*** ហើយគោលដៅនេះស្រមតាមវឌ្ឍនភាពក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាក្នុងរយៈពេលមធ្យម ។ ដូច្នេះ គោលដៅនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺ :

***"ត្រឹមឆ្នាំ២០១២ ប្រជាពលរដ្ឋកម្ពុជាក្រីក្រ និងអសន្តិសុខស្បៀងនឹងមានលទ្ធភាពល្អប្រសើរច្រើន ទាំងផ្នែករូបវ័ន្ត និងផ្នែកសេដ្ឋកិច្ច ក្នុងការទទួលបានស្បៀងអាហារមានសុវត្ថិភាព និងមានជីវជាតិគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការរបបអាហារ និងចំណង់ចំណូលចិត្តនៅគ្រប់ពេលវេលាទាំងអស់ សម្រាប់ជីវិតរស់នៅយ៉ាងសកម្ម និងមានសុខភាពមាំមួន"*** ។

### គោលបំណងនៃក្របខ័ណ្ឌយុទ្ធសាស្ត្រ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០០៨-២០១២

ក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០០៨-២០១២ មានគោលបំណងប្រាំ ដើម្បីសម្រេច គោលដៅនៃក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ។ គោលបំណងទីមួយ១នឹងតម្រូវឱ្យមានការផ្តល់ឱកាសសម្រាប់ការអនុវត្តសកម្មភាព ជាអាទិភាពជាច្រើន ដែលទាមទាឱ្យមានការវិនិយោគលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម

តាមវិស័យនានាជាច្រើនរបស់ក្រសួង-ស្ថាប័នសម្របសម្រួលរបស់រាជរដ្ឋាភិបាល ។ ក្រសួង-ស្ថាប័នសម្របសម្រួលរបស់ រាជរដ្ឋាភិបាលទាំងនេះក៏នឹងទាមទាឱ្យមានការអភិវឌ្ឍសមត្ថភាពស្ថាប័នបន្ថែមទៀតផងដែរ ។

**គោលបំណងទី១:** ក្រុមគ្រួសារអសន្តិសុខស្បៀង**បង្កើនភាពមានស្បៀង**តាមរយៈផលិតកម្មកសិកម្ម និងបសុសត្វ និងតាមរយៈធនធានជលផល និងអនុផលព្រៃឈើ ។

យើងអាចសម្រេចគោលដៅនេះតាមរយៈការធ្វើឱ្យមានវឌ្ឍនភាពលើវិស័យបួន ដូចខាងក្រោម :

១. ការកែលម្អផលិតភាពកសិកម្ម និងពិពិធកម្មកសិកម្ម

២. ការកែលម្អការគ្រប់គ្រងធនធានទឹក និងធារាសាស្ត្រ

៣. ការជំរុញកំណែទម្រង់ជលផល

៤. ការជំរុញកំណែទម្រង់ព្រៃឈើ

**គោលបំណងទី២:** ក្រុមគ្រួសារអសន្តិសុខស្បៀង**បង្កើនភាពទទួលបានស្បៀង**តាមរយៈការបង្កើនប្រាក់ចំណូលក្នុងគ្រួសារ ។

យើងអាចសម្រេចគោលដៅនេះតាមរយៈការធ្វើឱ្យមានវឌ្ឍនភាពលើវិស័យបួន ដូចខាងក្រោម :

១. ការបង្កើនកាលានុវត្តភាពការងាររកកម្រៃសម្រាប់ក្រុមគ្រួសារក្រីក្រ និងអសន្តិសុខស្បៀង

២. ការបង្កើនកាលានុវត្តភាពមីក្រូសហគ្រាស សម្រាប់ក្រុមគ្រួសារក្រីក្រ និងអសន្តិសុខស្បៀង

៣. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទីផ្សារ

៤. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដឹកជញ្ជូន

**គោលបំណងទី៣:** ក្រុមគ្រួសារអសន្តិសុខស្បៀង**កែលម្អការប្រើប្រាស់និងការបឺតស្រូបស្បៀង** ដើម្បីកាត់បន្ថយបញ្ហាកង្វះអាហារូបត្ថម្ភ ជំងឺដង្កាត់ និងមរណភាព ជាពិសេសក្នុងចំណោមស្ត្រី និងកុមារ ។

យើងអាចសម្រេចគោលដៅនេះតាមរយៈការធ្វើឱ្យមានវឌ្ឍនភាពលើវិស័យបី ដូចខាងក្រោម :

១. ការកាត់បន្ថយកង្វះអាហារូបត្ថម្ភ និងមរណភាពរបស់មាតា និងកុមារ

២. ការកែលម្អការផ្គត់ផ្គង់ទឹកស្អាត និងការអនុវត្តអនាម័យនៅតាមគ្រួសារ

៣. ការកែលម្អសុវត្ថិភាពស្បៀង និងការបញ្ចូលមីក្រូសារជាតិផ្សេងៗទៅក្នុងអាហារ

**គោលបំណងទី៤ :** កែលម្អបណ្តាញសុវត្ថិភាពសង្គម និងលើកកម្ពស់សមត្ថភាពរបស់ក្រុមគ្រួសារអសន្តិសុខស្បៀងក្នុងការដោះស្រាយហានិភ័យផ្សេងៗ នឹងជួយ**បង្កើនស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀង** ។

យើងអាចសម្រេចគោលដៅនេះតាមរយៈការធ្វើឱ្យមានវឌ្ឍនភាពលើវិស័យពីរ ដូចខាងក្រោម :

១. ការពង្រឹងបណ្តាញសុវត្ថិភាពសម្រាប់គ្រប់គ្រងគ្រោះធម្មជាតិ

២. ការបង្កើតបណ្តាញសុវត្ថិភាពសង្គមសម្រាប់ក្រុមជនងាយរងគ្រោះ

**គោលបំណងទី៥: កែលម្អបរិស្ថានគោលនយោបាយ និងស្ថាប័ន** ដើម្បីសម្រេចបានការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា។

យើងអាចសម្រេចគោលដៅនេះតាមរយៈការធ្វើឱ្យមានវឌ្ឍនភាពលើវិស័យបី ដូចខាងក្រោម :

១. ការពង្រឹងសមត្ថភាព និងការកែលម្អការសម្របសម្រួលសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ

២. ការបញ្ជ្រាប (ការបញ្ចូល)សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទៅក្នុងដំណើរការរៀបចំផែនការវិមជ្ឈការ

៣. ការកែលម្អការគ្រប់គ្រងព័ត៌មានពាក់ព័ន្ធនឹងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងការកំណត់គោលដៅអន្តរាគមន៍ ។

## ៤. ***ក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ២០០៨-២០១២: គោលបំណង និងសកម្មភាពជាអាទិភាព***

ផ្នែកនេះពិពណ៌នាអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភតាមគោលបំណងទាំងប្រាំ ។ នៅក្នុងគោលបំណងនីមួយៗមានបញ្ចូលការវិភាគយ៉ាងជាក់ច្បាស់អំពីស្ថានភាពនៃកង្វះអាហារូបត្ថម្ភ និងអសន្តិសុខស្បៀង តាមវិស័យជាក់ស្តែងនីមួយៗ ដែលចាត់ទុកដូចជាសន្និទានភាពសម្រាប់សកម្មភាពជាអាទិភាពដាច់ដោយឡែកនានាសម្រាប់កែលម្អសន្តិសុខស្បៀងនិងអាហារូបត្ថម្ភសម្រាប់ប្រជាពលរដ្ឋកម្ពុជា ។ ការពិពណ៌នាពីគោលបំណងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងសកម្មភាពជាអាទិភាពនានាត្រូវបានដកស្រង់ចេញពីឯកសារយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ឆ្នាំ២០០៥ ដែលត្រូវបានរៀបចំឡើងដោយមានការចូលរួមពីសមាជិកក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់ដាក់ជូនក្រសួងផែនការ ដើម្បីបញ្ចូលទៅក្នុងដំណើរការរៀបចំ ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ***។

### ៤.១. <u>ការបង្កើនភាពមានស្បៀង</u>

***គោលបំណងទី១:*** *ក្រុមគ្រួសារអសន្តិសុខស្បៀង**បង្កើនភាពមានស្បៀង**តាមរយៈផលិតកម្មកសិកម្ម និងបសុសត្វ និងតាមរយៈធនធានជលផល និងអនុផលព្រៃឈើ ។*

**ស្ថានភាពទូទៅ និងសន្និទានភាព**

គ្រួសារក្រីក្រ និងអសន្តិសុខស្បៀងនៅប្រទេសកម្ពុជាភាគច្រើន គឺគ្រួសារទាំងឡាយណាដែលធ្វើកសិកម្មទ្រង់ទ្រាយតូច ។ ពួកគាត់ខិតខំប្រឹងប្រែងផលិតស្បៀងឱ្យបានច្រើនតាមលទ្ធភាពដែលអាចធ្វើបានសម្រាប់បំពេញតម្រូវការ ។ សកម្មភាពផលិតស្បៀងរបស់ពួកគាត់រួមមាន: ការធ្វើស្រែចំការ ការចិញ្ចឹមសត្វ ការប្រមូលអនុផលព្រៃឈើ និងការនេសាទ។ ពួកគាត់ក៏ស្វែងរកប្រាក់ចំណូលតាមរយៈសកម្មភាពទាំងអស់នេះ ដើម្បីទិញស្បៀងដែលពួកគាត់មិនអាចផលិតបាន និងដើម្បីបំពេញតម្រូវការចាំបាច់ផ្សេងៗទៀត។ ស្របពេលដែលសកម្មភាពទាំងអស់

នេះគឺជាប្រភពយ៉ាងសំខាន់ក្នុងការផលិតស្បៀង និងរកប្រាក់ចំណូល ប្រជាពលរដ្ឋកម្ពុជានៅតាមជនបទកំពុងប្រឈមមុខនឹងផលិតភាពទាប និងកម្រិតហានិភ័យខ្ពស់ក្នុងការខិតខំប្រឹងប្រែងផលិតស្បៀង និងក្នុងការប្រមូលអនុផលព្រៃឈើ និងជលផល[៤៤] ។

គោលបំណងសន្តិសុខស្បៀង និងអាហារូបត្ថម្ភសង្កត់ធ្ងន់លើវិស័យបួនគឺ :

- ការកែលម្អផលិតភាពកសិកម្ម និងកសិកម្មចំរុះ កំណែទម្រង់ដីធ្លី និងការកំចាត់មីន
- ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ
- កំណែទម្រង់ជលផល
- កំណែទម្រង់ព្រៃឈើ ។

### ៤.១.១. ការកែលម្អផលិតភាព និងពិពិធកម្មកសិកម្ម

#### ស្ថានភាព និងសន្និទានភាព

ផលិតកម្មដំណាំ និងបសុសត្វគឺជាសកម្មភាពយ៉ាងសំខាន់ក្នុងការបំពេញតម្រូវការស្បៀង និងការរកប្រាក់ចំណូលរបស់គ្រួសារកម្ពុជានៅតាមជនបទ ។ ការធ្វើស្រែ-ចម្ការ (ការប្រកបរបរដាំដំណាំ) គឺជាសកម្មភាពផលិតស្បៀងដ៏សំខាន់ ជាពិសេសផ្តោតជាសំខាន់ទៅលើផលិតកម្មស្រូវ ព្រមទាំងដំណាំផ្សេងៗទៀតក្រៅពីស្រូវ និងដើមឈើកសិកម្ម ។ ដោយសារតែមិនមានដីគ្រប់គ្រាន់សម្រាប់ដាំដំណាំ ប្រជាកសិករតូចតាចពឹងផ្អែកជាសំខាន់លើការចិញ្ចឹមសត្វ ដែលជាប្រភពផ្តល់ស្បៀង និងប្រាក់ចំណូល ។ តាមធម្មតាបក្សីសត្វត្រូវបានកសិករ ចិញ្ចឹមសម្រាប់ធ្វើជាម្ហូបអាហារផង និងសម្រាប់រកចំណូលផង ហើយការចិញ្ចឹមជ្រូកគឺជាសកម្មភាពយ៉ាងសំខាន់សម្រាប់រកចំណូលប្រចាំគ្រួសារ ។ ចំណែកឯគោ-ក្របីត្រូវបានប្រជាកសិករចិញ្ចឹមសម្រាប់សន្សំប្រាក់ និងសម្រាប់ធ្វើជាកម្លាំងអូសទាញក្នុងការធ្វើស្រែ-ចម្ការ ហើយប្រជាកសិករក៏អាចរកប្រាក់ចំណូលបានពីកូនគោ-ក្របីដែលកើតមកដែរ[៤៥] ។

មានឧបសគ្គជាច្រើនបានរួមចំណែកធ្វើឱ្យមានផលិតភាពទាប និងហានិភ័យខ្ពស់ក្នុងផលិតកម្មដំណាំ ។ ឧបសគ្គទាំងនោះរួមមានៈ បរិមាណដីកសិកម្មដែលគ្រួសារនីមួយៗគ្រប់គ្រងមានទំហំតូច គឺថា ៤៨ភាគរយនៃគ្រួសារកសិករមានទំហំដីសរុបតូចជាង ១ហ.ត[៤៦] ហើយគ្រួសារភាគច្រើនមានដីសម្រាប់ដាំដំណាំត្រឹមតែ 0.៥ហ.ត ឬអាចតិចជាងនេះ ។ គ្រួសារដែលមានដីកសិកម្មតូចៗទាំងនេះកំពុងតែជួបនូវបញ្ហាអសន្តិសុខស្បៀងរ៉ាំរ៉ៃ ។ កសិករ

---

៤៤ របាយការណ៍វិភាគវិស័យកសិកម្មកម្ពុជា រៀបចំសម្រាប់អង្គការ AusAID ដោយក្រុមហ៊ុន Agrifood Consulting International/CamConsult ឆ្នាំ ២០០៦, កាត់បន្ថយអត្រាភាពក្រីក្រឱ្យបានពាក់កណ្តាល ត្រឹមឆ្នាំ ២០១៥: ការវាយតម្លៃលើភាពក្រីក្រនៅកម្ពុជា ដោយធនាគារពិភពលោក ឆ្នាំ ២០០៦ ឯកសារ សរសេរដោយ McKenney និង Tola ឆ្នាំ ២០០២ និងឯកសារ ស្តីពី ការប្រឈមមុខសរសេរដោយ Chan និង Acharya ឆ្នាំ ២០០២ វិទ្យាស្ថានធនធានអភិវឌ្ឍន៍កម្ពុជា ។

៤៥ របាយការណ៍វិភាគវិស័យកសិកម្មកម្ពុជា រៀបចំសម្រាប់អង្គការ AusAID ដោយក្រុមហ៊ុន Agrifood Consulting International/ CamConsult ឆ្នាំ ២០០៦, កាត់បន្ថយអត្រាភាពក្រីក្រឱ្យបានពាក់កណ្តាល ត្រឹមឆ្នាំ ២០១៥: ការវាយតម្លៃលើភាពក្រីក្រនៅកម្ពុជា ដោយធនាគារពិភពលោក ឆ្នាំ ២០០៤ (ដោយ Helmers, Gibson និង Wallgren )

៤៦ ស្ថិតិកសិកម្ម ឆ្នាំ ២០០៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ភាគច្រើននៅតែពុំមានកម្មសិទ្ធិដីកសិកម្មស្របច្បាប់  ទោះបីជាការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធបានដំណើរការល្អក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ ។

៨០ភាគរយនៃផ្ទៃដីសម្រាប់ដំណាំកសិកម្មជាតិ  ពឹងផ្អែកទាំងស្រុងលើទឹកភ្លៀងដែលធ្លាក់មិនទៀងទាត់ ហើយប្រជាកសិករមិនមានលទ្ធភាពក្នុងការដាំដំណាំនៅរដូវប្រាំង ។ លក្ខណៈសណ្ឋានដីមិនមានជីជាតិល្អដែលមានចំនួន៥០ភាគរយនៃផ្ទៃដីកសិកម្មជាតិ  ក៏ជាកត្តាធ្វើឱ្យការបង្កបង្កើនផលស្រូវមានកម្រិតផងដែរ។  នៅតំបន់វាលទំនាបដែលជាទីកន្លែងប្រជាពលរដ្ឋជនបទរស់នៅ ការធ្វើពិពិធកម្មដំណាំនៅមានកម្រិត ហើយប្រជាកសិករពឹងផ្អែកទៅលើការធ្វើស្រូវតែមួយមុខ ។ ចំណែកឯការធ្វើកសិកម្មនៅតំបន់ខ្ពង់រាបវិញ ការដាំដំណាំមានលក្ខណៈពិពិធកម្មជាង ប៉ុន្តែមានផលិតភាពទាប ហើយទទួលរងហានិភ័យដោយសារគ្រោះរាំងស្ងួត ព្រមទាំង ងាយរងគ្រោះដោយសារការទន្ទ្រានកាន់កាប់ដីធ្លី និងការកាប់បំផ្លាញព្រៃឈើ ។

កំណើនយ៉ាងឆាប់រហ័សនៃគ្រួសារនៅតាមជនបទ  ជាហេតុបណ្តាលឱ្យមានកង្វះផ្ទៃដីកសិកម្ម  នៅគ្រប់កម្រិត(នៅឆ្នាំ១៩៨៩ ប្រជាពលរដ្ឋស្ទើរតែគ្រប់គ្នាមានដីធ្វើស្រែ មកដល់ឆ្នាំ២០០៤នេះ ប្រជាពលរដ្ឋប្រហែលជាង ២០ភាគរយគ្មានដីកសិកម្ម  ហើយសកម្មភាពនេះនៅតែបន្ត)[៤៧] ។ នៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយសារមីន ប្រជាពលរដ្ឋនៅតែជួបប្រទះគ្រោះថ្នាក់ដោយសារមីន  ឬយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ  ហើយពួកគាត់មិនអាចប្រើប្រាស់ដី និងធនធានធម្មជាតិដទៃទៀតបាន។

នៅមានមូលហេតុមួយចំនួន  ដែលបណ្តាលឱ្យមានផលិតភាពទាប  និងហានិភ័យខ្ពស់នៅក្នុងផលិតកម្មស្បៀង ជាពិសេសក្នុងចំណោមកសិករក្រីក្រតូចតាច។ មូលហេតុទាំងនេះ រួមមានៈ

- កង្វះសម្ភារៈដែលមានគុណភាពខ្ពស់  និងតម្លៃសមរម្យដើម្បីកែលម្អកសិកម្ម  (គ្រាប់ពូជ  ជី ម៉ាស៊ីន និងប្រដាប់ប្រដាដទៃទៀត )
- កង្វះការទទួលបានសេវាកម្មសម្រាប់គាំទ្រកសិកម្ម  (ការផ្សព្វផ្សាយកសិកម្ម  ការអប់រំ  និងបណ្តុះបណ្តាលកសិករ ឥណទាន ការស្រាវជ្រាវកសិកម្ម)
- កង្វះព័ត៌មានអំពីគ្រោះមហន្តរាយ(ទិន្នន័យឧតុនិយម ការព្យាករណ៍កម្ពស់ទឹកភ្លៀង ការប្រកាសអាសន្នអំពីទឹកជំនន់ និងគ្រោះរាំងស្ងួត)
- កង្វះការកែច្នៃ និងបច្ចេកវិទ្យារក្សាទុកកសិផលដើម្បីកាត់បន្ថយការបាត់បង់ក្រោយពេលប្រមូលផល
- កង្វះខាតសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធទីផ្សារកសិកម្ម។

លើសពីនេះទៀត បសុវប្បកម្មក៏មានផលិតភាពទាប និងហានិភ័យខ្ពស់ផងដែរ។ ឧបសគ្គរួមមានៈ គ្រួសារនីមួយៗចិញ្ចឹមសត្វតិច  ហើយអត្រាស្លាប់របស់សត្វមានកម្រិតខ្ពស់  ដោយសារតែជំងឺ  និងកង្វះចំណីអាហារតាមរដូវ។

---

[៤៧] លទ្ធផលនៃការអង្កេតសេដ្ឋកិច្ច-សង្គម នៅក្នុងឯកសារវាយតម្លៃភាពក្រីក្រនៅកម្ពុជារបស់ធនាគារពិភពលោក ឆ្នាំ ២០០៦ ។ ស្ថិតិកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ( អត្រានៃភាពអត់ដីធ្លីមានការថយចុះបន្តិច គឺ ១៦ភាគរយ) ។

ឧបសគ្គជាទូទៅក្នុងការលើកកម្ពស់ផលិតកម្មកសិកម្ម និងបសុវប្បកម្មសម្រាប់កែលម្អសន្តិសុខស្បៀងគឺថា កសិករក្រីក្រតូចតាចពុំមានចំណេះដឹង និងជំនាញគ្រប់គ្រាន់ក្នុងការបង្កើនផលិតភាពដំណាំ និងកាត់បន្ថយហានិភ័យ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាផលិតកម្មដំណាំ និងបសុវប្បកម្មជឿនលឿន។ ទន្ទឹមនឹងនេះដែរ កសិករក្រីក្រ តូចៗ (រួមបញ្ចូលទាំងស្ត្រីក្រីក្រនៅតាមជនបទ) ពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបានសេវាកម្មផ្សព្វផ្សាយ និងបណ្តុះបណ្តាលអំពីកសិកម្ម និងបសុវប្បកម្ម ហើយពួកគាត់ពុំមានប្រភពថវិកា ឬពុំមានលទ្ធភាពទទួលបាន ឥណទានដើម្បីអនុវត្តបច្ចេកវិទ្យា ឬទិញសម្ភារៈល្អៗ ដូចជា: គ្រាប់ពូជដែលមានគុណភាពល្អ ជី និងថ្នាំព្យាបាល សត្វ។

**សកម្មភាពទូទៅជាអាទិភាពរួមមាន:**

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចាំបាច់គួរតែពង្រីកការបណ្តុះបណ្តាលអប់រំនិងផ្សព្វផ្សាយ កសិកម្ម និងបសុវប្បកម្ម និងពង្រីកសេវាកម្មផ្សេងៗទៀត ដូចជាៈការធ្វើពិសោធន៍ និងការធ្វើស្រែ បង្ហាញ ដោយផ្តោតជាសំខាន់លើកសិករតូចតាច ឱ្យបានទៅដល់គ្រប់ខេត្ត និងស្រុក ។
- បង្កើនសមត្ថភាពរបស់មន្ត្រីផ្សព្វផ្សាយដើម្បីធ្វើការជាមួយកសិករតូចតាច ក្នុងការបង្កើនផលិតភាព ដំណាំស្រូវនិងដំណាំក្រៅពីស្រូវ ធ្វើពិពិធកម្មដំណាំនិងកែលម្អប្រព័ន្ធកសិកម្មខ្ពង់រាប និងបសុវប្បកម្ម។
- កែលម្អការផ្គត់ផ្គង់ទឹកសម្រាប់ផលិតកម្មដំណាំនិងបសុវប្បកម្ម តាមរយៈការពង្រីកប្រព័ន្ធស្រោចស្រព និងការផ្គត់ផ្គង់ទឹកកសិកម្ម ដោយផ្តល់អាទិភាពដល់សហគមន៍អសន្តិសុខស្បៀង ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាណិជ្ជកម្ម និងកាំកុងត្រូលត្រូវតែបន្តរៀបចំបង្កើត ផ្សព្វផ្សាយ និងអនុវត្តបទបញ្ញត្តិទាំងឡាយស្តីពីសុវត្ថិភាពសម្ភារៈកសិកម្ម និងស្តង់ដារគុណភាព ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចាំបាច់គួរតែជំរុញ និងគាំទ្រដល់អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនឱ្យចាប់អារម្មណ៍ដល់ការបង្កើនការផ្តល់ឥណទានដែលមានការប្រាក់ទាប សម្រាប់ រយៈពេលវែងដល់គ្រួសារកសិករតូចតាច ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងអភិវឌ្ឍន៍ជនបទចាំបាច់គួរតែបញ្ជាក់ឱ្យបានច្បាស់ អំពីយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ និងការគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងសកម្មភាពរបស់ខ្លួន (ការគ្រប់គ្រងផលប៉ះពាល់នៃគ្រោះរាំងស្ងួតនិងទឹកជំនន់លើដំណាំ ការផ្ទុះឡើងនៃជំងឺសត្វ និង បច្ចេកទេសរក្សាទុកកសិផលក្រោយប្រមូលផល) ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចាំបាច់គួរតែបន្តបង្កើតប្រពន្ធ័ព្យាករណ៍ និងត្រួតពិនិត្យដំណាំ ថ្មីៗថែមទៀត ដោយផ្សារភ្ជាប់ផលិតកម្មដំណាំទៅនឹងបម្រែបម្រួលអាកាសធាតុ ។
- នាយកដ្ឋានឧតុនិយមនៃក្រសួងធនធានទឹក និងឧតុនិយម ចាំបាច់គួរតែស្វែងរកមូលនិធិ និងការគាំទ្រ ពីអង្គការឧតុនិយមពិភពលោករបស់អង្គការសហប្រជាជាតិ ឬដៃគូអភិវឌ្ឍន៍ដទៃទៀតដើម្បីរៀបចំ ឱ្យមានការព្យាករណ៍កម្ពស់ទឹកភ្លៀងនៅតាមមូលដ្ឋាន និងបង្កើតប្រព័ន្ធប្រកាសអាសន្នអំពីគ្រោះទឹក ជំនន់ និងគ្រោះរាំងស្ងួត ហើយធ្វើការផ្សព្វផ្សាយតាមវិទ្យុជាប្រចាំដល់កសិករ។ សេវាកម្មផ្សាយ សម្លេងគួរតែបញ្ចូលការអប់រំ ដើម្បីធ្វើឱ្យកសិករអាចធ្វើការស្វែងយល់ ហើយប្រើប្រាស់សេវាកម្មនេះ សម្រាប់កាត់បន្ថយហានិភ័យ ។

- ស្ថាប័នកម្ចាត់មីនទាំងឡាយចាំបាច់ត្រូវតែបន្ត និងបង្កើន (បើសិនជាអាច) ការលុបបំបាត់គ្រោះថ្នាក់ដោយសារមីនក្នុងដី និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ។
- ផ្តល់ដីដែលបានដោះមីនរួចហើយ ឱ្យទៅប្រជាពលរដ្ឋក្រីក្រនិងអសន្តិសុខស្បៀងនៅតាមជនបទ។

**សកម្មភាពអាទិភាពដើម្បីដោះស្រាយឧបសគ្គនានាពាក់ព័ន្ធនឹងកម្មសិទ្ធិដីធ្លីៈ**

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចាំបាច់ត្រូវបន្តដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី តាមរយៈគម្រោងរៀបចំដែនដីនិងរដ្ឋបាលដីធ្លី (LMAP) សម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ប្រជាពលរដ្ឋក្រីក្រ ក្នុងនោះរួមមានៈ ១-ការផ្តល់កម្មសិទ្ធិដីឯកជនសម្រាប់ដីកសិកម្ម ២-សម្បទានដីសង្គមកិច្ច ៣-ការផ្តល់ប័ណ្ណកម្មសិទ្ធិសមូហភាពសម្រាប់សហគមន៍ជនជាតិដើមភាគតិចក្នុង ការគ្រប់គ្រង និងប្រើប្រាស់ដីស្របតាមច្បាប់និងនីតិវិធីមានជាធរមាន ៤-ការគិតគូរអំពីសមភាពយេនឌ័រក្នុងដំណើរការចុះបញ្ជីដីធ្លី ។
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចាំបាច់គួរតែត្រួតពិនិត្យមើលវឌ្ឍនភាព និងផលប៉ះពាល់នៃគោលនយោបាយដីធ្លី ទៅលើគ្រួសារក្រីក្រ និងអសន្តិសុខស្បៀង ដោយសហការជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ហើយចាំបាច់ត្រូវចាត់វិធានការ ដើម្បីធានាថាតម្រូវការនៃក្រុមក្រីក្រ ទាំងនេះត្រូវបានដោះស្រាយជាក់ស្តែង ដោយគោលនយោបាយដីធ្លី។

**សកម្មភាពជាអាទិភាពដើម្បីដោះស្រាយឧបសគ្គក្នុងផលិតកម្មដំណាំៈ**

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូអភិវឌ្ឍន៍កសិកម្មចាំបាច់គួរតែរៀបចំ និងអនុវត្តអន្តរាគមន៍ដើម្បីឱ្យកសិករអសន្តិសុខស្បៀងអាចទទួលបាននូវសម្ភារៈកសិកម្មដែលមាន គុណភាពល្អ (តាមរយៈកម្មវិធីគាំទ្រសន្តិសុខស្បៀង ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក ២០០៦-២០១០) ។
- ពង្រីកការធ្វើប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ (SRI) ដែលមានការចំណាយតិច និងមិនប៉ះពាល់ដល់បរិស្ថាន សម្រាប់កសិករអសន្តិសុខស្បៀង ។
- បន្តពង្រីក និងពង្រឹងកម្មវិធីវិធានការចម្រុះគ្រប់គ្រងដំណាំ (IPM) ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូអភិវឌ្ឍន៍កសិកម្មចាំបាច់គួរតែបង្កើនអន្តរាគមន៍ក្នុងការអនុវត្តគម្រោងផលិតកម្មស្បៀង និងសួនបន្លែតាមផ្ទះ ដោយផ្តល់អាទិភាពទៅឱ្យអ្នកគ្មានដីធ្លី កសិករតូចតាច និងស្ត្រី។

**សកម្មភាពអាទិភាពដើម្បីដោះស្រាយឧបសគ្គក្នុងបសុវប្បកម្មៈ**

- ពង្រីកសេវាកម្មរបស់នាយកដ្ឋានផលិតកម្ម និងបសុពេទ្យាបាលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការអប់រំនិងបណ្តុះបណ្តាលកសិករអំពីបសុពេទ្យាបាល និងការធ្វើពិសោធន៍ផ្ទាល់នៅមូលដ្ឋាន ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើកសិករ ក្រីក្រតូចតាចនៅតាមជនបទ ។

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូចាំបាច់គួរតែគាំទ្រនិងជំរុញឱ្យកសិករតូចតាច ទទួលយក និងអនុវត្តការធ្វើវារីវប្បកម្មតាមគ្រួសារ ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចាំបាច់គួរតែរៀបចំបង្កើតប្រព័ន្ធប្រកាសអាសន្នពីការផ្ទុះឡើងនូវជំងឺសត្វ ដោយធ្វើការផ្សាយតាមវិទ្យុឱ្យបានដឹងជាសាធារណៈ ដែលក្នុងនោះ ត្រូវមានបញ្ចូលការផ្តល់យោបល់ ឬដំបូន្មានផ្សេងៗដល់កសិករអំពីវិធានការគ្រប់គ្រងនិងព្យាបាល ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល និងដៃគូពាក់ព័ន្ធដទៃទៀតចាំបាច់គួរតែរៀបចំផែនការនិងចាត់វិធានការត្រៀមបង្ការ សម្រាប់ពេលមានការផ្ទុះឡើងនិងការរីករាលដាលនៃជំងឺគ្រុនផ្តាសាយបក្សី និងផលប៉ះពាល់របស់វាទៅលើសន្តិសុខស្បៀង ។

### ៤.១.២ ការកែលម្អការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ

ការកែលម្អការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ មានសារសំខាន់យ៉ាងខ្លាំងសម្រាប់ការបង្កើនសន្តិសុខស្បៀង។ តាមទស្សនវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ មានបញ្ហាជាមូលដ្ឋានគ្រឹះពីរសម្រាប់ការគ្រប់គ្រងធនធានទឹក គឺៈ ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងធនធានទឹកសម្រាប់ការធ្វើស្រែ-ចម្ការ និងការនេសាទ ។ បញ្ហាពាក់ព័ន្ធនឹងការងារជលផលនឹងត្រូវបានលើកយកមកពិចារណា និងអត្ថាធិប្បាយនៅក្នុងផ្នែកស្តីអំពីកំណែទម្រង់ជលផល ។ នៅក្នុងផ្នែកនេះយើងផ្តោតជាសំខាន់ទៅលើការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ ។

#### ស្ថានភាព និងសន្និទានភាព

តម្រូវការប្រព័ន្ធធារាសាស្ត្រសម្រាប់បង្កើនផលិតផលដំណាំ និងកាត់បន្ថយការខូចខាតដំណាំត្រូវបានអត្ថាធិប្បាយពីខាងលើរួចមកហើយនៅក្នុងការពិភាក្សាអំពីឧបសគ្គនានាក្នុងការកែលម្អផលិតភាពកសិកម្ម ។ តាមទស្សនវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ចំណុចសំខាន់នៅទីនេះគឺថា ការវិនិយោគប្រព័ន្ធធារាសាស្ត្រចាំបាច់គួរតែមានផែនការច្បាស់លាស់ និងអនុវត្តឱ្យចំគោលដៅដើម្បីជួយដោយផ្ទាល់ដល់សហគមន៍អសន្តិសុខស្បៀងនៅក្នុងប្រទេស ។

តំបន់អាទិភាពដែលជួបបញ្ហាអសន្តិសុខស្បៀង រួមមានៈ តំបន់ដែលទទួលរងគ្រោះខ្លាំងជាងគេ ដោយសារគ្រោះរាំងស្ងួត (វាលទំនាប និងតំបន់ខ្ពង់រាប) និងតំបន់ដែលទទួលរងគ្រោះទឹកជំនន់ (វាលទំនាបលិចទឹកដែលធ្វើបានតែស្រូវវស្សា) ។ ក្រុមនៅក្នុងសង្គមមួយចំនួនទៀត រួមមានៈ ស្ត្រី និងកសិករតូចតាចគួរតែត្រូវបានផ្តល់អាទិភាពក្នុងការទទួលផលពីប្រព័ន្ធធារាសាស្ត្រ ។ ការងាររៀបចំកសាងប្រព័ន្ធធារាសាស្ត្រគួរតែត្រូវបានកំណត់រួមគ្នាជាមួយសហគមន៍ទាំងនេះ ហើយគួរតែសង្កត់ធ្ងន់លើគម្រោងការថ្នាក់សហគមន៍ ដោយផ្អែកលើការទាញយកទឹកភ្លៀង និងទឹកក្រោមដីមកប្រើប្រាស់ឱ្យបានប្រសើរដើម្បីជាជំនួយក្នុងការស្រោចស្រពដំណាំរដូវវស្សា ។

ធនធាន និងសមត្ថភាពរបស់ក្រសួងធនធានទឹក និងឧតុនិយម និងដៃគូនៅមានកម្រិតនៅឡើយ ។ ក្រសួងអភិវឌ្ឍន៍ជនបទ និងដៃគូដែលជាអាជ្ញាធរមូលដ្ឋានក៏មានការពាក់ព័ន្ធក្នុងការអនុវត្តគម្រោងប្រព័ន្ធធារាសាស្ត្រថ្នាក់សហគមន៍ផងដែរ ប៉ុន្តែធនធាន និងសមត្ថភាពពួកគាត់ក៏នៅមានកម្រិតដែរ ។ ប្រសិនបើមិនមានការវិនិយោគគ្រប់គ្រាន់ និងចំគោលដៅសម្រាប់ការអនុវត្តគម្រោងខ្នាតធំទេនោះ សហគមន៍អសន្តិសុខស្បៀងក៏ប្រហែលជាមិនអាចទទួលបានផលប្រយោជន៍ច្រើនពីការវិនិយោគប្រព័ន្ធធារាសាស្ត្រនេះដែរ ។

ក្នុងពេលថ្មីៗនេះ មានវឌ្ឍនភាពគួឱ្យកត់សំគាល់នៅក្នុងគោលនយោបាយធនធានទឹក ដោយក្នុងនោះ យុទ្ធសាស្ត្ររបស់ក្រសួងធនធានទឹកនិងឧតុនិយម ២០០៦-២០១០ និងយុទ្ធសាស្ត្រកសិកម្ម និងទឹក ២០០៦-២០១០ ត្រូវបានបញ្ចប់ជាស្ថាពរ ។

### សកម្មភាពអាទិភាព

ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចាំបាច់ត្រូវបង្កើនលទ្ធភាពដល់គ្រួសារតូចតាចក្នុងការទទួលបានការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រតាមរយៈ

- ការអនុវត្តយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក ២០០៦-២០១០
- ការអនុវត្តផែនការយុទ្ធសាស្ត្រ ២០០៦-២០១០ របស់ក្រសួងធនធានទឹក និងឧតុនិយម ដែលក្នុងយុទ្ធសាស្ត្រនេះមានវិធានការមានប្រយោជន៍ជាច្រើនសម្រាប់ការកែលម្អសន្តិសុខស្បៀង និងការបង្កើនកំណើនសេដ្ឋកិច្ច
- ការកំណត់តំបន់អសន្តិសុខស្បៀង និងក្រុមនានានៅក្នុងសង្គម (ស្ត្រី និងកសិករតូចតាច) នៅក្នុងការវិនិយោគប្រព័ន្ធធារាសាស្ត្រ
- ការអនុវត្តគម្រោងប្រព័ន្ធធារាសាស្ត្រ នៅក្នុងតំបន់ដែលរងគ្រោះខ្លាំងជាងគេដោយសារគ្រោះរាំងស្ងួត (វាលទំនាប និងតំបន់ខ្ពង់រាប) និងតំបន់ដែលទទួលរងគ្រោះទឹកជំនន់ (វាលទំនាបលិចទឹកដែលធ្វើបានតែស្រូវវស្សា)
- ការរៀបចំគម្រោងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួមពីសហគមន៍អសន្តិសុខស្បៀង
- ការកំណត់អាទិភាពប្រព័ន្ធធារាសាស្ត្រ សម្រាប់បំពេញបន្ថែមការស្រោចស្រពដំណាំរដូវវស្សានៅក្នុងតំបន់អសន្តិសុខស្បៀងដែលធ្វើការដាំដុះតែដំណាំរដូវវស្សាមួយមុខក្នុងមួយឆ្នាំ ដើម្បីកាត់បន្ថយការខូចខាតផលដំណាំដោយសារគ្រោះរាំងស្ងួត និងទឹកជំនន់ ។

## ៤.១.៣. ការជំរុញកំណែទម្រង់ជលផល

### ស្ថានភាព និងសន្និទានភាព

ត្រី (ទាំងនៅក្នុងស្រែ និងនៅក្នុងទន្លេឬសមុទ្រ) គឺជាប្រភពយ៉ាងសំខាន់នៃប្រូតេអ៊ីននៅក្នុងរបបអាហាររបស់ប្រជាពលរដ្ឋកម្ពុជានៅតាមជនបទ ព្រោះថា ត្រីផ្តល់ជាតិប្រូតេអ៊ីនរហូតដល់ទៅ ៦០-៧៥ ភាគរយនៃតម្រូវការប្រូតេអ៊ីនសរុប ។ ហេតុដូច្នេះហើយបានជាការនេសាទត្រីជាសកម្មភាពដ៏សំខាន់សម្រាប់សន្តិសុខស្បៀង ។ ពេលផុតរដូវនេសាទ ប្រជាពលរដ្ឋនៅតាមជនបទពឹងផ្អែកលើការទិញត្រីស្រស់ ឬត្រីកែច្នៃដែលបានមកពីជលផលធម្មជាតិ[៤៨] ។ ថ្វីត្បិតតែវារីវប្បកម្មកំពុងតែមានការរីកដុះដាលក៏ដោយ ក៏វាមិនទាន់ក្លាយជាប្រភពជំនួសមួយផ្សេងសម្រាប់ការផ្គត់ផ្គង់ត្រីនៅកម្ពុជានៅឡើយទេ ។

---

៤៨ ប្រវត្តិដើមនៃវិស័យជលផលមាននៅក្នុងឯកសារស្តីពីការពិត តួរលេខ និងបរិបទនៃការនេសាទនៅកម្ពុជា ដោយមជ្ឈមណ្ឌលមច្ឆាពិភពលោក និងមាននៅក្នុងឯកសារសរសេរដោយ McKenney និង Tola ឆ្នាំ ២០០២ ។

បើនិយាយអំពីការនេសាទត្រីធម្មជាតិ ប្រជាពលរដ្ឋនៅតាមតំបន់ជនបទភាគច្រើនបាន និងកំពុងប្រឈមមុខទៅនឹងការរំលោភយកនិងការហ៊ុំព័ទ្ធដោយខុសច្បាប់នូវតំបន់នេសាទរួមទាំងនេះ ហើយពួកគាត់ជួបប្រទះ និងឃើញដោយផ្ទាល់នូវការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ ដោយសារការធ្វើអាជីវកម្មនេសាទហួសហេតុពីមុនមក ដោយមិនមានការចាត់វិធានការផ្លូវច្បាប់ឱ្យមានប្រសិទ្ធភាព ។ តួអង្គសំខាន់នៅក្នុងការបំផ្លិចបំផ្លាញធនធានធម្មជាតិដែលជាសម្បត្តិរួម គឺក្រុមឈ្មួញឯកជនដែលធ្វើអាជីវកម្មខុសច្បាប់ ។ ការធ្វើអាជីវកម្មជលផលហួសហេតុ និងការបំផ្លាញជម្រកត្រីពងបានបណ្តាលឱ្យមានការថយចុះនូវបរិមាណត្រី និងពូជត្រីចម្រុះដែលជាហេតុធ្វើឱ្យផលត្រីមានការថយចុះ[៤៩] ។

នៅពេលថ្មីៗនេះ រដ្ឋាភិបាលបានលើកវិធានការគោលនយោបាយសំខាន់ៗមួយចំនួនដើម្បីដោះស្រាយបញ្ហាជលផលទាំងអស់នេះ[៥០] ។ នៅឆ្នាំ២០០៥ គោលនយោបាយជាតិថ្មីស្តីពីវិស័យជលផលត្រូវបានរៀបចំឡើង និងនៅឆ្នាំ២០០៦ ច្បាប់ស្តីពីជលផលត្រូវបានអនុម័ត និងប្រកាសឱ្យប្រើ ។ លើសពីនេះទៅទៀត ព្រះរាជក្រឹត្យស្តីអំពីការបង្កើតសហគមន៍នេសាទ និងអនុក្រឹតស្តីពីការគ្រប់គ្រងជលផលសហគមន៍ត្រូវបានអនុវត្ត ។ រដ្ឋាភិបាលបានបង្កើតឱ្យមានជលផលសហគមន៍តាមរយៈការកាត់ឡូតិ៍នេសាទពាណិជ្ជកម្មមួយចំនួនឱ្យទៅសហគមន៍[៥១] ។ គម្រោងភាពជាដៃគូរវាងរដ្ឋាភិបាលនិងម្ចាស់ជំនួយគឺ "**កម្រងគម្រោងអភិរក្ស និងអភិវឌ្ឍន៍បឹងទន្លេសាប (TSI)**" ដែលក្នុងនោះ សកម្មភាពប្រកបរបរចិញ្ចឹមជីវិតដោយការនេសាទត្រី និងការអភិរក្សត្រូវបានដាក់បញ្ចូលទៅក្នុងសមាសធាតុមួយស្តីពីការអភិរក្សនិងការប្រកបរបរចិញ្ចឹមជីវិតដោយចីរភាព ។ សមាសភាពដទៃទៀតនៃកម្រងគម្រោងអភិរក្ស និងអភិវឌ្ឍន៍បឹងទន្លេសាប រួមមាន: ការកាត់បន្ថយភាពក្រីក្រ ការប្រកបរបរចិញ្ចឹមជីវិតដោយចីរភាព និងការអភិរក្សធនធានធម្មជាតិ ដែលមានថវិកាសរុបចំនួន ១២០ លាន ដុល្លារ អាមេរិក[៥២] ។

សកម្មភាពជាអាទិភាពដើម្បីដោះស្រាយឧបសគ្គទាំងនេះផ្តោតជាសំខាន់ទៅលើការបង្កើត និងអនុវត្តច្បាប់ស្តីពីជលផល សិទ្ធិសហគមន៍ក្នុងការនេសាទ និងការកែលម្អការគ្រប់គ្រងជលផល ដោយរួមបញ្ចូលទាំងការជំរុញវារីវប្បកម្ម ។

**សកម្មភាពអាទិភាព:**

➢ រាជរដ្ឋាភិបាលកម្ពុជាត្រូវតែអនុវត្តគោលនយោបាយជាតិស្តីពីវិស័យជលផលឆ្នាំ២០០៥ដែលមានចក្ខុវិស័យ "ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍន៍ធនធានជលផលដោយចីរភាពដើម្បីរួមចំណែក

---

៤៩ សូមមើលឯកសារសរសេរដោយ McKenney និង Tola ឆ្នាំ ២០០២ ឯកសារស្តីពីទស្សនទានរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ទៅលើធនធានធម្មជាតិ និងជម្រើសនៃការប្រកបរបរចិញ្ចឹមជីវិត របស់កម្មវិធីសីលា ឆ្នាំ ២០០៥ ។ ការសិក្សានេះគឺជាការស្ទង់មតិនៅក្នុងឃុំស្ទើរតែទាំងអស់នៅតាមជនបទនៅក្នុងប្រទេសកម្ពុជា ហើយដោយមានបញ្ចូលបញ្ហាជលផលផងដែរ ។

៥០ គោលនយោបាយ និងបទបញ្ញត្តិថ្មីៗដែលពាក់ព័ន្ធនឹងជលផលមាននៅក្នុងវិបសាយរបស់ក្រុមការងារបច្ចេកទេសជលផល (http://www.twgf.org/index.php?page=home)

៥១ ជាគោលការណ៍ ក្នុងខណៈពេលដែលមានជំហានវឌ្ឍនភាពគួរឱ្យកត់សំគាល់ នៅមានបញ្ហាជាច្រើនក្នុងការអនុវត្ត និងការគ្រប់គ្រងជលផលនៅតាមសហគមន៍ ដូចដែលបានទទួលស្គាល់នៅក្នុងគោលនយោបាយវិស័យជលផល ឆ្នាំ ២០០៥ ។

៥២ សូមមើលវិបសាយ http://www.asiandevbank.org/Projects/Tonle_Sap/

ដល់ការធានាឱ្យមានសន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់ប្រជាពលរដ្ឋ និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងភាពរុងរឿងរបស់សង្គមជាតិ''[៥៣] ។

- រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចាំបាច់គួរតែកែលម្អការធ្វើផែនការ និងក្របខ័ណ្ឌច្បាប់ដើម្បីធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងជលផល ។ សកម្មភាពទាំងនេះ រួមមានៈ ការត្រួតពិនិត្យនិងការគ្រប់គ្រងជលផលរបស់សហគមន៍ និងការរៀបចំផែនការជាតិសម្រាប់ការនេសាទនៅតាមស្រែដោយមានការចូលរួមពីសហគមន៍ ។
- រដ្ឋបាលជលផល និងរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចាំបាច់គួរតែសហការគ្នាក្នុងការអភិរក្សតំបន់ត្រីពង ។
- ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងជលផលរបស់អង្គការមិនមែនរដ្ឋាភិបាល ចាំបាច់ត្រូវបង្កើនការចូលរួមរបស់កសិករតូចតាចក្នុងវិស័យវារីវប្បកម្ម។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចាំបាច់គួរតែប្រើប្រាស់ជំនាញឯកទេសនៃកម្មវិធីវិធានការចម្រុះគ្រប់គ្រងដំណាំ (IPM) សម្រាប់កែលម្អការគ្រប់គ្រងការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងជីកសិកម្មដើម្បីកាត់បន្ថយការបំផ្លាញជលផល ។
- រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ចាំបាច់គួរតែផ្តល់មូលនិធិ និងគាំទ្រយ៉ាងពេញទំហឹងដល់ការអនុវត្តសមាសភាពទាំងអស់ នៃកម្រងគម្រោងអភិរក្ស និងអភិវឌ្ឍន៍បឹងទន្លេសាប (TSI) ។

### ៤.១.៤. ការជំរុញកំណែទម្រង់ព្រៃឈើ

**ស្ថានភាព និងសន្និទានភាព**

ជានិច្ចកាល តំបន់ព្រៃឈើរួម គឺជាប្រភពផ្គត់ផ្គង់ស្បៀងបន្ថែម ផ្តល់ប្រាក់ចំណូល និងតម្រូវការជាមូលដ្ឋានផ្សេងៗទៀត សម្រាប់ប្រជាពលរដ្ឋកម្ពុជានៅតាមជនបទ។ សម្រាប់កសិករតូចតាច និងសហគមន៍ក្រីក្រដទៃទៀតក្រោយពេលខូចខាតផលដំណាំដែលបង្កដោយទឹកជំនន់ និងគ្រោះរាំងស្ងួត តំបន់ព្រៃឈើគឺជាប្រភពជម្រើសដ៏សំខាន់សម្រាប់ស្វែងរកស្បៀង និងផលិតផលដទៃទៀតសម្រាប់យកទៅលក់ដើម្បីរកប្រាក់ចំណូល ។ លើសពីនេះទៅទៀត គ្រួសារនៅតាមជនបទភាគច្រើនប្រើប្រាស់ផលិតផលព្រៃឈើសម្រាប់ដុតនិងសង់គេហដ្ឋាន។ បើនិយាយពីប្រព័ន្ធផលិតកម្មកសិកម្មរបស់ជនជាតិដើមភាគតិចនៅតំបន់ខ្ពង់រាប កសិកម្មគឺជាសកម្មភាពពឹងផ្អែកលើព្រៃឈើដែលគាំទ្រដល់ការប្រកបរបរចិញ្ចឹមជីវិត និងសន្តិសុខស្បៀង នៅតំបន់ខ្ពង់ រាប[៥៤] ។

ប្រជាពលរដ្ឋនៅតាមតំបន់ជនបទភាគច្រើនបាននិងកំពុងប្រឈមមុខទៅនឹងការរំលោភយក និងការហ៊ុំព័ទ្ធដោយខុសច្បាប់នូវតំបន់ព្រៃឈើរួមទាំងនេះ ហើយពួកគាត់បានជួបប្រទះនិងឃើញដោយផ្ទាល់នូវការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរនូវធនធានព្រៃឈើទាំងនេះ ដោយសារការធ្វើអាជីវកម្មហួសហេតុ ដោយមិនមានការចាត់វិធានការ

---

[៥៣] សេចក្តីថ្លែងការរបស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយវិស័យជលផលជាតិ ឆ្នាំ ២០០៥

[៥៤] ឯកសារសរសេរដោយ McKenney និង Tola ឆ្នាំ ២០០២, ឯកសាររបស់មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា ស្តីពីផលប្រយោជន៍ព្រៃឈើ និងការវិភាគសេដ្ឋកិច្ចនៃបំរែបំរួលព្រៃឈើធម្មជាតិ នៅក្នុងប្រទេសកម្ពុជា ទំព័រទី ៣៣ (សរសេរដោយ Hansen និង Neth នៅឆ្នាំ ២០០៥)

ផ្លូវច្បាប់ឱ្យមានប្រសិទ្ធភាព។ បើនិយាយពីការធ្វើកសិកម្មនៅតំបន់ខ្ពង់រាប ការបំផ្លិចបំផ្លាញព្រៃឈើ និងការទន្ទ្រានយកដីធ្លីនៅក្នុងតំបន់ព្រៃឈើបានធ្វើឱ្យខូចខាតដោយផ្ទាល់ទៅលើប្រព័ន្ធកសិកម្មតំបន់ខ្ពង់រាប ដែលត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធព្រៃឈើ ។ តួអង្គសំខាន់នៅក្នុងការបំផ្លិចបំផ្លាញធនធានធម្មជាតិដែលជាសម្បត្តិរួម គឺក្រុមឈ្មួញឯកជនដែលធ្វើអាជីវកម្មខុសច្បាប់[៥៥] ។ បញ្ហាមួយទៀត គឺការផាត់ប្រជាពលរដ្ឋក្រីក្រចេញពីគម្រោងសម្បទានព្រៃឈើពាណិជ្ជកម្មខ្នាតធំ និងកង្វះការអនុវត្តផែនការយុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើ ដែលក្នុងនោះ តាមច្បាប់ព្រៃឈើ គឺតម្រូវឱ្យមានការពិគ្រោះយោបល់ជាមួយសហគមន៍[៥៦] ។

នៅពេលថ្មីៗនេះ រដ្ឋាភិបាលបានលើកវិធានការគោលនយោបាយសំខាន់ៗមួយចំនួនដើម្បីដោះស្រាយបញ្ហាព្រៃឈើនិងបរិស្ថាន[៥៧] ។ វិធានការទាំងនេះមានគោលដៅពង្រឹងការអនុវត្តច្បាប់ព្រៃឈើ និងកែលម្អសម្បទានព្រៃឈើ និងការគ្រប់គ្រងព្រៃឈើសហគមន៍ ។

សកម្មភាពអាទិភាពដើម្បីដោះស្រាយឧបសគ្គ គឺផ្តោតទៅលើការអនុវត្តច្បាប់ព្រៃឈើ សិទ្ធិសហគមន៍ក្នុងការប្រើប្រាស់ព្រៃឈើ និងសកម្មភាពសក្តានុពលមួយចំនួនក្នុងការបញ្ចូលផលិតផលព្រៃឈើទៅក្នុងប្រព័ន្ធកសិ-ព្រៃឈើ ។

**សកម្មភាពជាអាទិភាព:**

- ក្រសួងបរិស្ថាន និងរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ នេសាទចាំបាច់គួរតែត្រួតពិនិត្យនិងទប់ស្កាត់ការប្រកបអាជីវកម្មកាប់ឈើខុសច្បាប់ឱ្យមានប្រសិទ្ធិភាពដើម្បីអភិរក្សធនធានព្រៃឈើ ។
- ក្រសួងបរិស្ថាន រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងសហគមន៍ព្រៃឈើចាំបាច់គួរតែចរចារអំពីសិទ្ធិរបស់សហគមន៍ក្នុងការប្រើប្រាស់ព្រៃឈើរដ្ឋ សម្រាប់ផលិតផលដែលមិនមែនជាឈើហ៊ុប (សម្រាប់ធ្វើជាអាហារ អុស-ធ្យូង សម្ភារៈសំណង់) និងសិទ្ធិរបស់សហគមន៍ ក្នុងការបរបាញ់សត្វធ្វើជាអាហារ ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចាំបាច់គួរតែពង្រីកព្រៃឈើសហគមន៍ ដោយអនុលោមតាមអនុក្រឹត្យស្តីពីព្រៃឈើសហគមន៍ ។
- រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គភាពផ្សព្វផ្សាយការងារព្រៃឈើ និងដៃគូរបស់ខ្លួនចាំបាច់គួរតែកែលម្អផលិតភាព និងការគ្រប់គ្រងព្រៃឈើសហគមន៍ ។

---

៥៥ ការវាយតម្លៃភាពក្រីក្ររបស់ធនាគារពិភពលោក ឆ្នាំ ២០០៦, ឯកសារសរសេរដោយ McKenney និង Tola ឆ្នាំ ២០០២ និងឯកសាររបស់កម្មវិធី សីលា និងអង្គការ Danidia ឆ្នាំ ២០០៥ ។

៥៦ ការវាយតម្លៃការពិគ្រោះយោបល់សហគមន៍ របស់ធនាគារពិភពលោក និង ឆ្នាំ ២០០៦ ដែលបានធ្វើឡើងក្នុងកំឡុងពេលរៀបចំផែនការយុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើនៅកម្ពុជា ។

៥៧ គោលនយោបាយ និងលិខិតបទដ្ឋានថ្មីៗ ដែលពាក់ព័ន្ធនឹងព្រៃឈើនិងបរិស្ថានមាននៅក្នុងវិបសាយរបស់ក្រុមការងារបច្ចេកទេសព្រៃឈើ និងបរិស្ថាន http://www.twgfe.org/Aboutus.php

- រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសម្បទានិកព្រៃឈើ ចាំបាច់គួរតែអនុវត្តផែនការយុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើ តាមរយៈការពិគ្រោះយោបល់ជាមួយសហគមន៍ដូចដែលមានចែងនៅក្នុងច្បាប់ព្រៃឈើ ។
- រដ្ឋបាលព្រៃឈើ និងនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចាំបាច់គួរតែធ្វើការសាកល្បងទាញយកផលិតផលព្រៃឈើពីប្រព័ន្ធកសិ-រុក្ខកម្ម (ផ្លែឈើព្រៃ គ្រាប់ផ្លែឈើ សសៃឈើ និងជ័រឈើ) តាមរយៈគម្រោងថ្នាក់សហគមន៍ ។
- អនុវត្តគម្រោងថ្នាក់សហគមន៍សម្រាប់ទាញយកអនុផលព្រៃឈើពីតំបន់កសិកម្មរួម និងព្រៃឈើសហគមន៍ ។

## ៤.២. ការបង្កើនភាពទទួលបានស្បៀង

***គោលបំណងទី២:*** *ក្រុមគ្រួសារអសន្តិសុខស្បៀង**បង្កើនភាពទទួលបានស្បៀង**តាមរយៈការបង្កើនប្រាក់ចំណូលក្នុងគ្រួសារ ។*

### ស្ថានភាពទូទៅ និងសន្និទានភាព

ការកែលម្អកត្តាកំណត់ផ្នែកសេដ្ឋកិច្ច នៃសន្តិសុខស្បៀង ពឹងផ្អែកយ៉ាងខ្លាំងលើការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងវិស័យឯកជនក្នុងការបង្កើនសមត្ថភាពប្រជាពលរដ្ឋអសន្តិសុខស្បៀង ដើម្បីដោះស្រាយបញ្ហាកង្វះស្បៀង និងកង្វះអាហារូបត្ថម្ភ ។ វិស័យឯកជនតម្រូវឱ្យមានការវិនិយោគថែមទៀតលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទីផ្សារ ដើម្បីឱ្យដំណើរការកាន់តែមានប្រសិទ្ធភាព និងប្រកបដោយសមធម៌ ។

ក្នុងន័យសេដ្ឋកិច្ច ប្រជាពលរដ្ឋក្រីក្រ និងអសន្តិសុខស្បៀងនៅតាមជនបទ ជាសមាសភាពចូលរួមយ៉ាងសំខាន់នៅក្នុងវិស័យឯកជន ជាពិសេសនៅក្នុងវិស័យមិនផ្លូវការ[៥៨] ។ ការកែលម្អការរកប្រាក់ចំណូលក្នុងគ្រួសារ និងឱកាសការងាររបស់ប្រជាពលរដ្ឋអសន្តិសុខស្បៀងគឺមានសារសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវសមភាពយេនឌ័រ ការលុបបាត់ភាពក្រីក្រ ឱកាសការងារនិងប្រាក់ចំណូលរបស់យុវជន (៣៧ភាគរយនៃប្រជាពលរដ្ឋសរុបមានអាយុចន្លោះពី ១០ ទៅ២៤ឆ្នាំ) និងការកាត់បន្ថយការធ្វើចំណាកស្រុកពីជនបទមកកាន់ទីក្រុង[៥៩] ។

ប្រភពប្រាក់ចំណូលសម្រាប់ទិញស្បៀងរួមមានៈផលិតកម្មដំណាំនិងបសុសត្វ និងការប្រមូលអនុផលព្រៃឈើនិងជលផល ។ ប៉ុន្តែទោះបីជាយ៉ាងណាក្តី ប្រាក់ចំណូលនៅមានកម្រិតនៅឡើយ ដូចដែលបានបញ្ជាក់ពីខាងលើ

---

៥៨ នៅកម្ពុជា ពាក្យថា "វិស័យមិនផ្លូវការ" ត្រូវបានប្រើប្រាស់ដើម្បីចង្អុលប្រាប់អំពីសកម្មភាពគ្មានការគាំពារ និងគ្មានរបៀបរៀបរយ នៅក្នុងវិស័យសេដ្ឋកិច្ច ។ ប្រទេសកម្ពុជាកំណត់លក្ខណៈពិសេសនៃពាក្យ "វិស័យមិនផ្លូវការ" ថា : ១-សកម្មភាពដែលមិនមានក្រុមហ៊ុននិងមិនមានអាស័យដ្ឋានទំនាក់ទំនង ។ ២-ជាវិស័យដែលប្រជាពលរដ្ឋធ្វើការដោយខ្លួនឯង ដូចជាៈអ្នកលក់ដូរតាមដងផ្លូវដែលមិនមានទិន្នន័យច្បាស់លាស់ ។ ៣-ជាវិស័យដែលប្រើប្រាស់កម្លាំងពលកម្មខ្លាំងក្នុងប្រតិបត្តិការ តែទទួលផលចំណេញបានលឿន ។ ៤-ជាកន្លែងដែលប្រើប្រាស់កម្លាំងមនុស្ស ឬសត្វ ហើយមានទីតាំងមិនច្បាស់លាស់ គ្មានច្បាប់ទំលាប់ គ្មានអាជ្ញាប័ណ្ណ គ្មានការធានារ៉ាប់រង និងមិនមានបង់ពន្ធ ។ (ឯកសារស្តីពីទិដ្ឋភាពទូទៅនៃសេដ្ឋកិច្ចមិនផ្លូវការនៅកម្ពុជា សរសេរដោយ Nuth នៅឆ្នាំ ២០០៥ , វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា- ភ្នំពេញ ) ។

៥៩ ឯកសារ គោលនយោបាយប្រជាពលរដ្ឋ ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាលកម្ពុជា

រួចមកហើយ ។ គេបានដឹងជាទូទៅថា ប្រាក់ចំណូលពីវិស័យសេដ្ឋកិច្ចផ្លូវការឬវិស័យសេដ្ឋកិច្ចសម័យទំនើប ជាពិសេសការងារនៅក្នុងសហគ្រាសកាត់ដេរធំៗ គឺជាប្រភពចំណូលយ៉ាងសំខាន់សម្រាប់ប្រជាពលរដ្ឋ ជាង ៣០០.០០០ នាក់ ជាពិសេសស្ត្រីក្រីក្រនៅតាមជនបទ ។ ជារឿយៗ ពុំសូវមានការទទួលស្គាល់អំពីតួនាទីយ៉ាងសំខាន់ៗនៃវិស័យមិនផ្លូវការ និងសហគ្រាសខ្នាតតូចនៅតាមគ្រួសារក្នុងការរកប្រាក់ចំណូលរបស់ប្រជាពលរដ្ឋកម្ពុជាក្រីក្រនិងអសន្តិសុខស្បៀងនៅតាមជនបទសម្រាប់ទិញស្បៀងអាហារ[៦០] ។

នៅឆ្នាំ២០០៤ នៅក្នុងចំណោមគ្វីនថាយពីរនៃគ្រួសារក្រីក្របំផុតនៅតាមជនបទ ភាគផលតម្លៃគិតជាប្រាក់នៃស្បៀងដែលផលិតនៅតាមផ្ទះគឺមានប្រមាណតែ៣៣-៣៦ភាគរយប៉ុណ្ណោះ ចំណែកភាគផលនៃតម្លៃជាប្រាក់នៃស្បៀងដែលទិញមកពីទីផ្សារមានរហូតដល់៦៤-៦៧ភាគរយ[៦១] ។ ម្យ៉ាងវិញទៀត តាមការសិក្សា[៦២] កាលពីពេលថ្មីៗនេះបានបង្ហាញឱ្យឃើញថា នៅក្នុងចំណោមគ្រួសារនៅតាមជនបទដែលប្រកបរបរកសិកម្ម ៤៦ភាគរយនៃរបបអាហារបានមកពីការទិញមកពីទីផ្សារ ៤៥ភាគរយបានមកពីផលិតកម្មផ្ទាល់ខ្លួន ចំណែកឯនៅសល់ពីនេះបានមកពីប្រភពដទៃទៀត ។ នេះបញ្ជាក់ឱ្យយើងដឹងថា ប្រជាពលរដ្ឋនៅតាមជនបទដែលប្រកបរបរកសិកម្មពឹងផ្អែកយ៉ាងខ្លាំងទៅលើស្បៀងអាហារទិញពីទីផ្សារសម្រាប់ធានាសន្តិសុខស្បៀងរបស់ពួកគាត់ហើយពួកគាត់ប្រឈមមុខនឹងភាពងាយរងគ្រោះដោយសារតែការប្រែប្រួលនៃតម្លៃស្បៀងអាហារ ។ តម្លៃស្បៀងបានកើនឡើងប្រមាណ ២៤ភាគរាយ ចាប់តាំងពីខែមករា ឆ្នាំ២០០៧ មកដល់ខែមករា ឆ្នាំ២០០៨[៦៣] ។ ដូច្នេះ ការកើនឡើងនៃតម្លៃស្បៀងក្នុងពេលបច្ចុប្បន្ននេះគឺជាបញ្ហាប្រឈមយ៉ាងខ្លាំងសម្រាប់ប្រជាពលរដ្ឋទាំងនៅក្នុងទីក្រុង និងទាំងនៅជនបទ ។

ការកើនឡើងនៃតម្លៃស្បៀងអាចជាបាតុភូតសាកលរយៈពេលវែង ដែលជាប់ទាក់ទងនឹងកំណើននៃតម្រូវការស្បៀង, តម្លៃខ្ពស់នៃប្រេងឥន្ធនៈនិងសម្ភារៈកសិកម្ម, ការប្រើប្រាស់ដីកសិកម្មសម្រាប់ផលិតជីវឥន្ធនៈ ឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុទៅលើផលិតកម្ម និងការកែងកេងចំណេញតម្លៃផ្សារទំនិញ ។ ទោះបីយ៉ាងនេះក្តី គោលនយោបាយ និងវិធានការដើម្បីទប់ស្កាត់ ឬសម្រាលឥទ្ធិពលនៃនិន្នាការពិភពលោកត្រូវបានលើកឡើងនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ[៦៤] ។

មធ្យោបាយមួយចំនួនសម្រាប់វាស់វែងអត្រាប្រេវ៉ាឡង់នៃកង្វះស្បៀងគឺផ្អែកលើប្រាក់ចំណូល និងការចំណាយលើការទិញស្បៀង ។ ចំណាត់ថ្នាក់នៃកង្វះស្បៀងដ៏ធ្ងន់ធ្ងរ គឺ “ភាពក្រីក្រស្បៀងអាហារកម្រិតធ្ងន់” ដែល

៦០ ឯកសារស្តីពីការងារក្រៅពីកសិកម្ម និងមិនមែនកសិកម្មៈ ទស្សនទានស្តីពីការបង្កើតការងារនៅកម្ពុជា សរសេរដោយ Nuth ឆ្នាំ ២០០៥ ; និង Acharya និង al. វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ និង ឯកសាររបស់ធនាគារពិភពលោកឆ្នាំ២០០៤ (ដោយ Helmers, Gibson និង Wallgren)

៦១ ការវាយតម្លៃភាពក្រីក្ររបស់ធនាគារពិភពលោក ឆ្នាំ ២០០៦ ទំព័រទី ៧៩ ។

៦២ ឯកសារវាយតម្លៃអសន្តិសុខស្បៀង របស់វិទ្យាស្ថានជាតិស្ថិតិ សហការជាមួយអង្គការ FAO និង EU ឆ្នាំ ២០០៧ ។

៦៣ សូមមើលរបាយការណ៍ស្តីពីសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) ឆ្នាំ ២០០៨ របស់វិទ្យាស្ថានជាតិស្ថិតិ ។ ជាពិសេសតម្លៃអង្ករមានការកើនឡើង ថែមទៀតក្នុងអំឡុងពេលបីខែដើមឆ្នាំ ២០០៨ ។ ក៏ប៉ុន្តែ រាជរដ្ឋាភិបាលបានចាត់វិធានការមួយចំនួនជាបន្ទាន់ដើម្បីទប់ស្កាត់ និងដោះស្រាយបញ្ហានៃ ការកើនឡើងនៃតម្លៃស្បៀង ។

៦៤ យុទ្ធសាស្ត្ររយៈពេលវែងដើម្បីទប់ស្កាត់ការកើនឡើងនៃតម្លៃស្បៀងផ្តោតជាសំខាន់លើការបង្កើនផលិតភាពកសិកម្ម ជាពិសេសសម្រាប់កសិករតូចតាច ហើយសកម្មភាពជាអទិភាពមាននៅក្នុងជំពូក ៤.១ ។ បណ្តាញសុវត្ថិភាពសម្រាប់ក្រុមគ្រួសារងាយរងគ្រោះនឹងមានពិភាក្សានៅក្នុងជំពូក ៤.៤ ដែលផ្តោតលើការបង្កើនកាលានុវត្តភាពការងាររកកម្រៃ និងហសគ្រាសខ្នាតតូចសម្រាប់ប្រជាពលរដ្ឋក្រីក្រ និងអសន្តិសុខស្បៀង ។

មានន័យថា ៖ គ្រួសារទាំងអស់នោះរកប្រាក់ចំណូលបានតិចជាងការចំណាយលើស្បៀងអាហារសម្រាប់បំពេញតម្រូវការថាមពលអាហារអប្បបរមា (MDER) គឺ ១៧១៥ គីឡូកាឡូរីក្នុងមនុស្សម្នាក់ក្នុងមួយថ្ងៃ ។ នៅកម្រិតថ្នាក់ជាតិ អត្រាប្រេវ៉ាឡង់នៃភាពក្រីក្រស្បៀងអាហារកម្រិតធ្ងន់ គឺមានប្រមាណ ២១.៤ភាគរយ នៃគ្រួសារទាំងអស់។ លើសពីនេះទៅទៀត អត្រាប្រេវ៉ាឡង់នេះមានការប្រែប្រួលយ៉ាងខ្លាំងពីខេត្តមួយទៅខេត្តមួយ និងពីក្រុមសង្គមមួយទៅក្រុមសង្គមមួយ ។ ជាឧទាហរណ៍ ប្រជាពលរដ្ឋដែលប្រកបរបរកសិកម្មមានអត្រានៃភាពក្រីក្រស្បៀង អាហារកម្រិតធ្ងន់ ច្រើនជាង ៦០ភាគរយនៃគ្រួសារទាំងអស់។

ក្រុមអ្នកដែលប្រមុខនឹងអសន្តិសុខស្បៀងមួយចំនួនធំទៀត គឺជាក្រុមដែលទទួលរងនូវ ''ភាពក្រីក្រស្បៀងអាហារ''។ ក្រុមនេះរកប្រាក់ចំណូលបានតិចជាងចំណាយលើការទិញស្បៀងអាហារសម្រាប់បំពេញតម្រូវ-ការថាមពលអាហារមធ្យម (ADER) គឺ ២១២០ គីឡូកាឡូរីក្នុងមនុស្សម្នាក់ក្នុងមួយថ្ងៃ[៦៥] ។ នៅកម្រិត ថ្នាក់ជាតិ អត្រាប្រេវ៉ាឡង់នៃភាពក្រីក្រស្បៀងប្រភេទនេះ គឺមាន ៥៧ភាគរយនៃគ្រួសារទាំងអស់។ ម្យ៉ាងវិញទៀត អត្រាប្រេវ៉ាឡង់នេះមានការប្រែប្រួលយ៉ាងខ្លាំងពីក្រុមមួយទៅក្រុមមួយ នៅកម្រិតថ្នាក់ក្រោមជាតិ ។ ជាឧទាហរណ៍ ស្ទើរតែ៧០ភាគរយនៃប្រជាពលរដ្ឋដែលប្រកបរបរកសិកម្មមានអត្រានៃភាពក្រីក្រស្បៀងអាហារ។

គោលបំណងនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ផ្តោតជាសំខាន់លើវិស័យបួន គឺ៖

- ការបង្កើនកាលានុវត្តភាពការងាររកកម្រៃសម្រាប់ក្រុមគ្រួសារក្រីក្រ និងអសន្តិសុខស្បៀង
- ការបង្កើនកាលានុវត្តភាពមីក្រូសហគ្រាស សម្រាប់ក្រុមគ្រួសារក្រីក្រ និងអសន្តិសុខស្បៀង
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទីផ្សារ
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដឹកជញ្ជូន

### ៤.២.១ ការបង្កើនកាលានុវត្តភាពការងាររកកម្រៃ

#### ស្ថានភាព និងសន្និទានភាព

សកម្មភាពសេដ្ឋកិច្ចយ៉ាងសាមញ្ញមួយ ដែលពាក់ព័ន្ធនឹងសន្តិសុខស្បៀងរបស់ប្រជាពលរដ្ឋក្រីក្រនៅតាមជនបទ គឺការធ្វើពលកម្មរកកម្រៃនៅក្នុងវិស័យមិនផ្លូវការ ។ គ្រួសារក្រីក្រនៅតាមជនបទភាគច្រើនមានសមាជិកធ្វើពលកម្មក្នុងវិស័យនេះដើម្បីស្វែងរកចំណូល ទៅតាមពេលវេលាផ្សេងៗគ្នា ជារៀងរាល់ឆ្នាំ។ សម្រាប់គ្រួសារក្រីក្របំផុត ការធ្វើការងារក្នុងវិស័យមិនផ្លូវការនេះ គឺជាប្រភពប្រាក់ចំណូលយ៉ាងសំខាន់ ហើយជួនកាលគឺជាប្រភពប្រាក់ចំណូលតែមួយគត់សម្រាប់ការទិញស្បៀងអាហារ ក្រោយពេលដែលពួកគាត់ប្រើប្រាស់អស់នូវស្បៀងដែលផលិតបាន ។ ប្រជាពលរដ្ឋដែលពឹងផ្អែកខ្លាំងលើការធ្វើពលកម្មក្នុងវិស័យមិនផ្លូវការដើម្បីរកកម្រៃសម្រាប់ទិញស្បៀងបរិភោគ គឺស្ថិតក្នុងចំណោមអ្នកងាយរងគ្រោះដោយសារបញ្ហាអសន្តិសុខស្បៀង។

យើងចាំបាច់គួរតែគូសបញ្ជាក់ឱ្យបានច្បាស់ថា ការធ្វើពលកម្មរកកម្រៃក្នុងវិស័យមិនផ្លូវការនេះ គឺជាសម្ព-ភាពក្នុងវិស័យឯកជន ។ ការដាក់វិស័យនេះនៅក្នុងបរិបទនៃការងាររកកម្រៃក្នុងវិស័យសេដ្ឋកិច្ចជាតិគឺមានសារ

---

[៦៥] តម្រូវការថាមពលប្រចាំថ្ងៃអប្បបរមាត្រូវបានកំណត់និយមន័យថាជាតម្រូវការថាមពលនៃរបបអាហារប្រចាំថ្ងៃដើម្បីទ្រទ្រង់រាងកាយឱ្យបានមាំមួនដោយមានការធ្វើលំហាត់ប្រាណក្នុងកម្រិតសមរម្យ ។

សំខាន់ណាស់ ពីព្រោះថា ក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាសរុប មានតែប្រមាណជា១៥ភាគរយប៉ុណ្ណោះដែលរកប្រាក់ចំណូលបានមកពីការងារទទួលបានប្រាក់កម្រៃទៀតទាត់។ វិស័យផ្លូវការទាំងនេះ រួមមានៈ វិស័យកាត់ដេរ វិស័យទេសចរណ៍ និងមន្ត្រីរាជការធ្វើការនៅក្នុងវិស័យសាធារណៈ។ កម្លាំងពលកម្មដែលនៅសេសសល់៨៥ភាគរយទៀតក្រៅពីការងារក្នុងកសិដ្ឋាន ប្រឹងប្រែងស្វែងរកការងារនៅក្នុងទីផ្សារការងារក្នុងវិស័យមិនផ្លូវការ ។

ការងារក្នុងវិស័យមិនផ្លូវការនៅតាមតំបន់ជនបទគឺភាគច្រើនពាក់ព័ន្ធទៅនឹងផលិតកម្មដំណាំ សំណង់ និងវិស័យសេវាកម្ម ដូចជាៈ ការដឹកជញ្ជូន និងការកែច្នៃផលិតផលកសិកម្ម។ ការងាររកកម្រៃក្នុងវិស័យមិនផ្លូវការនេះអាចជាប់ពាក់ព័ន្ធនឹងការធ្វើចំណាកស្រុករយៈពេលខ្លី ពីតំបន់ជនបទមួយទៅតំបន់ជនបទមួយទៀតឬពីតំបន់ជនបទទៅទីក្រុង ហើយរួមទាំងការធ្វើចំណាកស្រុកទៅក្រៅប្រទេសផងដែរ ជាពិសេសទៅប្រទេសថៃ និងប្រទេសវៀតណាម ។ ក្នុងចំណោមប្រជាពលរដ្ឋនៅទីក្រុង ការងាររកកម្រៃក្នុងវិស័យមិនផ្លូវការអាចជាប្រភពរកប្រាក់ចំណូលតែមួយគត់សម្រាប់ទិញស្បៀងអាហារដើម្បីបំពេញតម្រូវការ។

តាមធម្មតា ការងាររកកម្រៃក្នុងវិស័យមិនផ្លូវការនេះមានរយៈពេលខ្លី ហើយគ្មានសុវត្ថិភាពការងារទៀតផង ។ នៅតំបន់ជនបទ ប្រាក់ចំណូលពិតប្រាកដប្រចាំថ្ងៃសម្រាប់ការងារគ្មានជំនាញនៅក្នុងវិស័យនេះមានចំនួនតិច (ប្រហែល ៤០០០-៦០០០រៀល ឬ ១-២ ដុល្លារក្នុងមួយថ្ងៃ)[៦៦] ។ ហេតុដូច្នេះ ប្រសិនបើគេជួលឱ្យធ្វើការពេញមួយថ្ងៃ អ្នកធ្វើការម្នាក់ទទួលបានប្រាក់កម្រៃមិនគ្រប់គ្រាន់សម្រាប់ទិញស្បៀងអាហារពីរពេលឱ្យគ្រួសារមួយបានផង។ លើសពីនេះទៅទៀត អ្នកធ្វើពលកម្មរកកម្រៃក្នុងវិស័យមិនផ្លូវការនេះជានិច្ចកាលមិនត្រូវបានគេជួលជារៀងរាល់ថ្ងៃទេ ហើយទទួលបានប្រាក់កម្រៃទាប និងមិនទៀងទាត់។

សកម្មភាពការងារក្នុងវិស័យមិនផ្លូវការ ពុំមានច្បាប់ទម្លាប់ត្រឹមត្រូវ ហើយការយកចិត្តទុកដាក់របស់អាជ្ញាធរក៏នៅមានកម្រិតដែរ ។ អ្នកធ្វើពលកម្មរកកម្រៃក្នុងវិស័យនេះ ពុំទទួលបានការគាំពារពីផ្នែកច្បាប់ ដូចជាៈ កិច្ចសន្យាការងារ ស្ថានភាពការងារ ឬសិទ្ធិរបស់កម្មករ ជាដើម ។ ម្យ៉ាងវិញទៀត កម្មករទាំងនេះមានលទ្ធភាពតិចណាស់ក្នុងការពង្រឹងជំនាញការងាររបស់ខ្លួនហើយមិនមានប្រាក់ឧបត្ថម្ភនៅក្នុងកំឡុងពេលដែលអត់មានការងារធ្វើឡើយ។ ស្ត្រីដែលចូលរួមធ្វើការក្នុងវិស័យនេះជាមួយបុរស ប្រឈមមុខនឹងឧបសគ្គយេនឌ័រ រួមមានៈ ការទទួលបានប្រាក់កម្រៃទាប និងការពិបាកក្នុងការធ្វើបំលាស់ទីដើម្បីស្វែងរកការងារ។

សកម្មភាពអាទិភាពដើម្បីដោះស្រាយឧបសគ្គទាំងនេះ ផ្តោតលើការបង្កើនការយកចិត្តទុកដាក់ និងការទទួលស្គាល់នូវតួនាទីដ៏សំខាន់នៃការងាររកកម្រៃក្នុងវិស័យមិនផ្លូវការក្នុងប្រទេសកម្ពុជា និងជំរុញការគាំទ្រក្នុងការបង្កើនកាលានុវត្តភាពការងារសម្រាប់ប្រជាពលរដ្ឋក្រីក្រនិងអសន្តិសុខស្បៀង នៅតាមតំបន់ជនបទ ។

---

[៦៦] ការត្រួតពិនិត្យសេដ្ឋកិច្ច ឆ្នាំ ២០០៦ វ៉ុល ១០.៣ ដោយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កម្ពុជា។ អត្រាកម្រៃពលកម្មមាននៅក្នុងតារាង ៨ ។ (ការរកកម្រៃប្រចាំថ្ងៃជាមធ្យមរបស់កម្មករងាយរងគ្រោះ ក្នុងតម្លៃថេរ ១ ដុល្លារ = ៣៩១០ រៀល ក្នុងខែវិច្ឆិកា ឆ្នាំ ២០០០ ) ។ ការរកកម្រៃជាក់ស្តែងរបស់កសិករ គឺ ៤៥៤១ រៀល/ថ្ងៃ សម្រាប់ខែ ឧសភា ឆ្នាំ ២០០៦) ។

**សកម្មភាពជាអាទិភាពៈ**

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និងកីឡា ចាំបាច់គួរតែរៀបចំយុទ្ធសាស្ត្រសម្រាប់កែលម្អកាលានុវត្តភាពការងារ និងប្រាក់ចំណូល រួមមានៈ ពលកម្មរកកម្រៃក្នុងវិស័យមិនផ្លូវការ ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងអភិវឌ្ឍន៍ជនបទចាំបាច់គួរតែខិតខំធ្វើឱ្យប្រសើរឡើងនូវផលិតភាពកសិកម្ម បសុវប្បកម្មនិងផលិតផលសំខាន់ៗដែលបានពីធនធានរួម ដើម្បីបង្កើនតម្រូវការការងារនៅក្នុងវិស័យមិនផ្លូវការទាំងនេះ។ គួនាទីក្នុងការធ្វើឱ្យប្រសើរឡើងនូវផលិតភាពកសិកម្ម គួរតែត្រូវបានលើកយកមកពិចារណាក្នុងការធ្វើគម្រោងអន្តរាគមន៍នានា ។ ការបង្កើនសហប្រតិបត្តិការរវាងក្រសួងទាំងបីខាងលើ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាអាចជាមធ្យោបាយមួយសម្រាប់បង្កើនការ យល់ដឹងអំពីទំនាក់ទំនងទាំងនេះ ដើម្បីជំរុញកំណើនកាលានុវត្តភាពការងារនៅតំបន់ជនបទ ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាណិជ្ជកម្ម ក្រសួងផែនការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងកិច្ចការនារី ចាំបាច់គួរតែជួយជំរុញឱ្យប្រជាពលរដ្ឋក្រីក្រនៅជនបទ អាចមានលទ្ធភាពបង្កើនប្រាក់ចំណូលដែលបានមកពីពលកម្មរកកម្រៃក្នុងវិស័យមិនផ្លូវការ តាមរយៈការបង្កើនជំនាញការងារសម្រាប់ធ្វើការនៅក្នុងសហគ្រាសកែច្នៃកសិផល (រួមមានៈ សហគ្រាសខ្នាតតូច និងមធ្យម សម្បទានកសិ-សេដ្ឋកិច្ច និងរបៀបធ្វើកិច្ចសន្យាកសិ-ពាណិជ្ជកម្ម ។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និងកីឡាចាំបាច់គួរតែធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈនៅតំបន់ជនបទដើម្បីបង្កើនជំនាញការងារ និងសមត្ថភាពដល់ប្រជាពលរដ្ឋក្រីក្រនៅតាមជនបទ ។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកិច្ចការនារី និងក្រសួងពាណិជ្ជកម្ម និងអាជ្ញាធរខេត្ត-ក្រុង ចាំបាច់គួរតែពង្រីកការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ធ្វើការក្នុងសហគ្រាសខ្នាតតូចដល់ប្រជាពលរដ្ឋក្រីក្រនៅតាមជនបទ ដែលពឹងផ្អែកលើពលកម្មរកកម្រៃក្នុងវិស័យមិនផ្លូវការដើម្បីរកប្រាក់ចំណូល ។

## ៤.២.២. ការបង្កើនកាលានុវត្តភាពធុរកិច្ចសហគ្រាសខ្នាតតូច

**ស្ថានភាព និងសន្និទានភាព**

សហគ្រាសខ្នាតតូច និងមធ្យមគឺសំដៅលើគ្រឹះស្ថានទាំងឡាយណាដែលមានបុគ្គលិកតិចជាង១០០នាក់ ។ ដូច្នេះ យើងចាំបាច់គួរតែគូសបញ្ជាក់ឱ្យបានច្បាស់អំពីសារសំខាន់ចំពោះគ្រួសារអសន្តិសុខស្បៀងក្នុងការបង្កើត

សហគ្រាសខ្នាតតូចមិនផ្លូវការនៅតាមគ្រួសារ ។ សហគ្រាសខ្នាតតូចមិនផ្លូវការទាំងនេះ តាមធម្មតាគឺជាការវិនិយោគប្រើប្រាស់មូលធនតិច[៦៧] ហើយមានសមាជិកគ្រួសារម្នាក់ឬច្រើននាក់ធ្វើការនៅក្នុងសហគ្រាសប្រភេទនេះ ។ សហគ្រាសខ្នាតតូចក៏មានសារសំខាន់យ៉ាងខ្លាំងផងដែរ សម្រាប់គ្រួសារក្រីក្រនៅតាមជនបទក្នុងការកែលម្អសន្តិសុខស្បៀងនៅក្នុងគ្រួសារ ។

សហគ្រាសភាគច្រើនចាត់ចែងប្រតិបត្តិការដោយស្ត្រីនៅតាមភូមិជនបទ (ជាធម្មតានៅឆ្ងាយពីតំបន់ទីប្រជុំជនផ្សារ) ។ សហគ្រាសទាំងនេះគ្របដណ្តប់លើវិស័យ និងសកម្មភាពជាច្រើន រួមមានៈ ការធ្វើជំនួញផលិតផលកសិកម្ម ព្រៃឈើ ឬជលផល (ដូចជាៈការលក់នំផលិតពីអង្ករ ស្ករត្នោត ស្លឹកប្រក់ដំបូល អុស ធ្យូង និងត្រីកែច្នៃ) និង សំណង់ឬសិប្បកម្មខ្នាតតូច (ដូចជាៈការក្លូររាស់ ត្បាញក្រមា ផលិតសម្ភារៈកសិកម្ម និងការសង់ផ្ទះ) ។ ក្រៅពីនេះ សហគ្រាសខ្នាតតូចមួយភាគធំក៏ពាក់ព័ន្ធនឹងសកម្មភាពវិស័យសេវាកម្មផងដែរ ដូចជាៈ ការលក់ដូរផលិតផលរោងចក្រនៅតាមភូមិ សេវាកម្មដឹកជញ្ជូន ការព្យាបាលជំងឺតាមបែបបុរាណ ការលក់ដូរម្ហូបអាហារ សេវាកម្មជួសជុលនិងថែទាំ សំអាងការ អ៊ុតសក់ និងតន្ត្រី ។

សហគ្រាសខ្នាតតូចតាមគ្រួសារប្រឈមមុខនឹងឧបសគ្គជាច្រើន នៅក្នុងប្រតិបត្តិការរបស់ខ្លួន ។ សកម្មភាពរបស់សហគ្រាសខ្នាតតូចទាំងនេះពុំមានច្បាប់ទម្លាប់ត្រឹមត្រូវ ហើយមិនទាន់មានការយកចិត្តទុកដាក់ខ្ពស់ពីអាជ្ញាធរ ។ អ្នកប្រកបរបរក្នុងវិស័យមិនផ្លូវការនៃសហគ្រាសខ្នាតតូចនេះខ្វះខាតការគាំពារផ្នែកច្បាប់ គួយ៉ាងដូចជាៈ មិនមានកិច្ចសន្យា ឬមិនមានការគោរពសិទ្ធិក្នុងនាមជាប្រតិបត្តិករជំនួញ ហើយលើសពីនេះទៅទៀត គឺពុំមានសុវត្ថិភាពក្នុងការបណ្តាក់ទុនរបស់ខ្លួន ។ ដោយសារតែទទួលបានផលចំណេញទាប ហើយមានហានិភ័យខ្ពស់ ប្រតិបត្តិករភាគច្រើនងាយនឹងធ្លាក់ខ្លួនជាកូនបំណុលនៅក្នុងទីផ្សារឥណទានមិនផ្លូវការ ដែលតែងតែមានអត្រាការប្រាក់ខ្ពស់ ។ មានការគាំទ្រតិចតួចណាស់ដល់ប្រតិបត្តិករក្នុងការទទួលបានឥណទានដែលមានអត្រាការប្រាក់ទាប ហើយក៏ពុំសូវមានកម្មវិធីដើម្បីជួយពង្រឹងជំនាញសម្រាប់ប្រតិបត្តិការសហគ្រាសធុនតូចទាំងនេះ ។ លើសពីនេះទៀត ស្ត្រីដែលភាគច្រើនគឺជាម្ចាស់នៃអាជីវកម្មទាំងនេះប្រឈមមុខនឹងឧបសគ្គយេនឌ័រ ក្នុងការបង្កើនប្រាក់ចំណូលដែលបានមកពីសហគ្រាសខ្នាតតូចទាំងនេះ ។

ប្រាក់ចំណូលសុទ្ធពិតប្រាកដ ដែលបានមកពីសហគ្រាសខ្នាតតូចតាមគ្រួសារទាំងនេះ ស្ថិតក្នុងចន្លោះពី ៦០០០ រៀល ទៅ ៩០០០ រៀល ក្នុងមួយថ្ងៃ ។ ជាឧទាហរណ៍ នៅក្នុងខែឧសភា ឆ្នាំ២០០៦ ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកលក់បន្លែគឺ ៦៤៩២ រៀល អ្នករត់ស៊ីក្លូគឺ ៨៥៤៦ រៀល ហើយអ្នករត់មូតូឌុប គឺ៨៧៥០ រៀល[៦៨] ។

---

៦៧ ឯកសារស្តីពីការងារក្រៅពីកសិកម្ម និងមិនមែនកសិកម្មៈ ទស្សនទានស្តីពីការបង្កើតការងារនៅកម្ពុជា សរសេរដោយ Nuth ឆ្នាំ ២០០៥; និង Acharya និង al. វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ និង ឯកសាររបស់ធនាគារពិភពលោកឆ្នាំ២០០៤ (ដោយ Helmers, Gibson និង Wallgren)

៦៨ ការត្រួតពិនិត្យសេដ្ឋកិច្ច ឆ្នាំ ២០០៦ វុល ១០.៣ៈការរកកម្រៃប្រចាំថ្ងៃជាមធ្យមរបស់កម្មករងាយរងគ្រោះ (ក្នុងតម្លៃថេរ គឺថា ១ដុល្លារ = ៣៩១០រៀល ក្នុងខែវិច្ឆិកា ឆ្នាំ ២០០០) ដោយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កម្ពុជា ។

សកម្មភាពជាអាទិភាពដើម្បីដោះស្រាយឧបសគ្គទាំងនេះផ្តោតលើការបង្កើនការយកចិត្តទុកដាក់ និងការទទួលស្គាល់នូវតួនាទីដ៏សំខាន់នៃសហគ្រាសខ្នាតតូចតាមគ្រួសារ និងជំរុញការគាំទ្រ និងការអភិវឌ្ឍផ្នែកនេះនៅក្នុងវិស័យសហគ្រាសខ្នាតតូច និងមធ្យម ។

**សកម្មភាពអាទិភាព**

- ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងកិច្ចការនារី ចាំបាច់គួរតែត្រួតពិនិត្យឡើងវិញ និងបញ្ជាក់ឱ្យបានច្បាស់អំពីតួនាទី និងភារកិច្ចរបស់ក្រសួងនីមួយៗ ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍វិស័យសហគ្រាសខ្នាតតូចនៅតាមគ្រួសារ ព្រមទាំងបង្កើនការស្រាវជ្រាវ និងការត្រួតពិនិត្យលើវិស័យនេះដើម្បីឱ្យមានការគាំទ្រកាន់តែច្រើនឡើង ។
- ក្រសួងពាណិជ្ជកម្ម ចាំបាច់ត្រូវរៀបចំយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យសហគ្រាសខ្នាតតូច ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាណិជ្ជកម្ម ក្រសួងផែនការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងកិច្ចការនារី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចាំបាច់គួរតែជួយជំរុញការបង្កើនប្រាក់ចំណូលពីសហគ្រាសខ្នាតតូចក្នុងវិស័យកសិកម្ម តាមរយៈការកែច្នៃផលិតផលកសិកម្ម និងធនធានធម្មជាតិ ការផ្តល់ឥណទាន ការបណ្តុះបណ្តាលជំនាញ និងតាមរយៈការកែលម្អការផ្សព្វផ្សាយព័ត៌មាន និងការស្វែងរកទីផ្សារ ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាណិជ្ជកម្ម ក្រសួងផែនការ ក្រសួងកិច្ចការនារី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចាំបាច់គួរតែជួយជំរុញការបង្កើនប្រាក់ចំណូលពីវិស័យសហគ្រាសគ្រួសារខ្នាតតូចតាមគ្រួសារ និងសេវាកម្មបន្ទាប់បន្សំ តាមរយៈការផ្តល់ឥណទានសមស្រប ការបណ្តុះបណ្តាលជំនាញក្នុងការធ្វើជំនួញ និងតាមរយៈការកែលម្អការផ្សព្វផ្សាយព័ត៌មាន និងការស្វែងរកទីផ្សារ ។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកិច្ចការនារី ក្រសួងពាណិជ្ជកម្ម និងអាជ្ញាធរខេត្ត-ក្រុងចាំបាច់គួរតែពង្រីកការបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញសម្រាប់សហគ្រាសខ្នាតតូចដល់ប្រជា-ពលរដ្ឋក្រីក្រនៅទីប្រជុំជនខេត្ត-ក្រុង ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ ។

### ៤.២.៣. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទីផ្សារ

**ស្ថានភាព និងសន្និទានភាព**

នៅទីនេះ យើងផ្តោតជាសំខាន់ទៅលើទិដ្ឋភាពពិសេសដោយឡែកនៃការអភិវឌ្ឍសេដ្ឋកិច្ចក្នុងវិស័យឯកជនដែលពាក់ព័ន្ធនឹងបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។ ការលក់ដូររបស់ក្រុមគ្រួសារនៅជនបទទទួលបាន

ប្រាក់ចំណេញតិចដែលមួយផ្នែកដោយសារតែហេដ្ឋារចនាសម្ព័ន្ធទីផ្សារមិនទាន់មានការអភិវឌ្ឍបានល្អ ( ឧទាហរណ៍ៈ មិនមានអាគារផ្សារ កន្លែងស្តុកផលិតផល កន្លែងរក្សាទុកឱ្យត្រជាក់ ការផ្គត់ផ្គង់ទឹកនិងអគ្គិសនី) និងមួយផ្នែកទៀត ដោយសារកង្វះការទទួលបានសេវាកម្មព័ត៌មានទីផ្សារ ( ឧទាហរណ៍ៈ ព័ត៌មានអំពីតម្លៃទំនិញ តម្លៃវត្ថុធាតុដើម និង ទំហំពាណិជ្ជកម្មទំនិញ) ។ បញ្ហានេះប៉ះពាល់ដល់វិស័យកសិកម្ម និងសកម្មភាពទីផ្សារដទៃទៀតដែលប្រជាពលរដ្ឋ នៅជនបទចូលរួមពាក់ព័ន្ធ ក្នុងនេះរួមមានៈ ទីផ្សារសម្រាប់លក់ផលិតផលព្រៃឈើ និងជលផល ទីផ្សារពលកម្ម និង សហគ្រាសខ្នាតតូចតាមគ្រួសារ ។ សកម្មភាពជាអាទិភាពផ្តោតសំខាន់ទៅលើការ ពង្រីងវិស័យឯកជន។

**សកម្មភាពអាទិភាព**

- ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រសួងពាណិជ្ជកម្ម ចាំបាច់គួរតែកែលម្អហេដ្ឋារចនាសម្ព័ន្ធទីផ្សារនៅតាមតំបន់អសន្តិសុខស្បៀង រួម មានៈ ការកសាងអាគារផ្សារ កន្លែងស្តុកផលិតផល និងការផ្គត់ផ្គង់ទឹក និងអគ្គិសនី នៅតាមទីផ្សារ ដោយសហការជាមួយវិស័យឯកជន ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយចាំបាច់គួរតែបង្កើន ការផ្សព្វផ្សាយតាមវិទ្យុឱ្យបានទៀងទាត់អំពីផលិតផលកសិកម្ម បសុសត្វ ព្រៃឈើ និងជលផល និង អំពីទីផ្សារពលកម្ម ឱ្យបានទៅដល់គ្រួសារកសិករតូចតាច។

### ៤.២.៤. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដឹកជញ្ជូន

**ស្ថានភាព និងសន្និទានភាព**

ជាង៦០ភាគរយនៃបណ្តាញផ្លូវជាតិមានសភាពទ្រុឌទ្រោមដោយមិនមានការថែទាំឱ្យបានល្អ ហើយជា ពិសេសទៅទៀតនោះ នៅតាមតំបន់ជនបទពុំទាន់មានបណ្តាញផ្លូវគ្រប់គ្រាន់នៅឡើយ ។ លើសពីនេះទៀត ផ្លូវលំជនបទសម្រាប់តភ្ជាប់ពីភូមិនានាទៅផ្លូវធំឬផ្លូវជាតិក៏រឹតតែមានការខ្វះខាតថែមទៀត។ កង្វះខាតផ្លូវនិងហេដ្ឋា-រចនាសម្ព័ន្ធដឹកជញ្ជូនធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពរស់នៅរបស់សហគមន៍ក្រីក្រ និងអសន្តិសុខស្បៀង ។ ប្រជាពលរដ្ឋដែលខិតខំប្រឹងប្រែងតស៊ូផលិតស្បៀងនៅតាមកសិដ្ឋានតូចៗ ហើយដែលពឹងផ្អែកលើចំណូលដែលបាន មកពីការធ្វើពលកម្មរកកម្រៃក្នុងវិស័យមិនផ្លូវការដើម្បីទិញស្បៀងតែងតែជួបប្រទះបញ្ហាមួយ ចំនួនដូចជាៈ មាន កូនឈើច្រើន និងកង្វះខាតសេវាកម្មដឹកជញ្ជូន( កាលវិភាគមិនទៀងទាត់ហើយចំណាយខ្ពស់) ។

**សកម្មភាពជាអាទិភាព**

- ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងមហាផ្ទៃ ចាំបាច់គួរតែផ្តល់អាទិភាពទៅដល់ឃុំ-សង្កាត់ក្រីក្រ និង អសន្តិសុខស្បៀងក្នុងការធ្វើវិនិយោគទៅលើកែករលម្អផ្លូវលំនៅតាមជនបទ។

➢ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងមហាផ្ទៃចាំបាច់គួរតែស្វះស្វែងរកការឧបត្ថម្ភគាំទ្របន្ថែមទៀតពីរដ្ឋាភិបាលនិងពីដៃគូអភិវឌ្ឍន៍នានាសម្រាប់មូលនិធិឃុំ-សង្កាត់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់មានលទ្ធភាពកែលម្អផ្លូវលំជនបទនៅក្នុងសហគមន៍អសន្តិសុខស្បៀងឱ្យបានឆាប់រហ័ស។

➢ ចាំបាច់គួរតែបន្តការលើកកម្ពស់ និងការថែទាំផ្លូវលំនៅតាមជនបទ និងបណ្តាញផ្លូវជាតិ។ ការរៀបចំ និងការអនុវត្តគម្រោងអភិវឌ្ឍន៍បណ្តាញផ្លូវសំខាន់ដោយក្រសួងសាធារណការ និងដឹកជញ្ជូន និងដៃគូនានាគួរតែផ្តល់អាទិភាពដល់តំបន់អសន្តិសុខស្បៀងឱ្យស្របទឹងសកម្មភាពអាទិភាពជាតិផ្សេងៗទៀត។

## ៤.៣. ការកែលម្អការប្រើប្រាស់ និងការបឺតស្រូបស្បៀង

***គោលបំណងទី៣:*** *ក្រុមគ្រួសារអសន្តិសុខស្បៀង* ***កែលម្អការប្រើប្រាស់ និងការបឺតស្រូបស្បៀង*** *ដើម្បីកាត់បន្ថយបញ្ហាកង្វះអាហារូបត្ថម្ភ ជំងឺដង្កាត់ និងមរណភាព ជាពិសេសក្នុងចំណោមស្ត្រី និងកុមារ ។*

### ស្ថានភាពទូទៅ និងសន្និធានភាព

គោលបំណងនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ផ្តោតជាសំខាន់លើការកែលម្អស្ថានភាពសុខភាព និងអាហារូបត្ថម្ភរបស់ស្ត្រីនិងកុមារ។ ការវិភាគចំណុចសំខាន់មួយចំនួននៃស្ថានភាពសុខភាព និងអាហារូបត្ថម្ភ ត្រូវបានយកមកបង្ហាញជូនជាលម្អិតនៅក្នុងផ្នែក ២.១។

**គោលបំណងសន្តិសុខស្បៀង និងអាហារូបត្ថម្ភផ្តោតលើវិស័យបី គឺ:**

- ការកាត់បន្ថយកង្វះអាហារូបត្ថម្ភ និងមរណភាពរបស់មាតា និងកុមារ
- ការកែលម្អការផ្គត់ផ្គង់ទឹកស្អាត និងការអនុវត្តអនាម័យនៅតាមគ្រួសារ
- ការកែលម្អសុវត្ថិភាពស្បៀង និងការបញ្ចូលមីក្រូសារជាតិផ្សេងៗទៅក្នុងអាហារ

ការកែលម្អនៅក្នុងវិស័យទាំងនេះ មានសារសំខាន់យ៉ាងខ្លាំងក្នុងការសម្រេចបានវឌ្ឍនភាពនៃបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។ ការកែលម្អវិស័យទាំងនេះ ក៏មានសង្គតភាព (ភាពស្របគ្នា) ជាមួយផែនការយុទ្ធសាស្ត្រ ២០០៣-២០០៧ របស់ក្រសួងសុខាភិបាល ផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា ២០០៣-២០០៧ និងវិធានការទាំងឡាយដែលមាននៅក្នុងគោលនយោបាយជាតិប្រជាជន ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាល ។

យើងបានដឹងយ៉ាងច្បាស់អំពីឧបសគ្គនានាក្នុងការកែលម្អការប្រើប្រាស់ និងការបឺតស្រូបស្បៀងនៅក្នុងប្រទេសកម្ពុជា ហើយរាជរដ្ឋាភិបាលក៏បានកំណត់សកម្មភាពជាអាទិភាពជាក់ស្តែងជាច្រើន ដើម្បីដោះស្រាយឧបសគ្គទាំងនេះ ។ បញ្ហាប្រឈមសំខាន់ៗនៅទីនេះគឺតម្រូវឱ្យមានមូលនិធិគ្រប់គ្រាន់សម្រាប់ធ្វើការវិនិយោគ និងសម្រាប់ធ្វើការកសាងសមត្ថភាព ដើម្បីឱ្យរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍មានលទ្ធភាពគ្រប់គ្រាន់ក្នុងការដោះស្រាយ

តម្រូវការធំៗរបស់ប្រជាពលរដ្ឋក្រីក្រ និងអសន្តិសុខស្បៀង ។ ប្រសិនបើមានការផ្ដល់ធនធានគ្រប់គ្រាន់បញ្ហាជាច្រើនអាចដោះស្រាយបាន ហើយការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភក៏ទទួលបានជោគជ័យដែរ ។

ក្នុងឆ្នាំ២០០៧ ផែនការសំខាន់ៗពីរត្រូវបានយកមកពិនិត្យ និងធ្វើបច្ចុប្បន្នភាពឡើងវិញ ។ ផែនការទាំងពីរនេះ គឺផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ២០០៣-២០០៧ និងផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា ២០០៣-២០០៧។ គំនិតផ្ដួចផ្ដើមគោលនយោបាយថ្មីមួយទៀត គឺការបង្កើត **យុទ្ធសាស្ត្រជាតិស្ដីពីអាហារូបត្ថម្ភ** ដែលបច្ចុប្បន្ននេះ ក្រសួងសុខាភិបាលកំពុងតែដំណើរការរៀបចំដោយសហការជាមួយដៃគូអភិវឌ្ឍន៍ [អង្គការសុខភាពពិភពលោក (WHO) និងអង្គការយូនីសេហ្វ (UNICEF)] ។ ទន្ទឹមនឹងនេះ កម្មវិធីអាហារូបត្ថម្ភជាតិរបស់មជ្ឈមណ្ឌលគាំពារមាតា និងទារក នៃក្រសួងសុខាភិបាលក៏នឹងធ្វើការពិនិត្យកែសម្រួលឡើងវិញ តាមហ្នឹងដែរ។ ទំនាក់ទំនងរវាងយុទ្ធសាស្ត្រជាតិស្ដីពីអាហារូបត្ថម្ភ ២០០៨-២០១៥ របស់ក្រសួងសុខាភិបាល ផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា ២០០៨-២០១២ ថ្មី និងក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភចាំបាច់គួរតែធ្វើការពិនិត្យ និងកែសម្រួលឡើងវិញដើម្បីសម្រេចឱ្យបានជាអតិបរមានូវជោគជ័យរួម ។ ការពិភាក្សារវាងអ្នកពាក់ព័ន្ធក្នុងបញ្ហានេះអាចធ្វើការសម្របសម្រួលដោយក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលមានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងក្រសួងផែនការជាសហប្រធានហើយមានអង្គការកម្មវិធីស្បៀងអាហារពិភពលោក និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិជាអ្នកសម្របសម្រួលរួម។

### ៤.៣.១. ការកាត់បន្ថយកង្វះអាហារូបត្ថម្ភ និងមរណភាពរបស់មាតា និងកុមារ

ការកាត់បន្ថយកង្វះអាហារូបត្ថម្ភ និងអត្រាមរណភាពរបស់មាតា និងកុមារពាក់ព័ន្ធនឹងការអន្តរាគមន៍លើវិស័យបួនគឺៈ

- ការកាត់បន្ថយកង្វះថាមពលប្រូតេអ៊ីនរបស់កុមារ
- ការកាត់បន្ថយកង្វះមីក្រូសារជាតិរបស់មាតា និងកុមារ
- ការកាត់បន្ថយកង្វះអាហារូបត្ថម្ភរបស់មាតា
- ការកែលម្អសុខភាពស្ត្រី និងកុមារដើម្បីឱ្យមានអាហារូបត្ថម្ភល្អប្រសើរ ។

#### *៤.៣.១.១. ការកាត់បន្ថយកង្វះថាមពលប្រូតេអ៊ីនរបស់កុមារ*

**ស្ថានភាព និងសន្និទានភាព**

ការអនុវត្តរបៀបចិញ្ចឹមបីបាច់កុមារមិនបានសមស្របជាចំណែកយ៉ាងសំខាន់ ដែលបណ្ដាលឱ្យកុមារអាយុក្រោម៥ឆ្នាំប្រឈមមុខនឹងបញ្ហាកង្វះអាហាថាមពលប្រូតេអ៊ីន។ យោងតាមការធ្វើអង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០០៥ មានកុមារអាយុក្រោម៥ឆ្នាំ ប្រមាណ៣៧ភាគរយមានជំងឺក្រិន ៣៦ភាគរយខ្វះទម្ងន់ និង៧ភាគរយស្គមស្គាំង ។ មានកុមារតូចៗតែ៥៧ភាគរយប៉ុណ្ណោះ ដែលទទួលបានការចិញ្ចឹមបីបាច់បានសមស្របតាមយុទ្ធសាស្ត្រ

ទាំងបីនៃការចិញ្ចឹមទារកនិងកុមារតូច (IYCF)[៦៩] ។ យើងទទួលស្គាល់អំពីទំនាក់ទំនងរវាងកង្វះអាហារូបត្ថម្ភរបស់កុមារ និងមរណភាពរបស់កុមារ ហើយមានការប៉ាន់ស្មានថា កង្វះអាហារូបត្ថម្ភបានរួមចំណែករហូតដល់៥៤ភាគរយនៃមរណភាពរបស់កុមារ ។ ទោះបីជាស្ថានភាពអាហារូបត្ថម្ភរបស់កុមារជាលទ្ធផលរួមដែលស្តែងចេញពីភាពមានស្បៀង ភាពទទួលបានស្បៀង និងការប្រើប្រាស់និងការបឺតស្រូបស្បៀង ក៏ប៉ុន្តែវាហាក់បីដូចជាថា ការចិញ្ចឹមបីបាច់កុមារ និងទារកមិនបានត្រឹមត្រូវល្អ និងការឈឺញឹកញាប់ក្នុងកំឡុងពីរឆ្នាំដំបូង គឺជាកត្តាជះឥទ្ធិពលជាអវិជ្ជមានដល់ស្ថានភាពអាហារូបត្ថម្ភរបស់កុមារនៅកម្ពុជា ។

ការចាប់ផ្តើមបំបៅកូនដោយទឹកដោះម្តាយឱ្យបានឆាប់បន្ទាប់ពីសម្រាលរួច និងការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ក្នុងកំឡុងពេលប្រាំមួយខែដំបូង មានសារសំខាន់យ៉ាងខ្លាំង ដោយហេតុថា នៅក្នុងទឹកដោះម្តាយមានគ្រប់សារជាតិទាំងអស់ដែលទារកត្រូវការក្នុងកំឡុងពេលប្រាំមួយខែដំបូងនៃជីវិត ។ អង្គទីករដែលបានមកពីទឹកដោះម្តាយការពារមិនឱ្យកុមារមានជំងឺ និងមានបញ្ហាសុខភាពដោយសារទឹកមិនស្អាត ឬមានមេរោគ។ អត្រានៃការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខ មានការកើនឡើងគួរឱ្យកត់សំគាល់ នៅចន្លោះឆ្នាំ២០០០ និង ២០០៥[៧០] ប៉ុន្តែយើងត្រូវតែខិតខំប្រឹងប្រែងបន្តទៀតដើម្បីបង្កើនរយៈពេលនៃការបំបៅដោះក៏ដូចជាការបង្កើនការចាប់ផ្តើមបំបៅកូនដោយទឹកដោះម្តាយឱ្យបានឆាប់បន្ទាប់ពីសម្រាលរួច។

ទន្ទឹមនឹងនេះ យើងចាំបាច់គួរតែកែលម្អការផ្តល់អាហារបន្ថែមដល់ទារក និងកុមារតូចនៅក្នុងកំឡុងពេលកាត់បន្ថយការបំបៅដោះឬបញ្ឈប់ការបំបៅដោះដើម្បីឱ្យទារក និងកុមារតូចមានស្ថានភាពអាហារូបត្ថម្ភល្អប្រសើរ។ ការផ្តល់អាហារបន្ថែមដែលមានជីវជាតិ និងប្រូតេអ៊ីនខ្ពស់ដល់ទារក និងកុមារតូចទាមទារឱ្យមានការផ្លាស់ប្តូរឥរិយាបថ និងយកចិត្តទុកដាក់ខ្ពស់ពីមាតាបិតា ដើម្បីធ្វើយ៉ាងណាឱ្យកុមារទទួលបានអាហារមានជីវជាតិ និងប្រូតេអ៊ីនគ្រប់គ្រាន់ ។

**សកម្មភាពជាអាទិភាព**

ក្រសួងសុខាភិបាល និងក្រសួងផែនការ ចាំបាច់គួរតែជំរុញការអនុវត្តយុទ្ធសាស្ត្រចិញ្ចឹមបីបាច់ និងថែទាំទារក និងកុមារតូចដូចដែលមានចែងនៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីអាហារូបត្ថម្ភ ២០០៨-២០១៥ របស់ក្រសួងសុខាភិបាល និងផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា ២០០៨-២០១២ ថ្មី ដូចខាងក្រោម:

- បង្កើនអត្រានៃការបំបៅកូនដោយទឹកដោះម្តាយឱ្យបានឆាប់ក្នុងម៉ោងដំបូងបន្ទាប់ពីសម្រាលរួច ដោយរួមទាំងទឹកដោះដំបូង។
- បង្កើនការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ក្នុងរយៈពេលប្រាំមួយខែដំបូង។

---

៦៩ ការធ្វើអង្កេតប្រជាសាស្ត្រ និង សុខភាព ឆ្នាំ ២០០៥

៧០ ពី១១ភាគរយ នៅឆ្នាំ ២០០០ ទៅ៦០ភាគរយ នៅឆ្នាំ ២០០៥ ។ នេះបើតាមការធ្វើអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ ២០០៥ ។

- ជំរុញការផ្តល់អាហារបន្ថែមឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា ដល់ទារកចាប់ពីអាយុប្រាំមួយខែ ដោយនៅតែបន្តការបំបៅកូនដោយទឹកដោះម្តាយរហូតដល់កុមារមានអាយុយ៉ាងតិចពីរឆ្នាំ ។
- ពង្រីកការអនុវត្តកម្មវិធីបង្កើតមន្ទីរពេទ្យស្រឡាញ់ទារក និងសហគមន៍ស្រឡាញ់ទារក។
- អនុវត្តអនុក្រឹត្យឆ្នាំ ២០០៥ ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ។
- ផ្តល់ការគាំពារឱ្យសមស្របត្រឹមត្រូវដល់កុមារមានជំងឺនិងមានបញ្ហាកង្វះអាហារូបត្ថម្ភ ជាពិសេសត្រូវបញ្ជូនកុមារដែលមានបញ្ហាកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរទៅកាន់មន្ទីរពេទ្យឱ្យបានទាន់ពេលវេលា ដើម្បីធ្វើការស្តារនីតិសម្បទា។
- រៀបចំ និងជំរុញឱ្យមានផលិតផលអាហារបន្ថែមសមស្របសម្រាប់កុមារតូចៗ (ដោយមិនរាប់បញ្ចូលផលិតផលជំនួសទឹកដោះម្តាយ) ។
- ផ្តល់ថ្នាំទម្លាក់ព្រូនដល់កុមារមុនវ័យសិក្សា និងកុមារក្នុងវ័យសិក្សា។
- ជំរុញឱ្យមានការរៀបចំ និងអនុវត្តកម្មវិធីអាហារូបត្ថម្ភនៅសហគមន៍ដើម្បីកែលម្អចំណេះដឹងផ្នែកអាហារូបត្ថម្ភ និងវិធីសាស្ត្រក្នុងការអនុវត្ត។
- ក្រសួងអប់រំ យុវជន និងកីឡាចាំបាច់គួរតែបញ្ចូលការអប់រំស្តីពីអាហារូបត្ថម្ភទៅក្នុងកម្មវិធីសិក្សារបស់សាលា។
- ក្រសួងសុខាភិបាល ក្រសួងផែនការ ក្រសួងកិច្ចការនារី និងដៃគូនានាចាំបាច់គួរតែសហការធ្វើការអប់រំសហគមន៍ និងក្រុមមាតាអំពីអាហារូបត្ថម្ភ និងអំពីការបំបៅកូនដោយទឹកដោះម្តាយ និងការផ្តល់អាហារបន្ថែម ។

### *៤.៣.១.២. ការកាត់បន្ថយកង្វះអាហារូបត្ថម្ភមីក្រូសារជាតិក្នុងចំណោមស្ត្រី និងកុមារ*

**ស្ថានភាព និងសន្និទានភាព**

បញ្ហាកង្វះមីក្រូសារជាតិជាបច្ច័យមួយបណ្តាលឱ្យមានបញ្ហាកង្វះអាហារូបត្ថម្ភ ក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ និងក្នុងចំណោមស្ត្រីស្ថិតក្នុងវ័យបន្តពូជ ហើយក៏ជាបច្ច័យធ្វើឱ្យអត្រាមានជំងឺ និងអត្រាមរណភាពរបស់កុមារ និងម្តាយខ្ពស់ ។ កង្វះមីក្រូសារជាតិនេះរួមមានៈ កង្វះជាតិអ៊ីយ៉ូដ កង្វះជីវជាតិអា និងកង្វះជាតិ ដែក[៧១] ។

សកម្មភាពជាអាទិភាពដើម្បីដោះស្រាយឧបសគ្គទាំងនេះ ផ្តោតលើការអនុវត្តវិធានការទាំងឡាយដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហាកង្វះមីក្រូសារធាតុ ដូចដែលមានចែងនៅក្នុងកម្មវិធីអាហារូបត្ថម្ភជាតិនិងផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា។ វិធានការទាំងនេះរួមមានៈ ការផ្តល់បន្ថែមគ្រាប់ថ្នាំជីវជាតិអា ការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារសំខាន់ៗមួយចំនួន ដើម្បីជួយកែលម្អអាហារូបត្ថម្ភ។

---

[៧១] ការអង្កេតប្រជាសាស្ត្រនិងសុខភាព ឆ្នាំ ២០០៥

តាមការអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ២០០៥ ៧៣ភាគរយនៃក្រុមគ្រួសារកម្ពុជាទាំងអស់បរិភោគអំបិលអ៊ីយ៉ូដ ។ ដូច្នេះ ការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដទទួលបានលទ្ធផលល្អ ហើយយើងសង្ឃឹមថានឹងជួយរួមចំណែកដល់ការលុបបំបាត់បញ្ហាកង្វះជាតិអ៊ីយ៉ូដ ។ ក៏ប៉ុន្តែទោះ បីជាយ៉ាងនេះក្តី បញ្ហាស្លេកស្លាំងដោយសារកង្វះជាតិដែកក្នុងចំណោមស្ត្រី និងកុមារនៅតែមិនទាន់អាចដោះស្រាយឱ្យបានគ្រប់គ្រាន់ ដោយហេតុថាការផ្តល់បន្ថែមគ្រាប់ថ្នាំជាតិដែកដល់ស្ត្រីមានផ្ទៃពោះ និងស្ត្រីក្រោយពេលសម្រាលមិនទាន់បានគ្រប់គ្រាន់ ចំណែកឯការបញ្ចូលជាតិដែកទៅក្នុងអាហារសំខាន់ៗស្ថិតក្នុងកម្រិតសាក ល្បងនៅឡើយ ។

**សកម្មភាពជាអាទិភាព**

ក្រសួងសុខាភិបាល ក្រសួងផែនការ និងដៃគូអភិវឌ្ឍន៍ ចាំបាច់គួរតែអនុវត្តវិធានការអាហារូបត្ថម្ភផ្នែកមីក្រូសារជាតិដែលមានចែងនៅក្នុងកម្មវិធីអាហារូបត្ថម្ភជាតិរបស់ក្រសួងសុខាភិបាល និងផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា ២០០៨-២០១២ ដូចខាងក្រោមៈ

- ជំរុញលើកទឹកចិត្តឱ្យកុមារ និងស្ត្រី បរិភោគអាហារទាំងឡាយណាដែលសម្បូរដោយមីក្រូសារជាតិ ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូអភិវឌ្ឍន៍ ចាំបាច់គួរតែពង្រីកគម្រោងផលិតកម្មស្បៀងតាមគ្រួសារ (សួនបន្លែ បសុវប្បកម្ម និងវារីវប្បកម្ម) ដើម្បីជាប្រយោជន៍ដល់ការជួយកែលម្អស្ថានភាពអាហារូបត្ថម្ភ ។
- បង្កើនការផ្តល់គ្រាប់ថ្នាំជីវជាតិអា ដល់កុមារអាយុចន្លោះពី៦-៥៩ខែ និងស្ត្រីស្ថិតក្នុងកំឡុងពេល ៦ សប្តាហ៍ក្រោយពេលសម្រាល ។
- បង្កើនការផ្តល់បន្ថែមគ្រាប់ថ្នាំជាតិដែក និងជាតិហ្វូឡេដល់ស្ត្រីមានផ្ទៃពោះ និងស្ត្រីក្រោយពេលសម្រាល ។
- រៀបចំបង្កើត និងអនុវត្តកម្មវិធីជាតិសម្រាប់ការផ្តល់បន្ថែមគ្រាប់ថ្នាំជាតិដែកដល់កុមារមុនវ័យ សិក្សា និងស្ត្រីក្នុងវ័យបន្តពូជ ។
- ក្រសួងសុខាភិបាលចាំបាច់ត្រូវពង្រីកកម្មវិធីសម្រាប់ការផ្តល់បន្ថែមគ្រាប់ថ្នាំមីក្រូសារជាតិ (គ្រាប់ថ្នាំជីវជាតិអា ជាតិដែក និងមីក្រូសារជាតិចម្រុះ) ។
- ផ្តល់បន្ថែមគ្រាប់ថ្នាំមីក្រូសារជាតិ (ជាតិដែក) និងអាហារដែលមានបញ្ចូលជាតិដែកដល់សិស្សសាលាបឋមសិក្សា ។
- ផ្តល់ថ្នាំទម្លាក់ព្រូនដល់ស្ត្រីមានផ្ទៃពោះ និងស្ត្រីក្រោយពេលសម្រាល ។
- ជំរុញឱ្យមានការប្រើប្រាស់ជាសាកលនូវអំបិលអ៊ីយ៉ូដនៅតាមគ្រួសារ ដោយអនុវត្តអនុក្រឹត្យឆ្នាំ២០០៣ ស្តីអំពីការគ្រប់គ្រងការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដ ដែលតម្រូវឱ្យអំបិលទាំងអស់ត្រូវមាន ជាតិអ៊ីយ៉ូដ ។
- អនុគណៈកម្មាធិការលុបបំបាត់បញ្ហាស្លេកស្លាំងដោយសារកង្វះជាតិដែក នៃគណៈកម្មាធិការជាតិអាហារូបត្ថម្ភ ចាំបាច់គួរតែរៀបចំបង្កើត និងអនុវត្តកម្មវិធីជាតិស្តីពីការបញ្ចូលជាតិដែកទៅក្នុងអាហារសំខាន់ៗ (ដោយផ្អែកលើបទពិសោធន៍ដែលទទួលបានមកពីគម្រោងសាកល្បងដែលកំពុងតែដំណើរការ) ។

➢ បង្កើតអនុគណៈកម្មាធិការមួយស្ថិតនៅក្រោមគណៈកម្មាធិការជាតិអាហារូបត្ថម្ភ សម្រាប់ការបញ្ចូលជាតិដែកទៅក្នុងអាហារ ហើយត្រូវរៀបចំបង្កើត និងអនុវត្តគោលនយោបាយជាតិស្តីពីការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារ ដោយសហការជាមួយវិស័យឯកជន ។
➢ ចាំបាច់ត្រូវធានាថា គ្រប់កម្មវិធីផ្តល់អាហារបន្ថែមទាំងអស់ប្រើប្រាស់ផលិតផលអាហារដែលមានបញ្ចូលមីក្រូសារជាតិ ។

### *៤.៣.១.៣. ការកាត់បន្ថយបញ្ហាកង្វះអាហារូបត្ថម្ភរបស់មាតា*

**ស្ថានភាព និងសន្និធានភាព**

បញ្ហាកង្វះអាហារូបត្ថម្ភ ក្នុងចំណោមស្ត្រីជាប់ពាក់ព័ន្ធនឹងការធ្វើឱ្យអត្រាមរណភាពរបស់មាតាមានកម្រិតខ្ពស់នៅប្រទេសកម្ពុជា ។ យោងតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ២០០៥ ២០ភាគរយនៃស្ត្រីក្នុងវ័យបន្តពូជត្រូវបានចាត់បញ្ចូលថាមានបញ្ហាកង្វះថាមពលប្រូតេអ៊ីនរ៉ាំរ៉ៃ ឬ “ស្គមស្គាំង” ដោយមានសន្ទស្សន៍ម៉ាស់រាងកាយ (BMI) តូចជាង ១៨.៥គ.ក្រ/ម៣ ហើយ៦.២ភាគរយត្រូវបានចាត់បញ្ចូលថា មានលក្ខណៈ ស្គមស្គាំងខ្លាំង ។ ការកើតមិនគ្រប់ទម្ងន់នៃទារក (ទម្ងន់ទារកស្រាលជាង ២.៥ គ.ក្រ) មានប្រមាណ ១៥ភាគរយ ហើយជាកត្តាសំខាន់ដែលធ្វើឱ្យអត្រាមរណភាពរបស់កុមារមានកម្រិតខ្ពស់[៧២] ។

ស្ត្រីភាគច្រើនមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបានសេវាកម្មពន្យាកំណើត និងការធ្វើផែនការគ្រួសារ ។ សេវាកម្មថែទាំមុនពេលសម្រាលសម្រាប់ស្ត្រីមានគភ៌ចាំបាច់គួរតែធ្វើការពង្រីកឱ្យបានកាន់តែទូលំទូលាយ ។ មានតែ៦៩ភាគរយនៃស្ត្រីមានគភ៌ប៉ុណ្ណោះដែលបានទៅទទួលសេវាកម្មថែទាំមុនពេលសម្រាលក្នុងអំឡុងពេលមានគភ៌ ហើយភាគច្រើនទៅទទួលសេវាកម្មតែមួយដងប៉ុណ្ណោះ ទោះបីជាសេវាកម្មថែទាំមុនពេលសម្រាលមានការីកចម្រើនយ៉ាងខ្លាំងចាប់តាំងពីឆ្នាំ២០០០ (ដែលពេលនោះមានតែ៣៧ភាគរយនៃស្ត្រីមានគភ៌សរុបបានទៅទទួលសេវាកម្មថែទាំមុនពេលសម្រាល) ក៏ដោយ ។ ស្ត្រីមានគភ៌ និងស្ត្រីក្រោយពេលសម្រាលជាច្រើនមានបញ្ហាស្លេកស្លាំង ។ ដូច្នេះ យើងត្រូវទទួលស្គាល់អំពីភាពចាំបាច់ក្នុងការកែលម្អចំណេះដឹងរបស់ស្ត្រីមានគភ៌ និងស្ត្រីក្រោយពេលសម្រាលអំពីការបរិភោគអាហារឱ្យមានអាហារូបត្ថម្ភគ្រប់គ្រាន់ និងត្រឹមត្រូវល្អ ។

**សកម្មភាពជាអាទិភាព**

ក្រសួងសុខាភិបាល ក្រសួងផែនការ និងដៃគូអភិវឌ្ឍន៍ ចាំបាច់គួរតែអនុវត្ត និងពង្រីកវិធានការកាត់បន្ថយអត្រាមរណភាព និងអត្រាកង្វះអាហារូបត្ថម្ភរបស់មាតា ដូចដែលមានចែងក្នុងយុទ្ធសាស្ត្រជាតិស្តីពីអាហារូបត្ថម្ភ និងផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា ២០០៨-២០១២ ដូចខាងក្រោម:

---

[៧២] ការអង្កេតប្រជាសាស្ត្រនិងសុខភាព ឆ្នាំ ២០០៥

- អប់រំស្ត្រីគ្រប់វ័យ ជាពិសេសស្ត្រីមានគភ៌ និងស្ត្រីក្រោយពេលសម្រាល ឱ្យបានយល់ដឹងអំពីសារសំខាន់នៃការបរិភោគអាហារដែលមានអាហារូបត្ថម្ភគ្រប់គ្រាន់ ។
- បង្កើនការផ្តល់ជាតិដែក/ហ្វូឡេ ដល់ស្ត្រីមានគភ៌ និងស្ត្រីក្រោយពេលសម្រាល ។
- បង្កើនការផ្តល់បន្ថែមគ្រាប់ថ្នាំជីវជាតិអាដល់ស្ត្រីក្នុងកំឡុងពេលប្រាំមួយខែក្រោយពេលសម្រាល ។
- កាត់បន្ថយអត្រាកើតមិនគ្រប់ទម្ងន់នៃទារក តាមរយៈការកែលម្អអាហារូបត្ថម្ភសម្រាប់មាតា ។
- ក្រសួងសុខាភិបាលនិងដៃគូអភិវឌ្ឍន៍ចាំបាច់គួរតែជួយជំរុញឱ្យស្ត្រីមានលទ្ធភាពកាន់តែប្រសើរក្នុងការទទួលបានសេវាកម្មសម្រាប់ការធ្វើផែនការគ្រួសារ រួមមានៈ សេវាកម្មពន្យាកំណើត និងការអប់រំ ឬការប្រឹក្សាយោបល់ ។
- ក្រសួងសុខាភិបាលចាំបាច់គួរតែពង្រីកសេវាកម្មថែទាំមុនពេលសម្រាលសម្រាប់ស្ត្រី តាមរយៈ កម្មវិធីអាហារូបត្ថម្ភជាតិ និងជំរុញឱ្យមានការពង្រីកសេវាកម្មថែទាំសុខភាពក្នុងចំណោមអ្នកផ្តល់សេវាកម្មថែទាំទូទៅ ។

### ៤.៣.១.៤. ការកែលម្អសុខភាពស្ត្រី និងកុមារដើម្បីឱ្យមានអាហារូបត្ថម្ភល្អប្រសើរ

**ស្ថានភាព និងសន្និទានភាព**

របៀបមួយចំនួនក្នុងការថែទាំសុខភាពរបស់មាតា និងទារកជាបច្ច័យធ្វើឱ្យអត្រានៃបញ្ហាកង្វះអាហារូបត្ថម្ភ និងអត្រាមានជំងឺរបស់កុមារមានកម្រិតខ្ពស់ ដែលក្នុងនោះរួមមានៈ ជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរ ជំងឺរាគរូស ការឆ្លងបរាសិតពោះវៀន និងការរៀបចំអាហារដោយគ្មានអនាម័យ ។

ការចំណាយខ្ពស់ទៅលើសេវាកម្មថែទាំសុខភាពដែលមានគុណភាពទាប ជាកត្តារាំងស្ទះដល់ប្រជាពលរដ្ឋក្រីក្រក្នុងការប្រើប្រាស់សេវាកម្មនេះ ។ ការចំណាយលើការថែទាំសុខភាពដែលមិនបានគ្រោងទុកជាហេតុបណ្តាលឱ្យគ្រួសារក្រីក្រមួយចំនួនជំពាក់បំណុលគេ ហើយបង្ខំចិត្តលក់អចលនទ្រព្យ ដូចជាៈដីធ្លីជាដើម ដែលជាលទ្ធផលពួកគាត់ប្រឈមមុខនឹងអសន្តិសុខស្បៀងរ៉ាំរ៉ៃ ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ យើងចាំបាច់គួរតែរៀបចំឱ្យមានមូលនិធិសមធម៌សុខភាព និងគម្រោងធានារ៉ាប់រងសុខភាពសម្រាប់ប្រជាពលរដ្ឋក្រីក្រ ។ បញ្ហានេះនឹងត្រូវបានយកមកពិភាក្សាដោះស្រាយនៅក្នុងផ្នែក ៤.៤ នៃឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ។

ទន្ទឹមនឹងនេះ យើងចាំបាច់គួរតែរៀបចំបង្កើតឱ្យមានស្តង់ដារផលិតផល និងសេវាកម្មឱ្យបានច្បាស់លាស់សម្រាប់វិស័យវេជ្ជសាស្ត្រឯកជន និងឧស្សាហកម្មឱសថ ហើយត្រូវអនុវត្តស្តង់ដារទាំងអស់នោះឱ្យបានតឹងរឹង ។ កង្វះខាតនៅក្នុងវិស័យទាំងនេះជាចំណែកធ្វើឱ្យអត្រាកង្វះអាហារូបត្ថម្ភ និងអត្រាមរណភាពមានការកើនឡើង ។ បញ្ហានេះត្រូវបានទទួលស្គាល់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ២០០៣-២០០៧ របស់ក្រសួងសុខាភិបាល ។

សកម្មភាពជាអាទិភាពដើម្បីជំនះឧបសគ្គទាំងនេះផ្តោតលើការគាំទ្រសេវាកម្ម ដើម្បីឱ្យមាតាមានការយល់ដឹង និងអនុវត្តបានកាន់តែប្រសើរអំពីរបៀបថែទាំសុខភាពកុមារ អាហារូបត្ថម្ភ និងអនាម័យ ហើយក៏ផ្តោតផងដែរលើសេវាកម្មថែទាំសុខភាព និងសុវត្ថិភាពស្បៀង ។

**សកម្មភាពជាអាទិភាព**

- បន្តអនុវត្តផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ២០០៣-២០០៧ របស់ក្រសួងសុខាភិបាលដើម្បីជំរុញឱ្យមានសេវាកម្មថែទាំសុខភាពប្រកបដោយគុណភាព និងមានតម្លៃសមរម្យសម្រាប់ប្រជាពលរដ្ឋក្រីក្រនៅតាមជនបទ ផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសដល់អ្នកផ្តល់សេវាកម្មថែទាំសុខភាព និងដើម្បីពង្រឹងការតាមដាននិងការអនុវត្តបទបញ្ញត្តិនានាពាក់ព័ន្ធនឹងសេវាកម្មថែទាំសុខភាពសាធារណៈ និងឯកជន។
- ក្រសួងសុខាភិបាល និងអ្នកដែលពាក់ព័ន្ធចាំបាច់គួរតែធ្វើការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាល នៅគ្រប់ខេត្ត-ក្រុងទាំងអស់អំពីសំនុំសកម្មភាពអប្បបរមា ម៉ូឌុលទី១០ (ស្តីពីអាហារូបត្ថម្ភ) ។
- ក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍ចាំបាច់គួរតែបន្តនិងពង្រីកកម្មវិធីសម្រាប់កែលម្អការអនុវត្តរបៀបថែទាំសុខភាពមាតា និងទារក។
- ក្រសួងអប់រំ យុវជន និងកីឡាចាំបាច់គួរតែបន្ត និងពង្រីកការអប់រំអំពីការថែទាំសុខភាពមាតា និងទារក ដោយបញ្ចូលឱ្យទៅជាសមាសភាពមួយនៃការអប់រំអំពីអាហារូបត្ថម្ភដែលមាននៅក្នុងកម្មវិធីសិក្សាតាមសាលានានា ។
- ក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡាចាំបាច់គួរតែផ្តល់ការគាំទ្រដល់ការអប់រំ និងប្រឹក្សាយោបល់អំពីសុខភាពមាតា និងទារក នៅថ្នាក់សហគមន៍ និងក្នុងចំណោមក្រុមមាតា។
- ក្រសួងសុខាភិបាល ក្រសួងពាណិជ្ជកម្ម និងកាំកុងត្រូលចាំបាច់គួរតែរៀបចំឱ្យមាន និងអនុវត្តឱ្យបានទូលំទូលាយ នូវស្តង់ដារគុណភាព និងសុវត្ថិភាព សម្រាប់ឱសថ ហើយចាំបាច់ត្រូវពង្រឹង ការតាមដាន និងការអនុវត្តបទបញ្ញត្តិនានាពាក់ព័ន្ធនឹងសេវាកម្មថែទាំសុខភាពវិស័យឯកជនដើម្បីជំរុញលើកទឹកចិត្តឱ្យមានសេវាកម្មថែទាំសុខភាពប្រកបដោយគុណភាពខ្ពស់ និងមានតម្លៃសមរម្យជាពិសេសសម្រាប់ប្រជាពលរដ្ឋក្រីក្រនៅតាមជនបទ។

### ៤.៣.២. ការកែលម្អការផ្គត់ផ្គង់ទឹកស្អាតនៅតាមមូលដ្ឋាន និងរបៀបអនុវត្តអនាម័យ

ប្រជាពលរដ្ឋនៅក្នុងភូមិភាគច្រើនមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបានប្រភពទឹកដែលមានសុវត្ថិភាព និងក្នុងការប្រើបាស់បង្គន់អនាម័យ ។ ស្ថានភាពបែបនេះមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយការប្រើប្រាស់ និងការបឺតស្រូបស្បៀង ហើយជាឧបសគ្គយ៉ាងសំខាន់ក្នុងការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា។

យោងតាមស្ថិតិជាតិ មានតែ៤២ភាគរយនៃគ្រួសារជនបទមានលទ្ធភាពទទួលបានទឹកស្អាតសម្រាប់ប្រើប្រាស់។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សាថ្មី១បានរកឃើញថា ពុំមានការកំណត់ច្បាស់លាស់នូវប្រភពទឹកដែលមានសុវត្ថិភាព និងមានចំណុចខុសគ្នាជាច្រើនក្នុងចំណោមលទ្ធផលនៃការសិក្សាថ្នាក់ជាតិនានា ។ បញ្ហាសំខាន់ គឺថាតើគ្រួសារទាំងនោះមានលទ្ធភាពក្នុងការទទួលបានប្រភពទឹក ដែលមានសុវត្ថិភាពល្អប្រសើរសម្រាប់ប្រើប្រាស់ពេញ

មួយឆ្នាំឬអត់ ហើយទំនងជាមានសមមាត្រនៃគ្រួសារកម្ពុជាទាបជាង៤២ភាគរយដែលមានលទ្ធភាពក្នុងការទទួលបានទឹកស្អាតសម្រាប់ប្រើប្រាស់[៧៣] ។ លើសពីនេះទៅទៀត មានតែ១៦ភាគរយនៃគ្រួសារនៅតាមជនបទ ប៉ុណ្ណោះដែលមានបង្គន់អនាម័យត្រឹមត្រូវ[៧៤] ។

កង្វះលទ្ធភាពក្នុងការទទួលបានទឹកស្អាតសម្រាប់ប្រើប្រាស់ និងកង្វះអនាម័យបណ្តាលឱ្យមានការរីករាលដាលជំងឺរាគរូស និងបរាសិតដែលជាមូលហេតុសំខាន់ក្នុងការធ្វើឱ្យបាត់បង់សារធាតុចិញ្ចឹមនិងលទ្ធភាពក្នុងការស្រូបយកជីវជាតិអាហារមានការថយចុះ ។ ជាលទ្ធផល ជំងឺរាគរូសគឺជាមូលហេតុចម្បងបណ្តាលឱ្យមានបញ្ហាកង្វះអាហារូបត្ថម្ភ និងមរណភាពរបស់កុមារនៅប្រទេសកម្ពុជា ។

នៅក្នុងសហគមន៍អសន្តិសុខស្បៀង គុណភាព និងនានាភាពនៃការបរិភោគអាហារគឺនៅមានកម្រិតទាបជាងតម្រូវការអប្បបរមា ។ កង្វះទឹកស្អាត និងអនាម័យកាត់បន្ថយបន្ថែមទៀតនូវការស្រូបយក និងការរំលាយអាហារ ហើយក៏ធ្វើឱ្យប៉ះពាល់ដល់អ្នកដែលមានបញ្ហាកង្វះអាហារូបត្ថម្ភស្រាប់ផងដែរ ។

នៅឆ្នាំ២០០១ ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំ (២០០១-២០១១) ស្តីពីការផ្គត់ផ្គង់ទឹក និងអនាម័យជនបទ ប៉ុន្តែ សេចក្តីព្រាងយុទ្ធសាស្ត្រនេះពុំទាន់ត្រូវបានរៀបចំឱ្យក្លាយទៅជាឯកសារគោលនយោបាយពេញលេញ នៅឡើយទេ ។

**សកម្មភាពជាអាទិភាព**

- ក្រសួងអភិវឌ្ឍន៍ជនបទចាំបាច់គួរតែរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំ (២០០១-២០១១) ស្តីពីការផ្គត់ផ្គង់ទឹក និងអនាម័យជនបទ ឱ្យក្លាយទៅជាឯកសារគោលនយោបាយពេញលេញមួយ ។
- ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការមិនមែនរដ្ឋាភិបាលចាំបាច់គួរតែបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតនៅតាមអាងទឹកនិងនៅសហគមន៍ ហើយគួរតែបង្កើតប្រព័ន្ធថែទាំមួយដែលមាននិរន្តរភាព ។ ការពិនិត្យគុណភាពទឹក និងជាតិអាសេនិចនៅក្នុងអណ្តូងទឹក ចាំបាច់គួរតែបន្តធ្វើ ។
- ក្រសួងអភិវឌ្ឍន៍ជនបទ និងដៃគូអភិវឌ្ឍន៍ចាំបាច់គួរតែបង្កើនការវិនិយោគលើបង្គន់អនាម័យនៅក្នុងសហគមន៍ ហើយក្រសួងសុខាភិបាលចាំបាច់គួរតែលើកកម្ពស់ការយល់ដឹងអំពីរបៀបអនុវត្តអនាម័យឱ្យបានល្អ ។
- ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសុខាភិបាលចាំបាច់គួរតែបង្កើនការអប់រំ និងលើកកម្ពស់ការយល់ដឹងអំពីការកែលម្អការប្រើប្រាស់ទឹក និងរបៀបអនុវត្តអនាម័យឱ្យបានល្អ ។

---

[៧៣] ឯកសារ ឆ្នាំ ២០០៦ របស់ក្រសួងអភិវឌ្ឍន៍ជនបទ (ដោយ Levisay M និង Chea S) ស្តីពីការប៉ាន់ស្មានអំពីលទ្ធភាពក្នុងការទទួលបានការផ្គត់-ផ្គង់ទឹក : លទ្ធផលដែលបានមកពីការវិភាគប្រៀបធៀបនៃការអង្កេតជាតិកម្ពុជា លើកម្មវិធីទឹកនិងអនាម័យរបស់ក្រសួងអភិវឌ្ឍន៍ជនបទ, ភ្នំពេញ ។

[៧៤] លទ្ធផលសម្រាប់ឆ្នាំ ២០០៥ នៃ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០*

- ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចាំបាច់គួរតែត្រួតពិនិត្យមើលការអនុវត្តអនាម័យបសុសត្វ និងផលប៉ះពាល់លើសុខភាពមនុស្ស ។
- ក្រសួងអភិវឌ្ឍន៍ជនបទ និងដៃគូអភិវឌ្ឍន៍គួរតែកំណត់គោលដៅ និងកំណត់អាទិភាពសហគមន៍អសន្តិសុខស្បៀងសម្រាប់ធ្វើការវិនិយោគ ដើម្បីទាញយកផលប្រយោជន៍ឱ្យបានជាអតិបរមាក្នុងការកាត់បន្ថយអត្រាមានជំងឺ និងអត្រាមរណភាពរបស់កុមារ ។

### ៤.៣.៣. ការកែលម្អសុវត្ថិភាពស្បៀង និងការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារ

**ស្ថានភាព និងសន្និទានភាព**

នៅមានកង្វះខាតខាងផ្នែកស្តង់ដារគុណភាព និងសុវត្ថិភាពនៃផលិតផលស្បៀង ហើយការអនុវត្តស្តង់ដារគុណភាពស្បៀងដែលមានស្រាប់នៅក្នុងវិស័យសេដ្ឋកិច្ចក៏នៅមានកម្រិត ។ ជារឿយៗ ចំណីអាហារនានាមានលក្ខណៈមិនស្អាត ឬខូច (មានឆ្លងមេរោគ) នៅកន្លែងតាំងលក់ ។ សំណល់នៃថ្នាំសម្លាប់សត្វល្អិតនៅក្នុងអាហារ និងសារធាតុគីមីដែលប្រើប្រាស់ក្នុងពេលកែច្នៃ ព្រមទាំងការរៀបចំ និងការថែរក្សាទុកអាហារមិនមានអនាម័យល្អ ធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពមនុស្ស ជាពិសេសប្រជាពលរដ្ឋក្រីក្រដែលទិញស្បៀងមាន តម្លៃថោកៗនៅទីផ្សារ ។

បើនិយាយអំពីឧស្សាហកម្មកែច្នៃស្បៀងវិស័យឯកជនចាំបាច់គួរតែមានការរៀបចំ និងអនុវត្តច្បាប់ និងបទបញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងការផលិត និងការលក់ស្បៀងអាហារកែច្នៃដែលមានបញ្ចូលមីក្រូសារជាតិ ។

**សកម្មភាពជាអាទិភាព :**

- ក្រសួងពាណិជ្ជកម្ម (កាំកុងត្រូល) ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចាំបាច់គួរតែរៀបចំ និងអនុវត្តស្តង់ដារសុវត្ថិភាពស្បៀង ដោយជាបឋមផ្តល់អាទិភាពលើអាហារសំខាន់ៗមួយចំនួន។
- ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងអប់រំ យុវជន និងកីឡា ចាំបាច់គួរតែធ្វើការផ្សព្វផ្សាយឱ្យបានជ្រួតជ្រាបដល់ជាសាធារណៈអំពីសារធាតុគីមីគ្រោះថ្នាក់ ដែលប្រើប្រាស់លើអាហារ និងអំពីផលប៉ះពាល់របស់វាទៅលើសុខភាពមនុស្ស ។
- អនុគណៈកម្មាធិការសម្រាប់ការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារនៃក្រុមប្រឹក្សាជាតិអាហារូបត្ថម្ភ ចាំបាច់គួរតែរៀបចំនិងអនុវត្តបទបញ្ញត្តិនានាដែលពាក់ព័ន្ធនឹងការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារនៅក្នុងប្រទេសកម្ពុជា ។

## ៤.៤.ការបង្កើនស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀង

**គោលបំណងទី៤ :** *កែលម្អបណ្តាញសុវត្ថិភាពសង្គម និងលើកកម្ពស់សមត្ថភាពរបស់ក្រុមគ្រួសារអសន្តិសុខស្បៀងក្នុងការដោះស្រាយហានិភ័យផ្សេងៗ និងជួយ**បង្កើនស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀង***។

របាយការណ៍ ឆ្នាំ២០០៦ បានធ្វើការសង្កេតថា “នៅប្រទេសកម្ពុជាក្រោយសង្គ្រាម បញ្ហាហានិភ័យ និងភាពងាយរងគ្រោះមាននៅគ្រប់ទិសទី ហើយវាមានលក្ខណៈកាន់តែធ្ងន់ធ្ងរថែមទៀតដោយសារភាពទន់ខ្សោយនៃបណ្តាញសុវត្ថិភាព”[៧៥]។ បញ្ហានេះក៏ដូចគ្នាដែរនឹងបរិបទនៃបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ហើយដូចដែលបានអង្កេតនៅក្នុងរបាយការណ៍ដដែលថា “អសន្តិសុខស្បៀងគឺជាលក្ខណៈសំខាន់ពិសេសនៃភាពក្រីក្រ និងភាពងាយរងគ្រោះនៅប្រទេសកម្ពុជា”។

ស្របពេលដែលគ្រួសារអសន្តិសុខស្បៀងជាទូទៅពឹងផ្អែកទាំងស្រុងលើផលិតផលកសិកម្ម និងសកម្មភាពក្នុងវិស័យឯកជនដើម្បីផលិត និងទិញស្បៀងសម្រាប់បំពេញតម្រូវការអប្បបរមា ការប្រឹងប្រែងរបស់ពួកគាត់អាចនឹងទទួលបរាជ័យក្នុងកាលៈទេសៈណាមួយ ។ គ្រោះធម្មជាតិដូចជាៈ ទឹកជំនន់ គ្រោះរាំងស្ងួត ព្រមទាំងវិបត្តិបុគ្គលដែលមិនអាចព្យាករណ៍ជាមុនបាន ដោយសារជំងឺធ្ងន់ ឬគ្រោះភ័យសេដ្ឋកិច្ច-សង្គមផ្សេងៗអាចធ្វើឱ្យប្រជាពលរដ្ឋជួបប្រទះបញ្ហាកង្វះស្បៀងជាបណ្តោះអាសន្ន ។ យុទ្ធសាស្ត្រដោះស្រាយប្រកបដោយភាពប្រថុយប្រថាន ដូចជាៈ ការលក់អចលនទ្រព្យ (រួមមានៈ ដី និងឧបករណ៍កសិកម្ម) ឬ គុណវិបត្តិផ្នែកសេដ្ឋកិច្ច-សង្គម រយៈពេលវែង (ជំងឺរ៉ាំរ៉ៃ ជំងឺអេដស៍/មេរោគអេដស៍ កង្វះអចលនទ្រព្យសម្រាប់ផលិតកម្ម ភាពក្រីក្រនិងកង្វះ ចំណូល) នឹងក្លាយជាមូលហេតុបណ្តាលឱ្យពួកគាត់ប្រឈមមុខនឹងបញ្ហាអសន្តិសុខស្បៀងរ៉ាំរ៉ៃ ។ នេះគឺជាបញ្ហាដ៏សំខាន់យ៉ាងជាក់ច្បាស់ដែលថាយើងចាំបាច់គួរតែរៀបចំបង្កើតឱ្យមានបណ្តាញសុវត្ថិភាពសង្គមដ៏មាន ប្រសិទ្ធិភាពដើម្បីធានាឱ្យមានស្ថេរភាពក្នុងការទទួលបានស្បៀងតាមតម្រូវការអតិបរមារបស់ក្រុមជនងាយ រងគ្រោះទាំងនេះ។

នៅក្នុងវិស័យដ៏ទូលំទូលាយនេះ យើងកំណត់យកតែវិស័យផ្សេងគ្នាចំនួនពីរ ដើម្បីជំរុញស្ថេរភាពសន្តិសុខស្បៀង :

- ការពង្រឹងបណ្តាញសុវត្ថិភាពសម្រាប់គ្រប់គ្រងគ្រោះធម្មជាតិ
- ការបង្កើតបណ្តាញសុវត្ថិភាពសង្គមសម្រាប់ក្រុមជនងាយរងគ្រោះ ។

### ៤.៤.១. ការកែលម្អបណ្តាញសុវត្ថិភាពសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយ

---

[៧៥] ឯកសារស្តីពី ការគ្រប់គ្រងហានិភ័យ និងភាពងាយរងគ្រោះនៅកម្ពុជា របស់ធនាគារពិភពលោក ឆ្នាំ ២០០៦ : ការវាយតម្លៃ និងការគាំពារសង្គម

**ស្ថានភាព និងសន្តិទានភាព**

ប្រទេសកម្ពុជាតែងតែជួបប្រទះគ្រោះមហន្តរាយដែលអាចគំរាមកំហែងដល់ជីវិត និងសន្តិសុខស្បៀងរបស់ប្រជាពលរដ្ឋ ។ នៅពេលមានគ្រោះមហន្តរាយកើតឡើង ប្រជាពលរដ្ឋក្រីក្រ និងអសន្តិសុខស្បៀងតែងតែងាយរងគ្រោះដោយសារតែផលប៉ះពាល់ពីគ្រោះមហន្តរាយនេះ[៧៦] ។ គ្រោះធម្មជាតិនៅប្រទេសកម្ពុជាភាគច្រើន គឺទឹកជំនន់ និងគ្រោះរាំងស្ងួតដែលប៉ះពាល់ដោយផ្ទាល់ដល់កសិកម្ម ហើយជាលទ្ធផលធ្វើឱ្យកើតមានបញ្ហាកង្វះស្បៀង ។ ទឹកជំនន់ក៏ជាគ្រោះមហន្តរាយដែលបង្កឱ្យប៉ះពាល់ដោយផ្ទាល់ដល់ជីវិតមនុស្សនិងសត្វ ព្រមទាំងលំនៅដ្ឋានផងដែរ ។ ចំណែកឯគ្រោះរាំងស្ងួត (ប្រសិនបើមានលក្ខណៈធ្ងន់ធ្ងរ) អាចគំរាមកំហែងដល់ជីវិតមនុស្ស ដោយសារតែវាបណ្តាលឱ្យមានការខ្វះខាតក្នុងការផ្គត់ផ្គង់ទឹកសម្រាប់មនុស្ស និងសត្វ ។

យើងទទួលស្គាល់ផងដែរថា ផលប៉ះពាល់ធ្ងន់ធ្ងរនៃការផ្ទុះឡើងនូវជំងឺគ្រុនផ្តាសាយបក្សីគឺជាគ្រោះគំរាមកំហែងយ៉ាងខ្លាំងដល់ជីវិតមនុស្ស និងសត្វ ។ ឥឡូវនេះ នៅប្រទេសកម្ពុជាក៏មានការទទួលស្គាល់ផងដែរ អំពីគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ។ នៅឆ្នាំ២០០៦ ក្រសួងបរិស្ថានបានបោះពុម្ពផ្សាយឯកសារកម្មវិធីជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA) ។ ការសិក្សាបានបង្ហាញឱ្យឃើញថា ប្រទេសកម្ពុជាងាយនឹងទទួលរងគ្រោះដោយសារបម្រែបម្រួលអាកាសធាតុ ហើយការសិក្សាដដែលនេះក៏បានផ្តល់អនុសាសន៍ជាច្រើនដើម្បីដោះស្រាយបញ្ហាទាំងនេះ ។

ម្យ៉ាងទៀត កាលពីពេលថ្មីៗនេះ មានការសិក្សាមួយបានគូសបញ្ជាក់អំពីគ្រោះថ្នាក់សេដ្ឋកិច្ច-សង្គម ដោយសារតែការកើនឡើងនៃតម្លៃស្បៀងដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខស្បៀងនៅប្រទេសកម្ពុជា[៧៧] ។ ការសិក្សានេះបានបង្ហាញឱ្យឃើញថា ៧០ភាគរយនៃការចំណាយសរុបប្រចាំគ្រួសារត្រូវបានប្រើប្រាស់សម្រាប់ទិញស្បៀងយកមកបរិភោគ ។

ការសិក្សាក៏បានរៀបរាប់ដែរថា ក្នុងចំណោមប្រជាពលរដ្ឋទូទៅ ៥១ភាគរយនៃកម្រិតរបបអាហារបានមកពីការទិញស្បៀងពីទីផ្សារ ៣៦ភាគរយបានមកពីផលិតកម្មផ្ទាល់ខ្លួន ហើយចំណែកនៅសល់បានមកពីប្រភពផ្សេងៗទៀត ។ ចំណែកឯក្នុងចំណោមគ្រួសារនៅតាមជនបទដែលប្រកបរបរកសិកម្ម ៤៨ភាគរយនៃកម្រិតរបបអាហារបានមកពីការទិញមកពីទីផ្សារ ៤២ភាគរយបានមកពីផលិតកម្មផ្ទាល់ខ្លួន ចំណែកឯនៅសល់ពីនេះបានមកពីប្រភពដទៃទៀត ។

នេះបង្ហាញឱ្យឃើញថា ទោះបីជាប្រជាពលរដ្ឋភាគច្រើនជាអ្នកប្រកបរបរកសិកម្មក៏ដោយ ក៏ប៉ុន្តែពួកគាត់នៅតែពឹងផ្អែកយ៉ាងខ្លាំងលើការទិញស្បៀងសម្រាប់បំពេញតម្រូវការស្បៀងប្រចាំគ្រួសារ ដែលប្រការនេះគឺជាមូលហេតុធ្វើឱ្យពួកគាត់ងាយនឹងរងគ្រោះដោយសារតែភាពមិនទៀតទាត់នៃតម្លៃស្បៀង ។ ក្នុងន័យនេះ ចាំបាច់តម្រូវឱ្យមានការរៀបចំបង្កើតឡើងនូវគោលនយោបាយ និងនីតិវិធីនានាសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយដើម្បីដោះស្រាយការកើនឡើងនៃតម្លៃស្បៀងដែលអាចបណ្តាលមកពីឥទ្ធិពលទាំងឡាយនៃគ្រោះមហន្តរាយ ។

---

[៧៦] ឯកសារ ឆ្នាំ ២០០៤ ស្តីពីទំនាក់ទំនងរវាងគ្រោះមហន្តរាយទឹកជំនន់និងរាំងស្ងួត និង សន្តិសុខស្បៀងនិងការប្រកបរបរចិញ្ចឹមជីវិតតាមជនបទរបស់ប្រជាពលរដ្ឋកម្ពុជា ( ដោយ Helmers K និង Jegillos S, អង្គការ និង IFRC កាកបាទក្រហមកម្ពុជា )

[៧៧] ការវាយតម្លៃអសន្តិសុខស្បៀង ឆ្នាំ ២០០៧ របស់វិទ្យាស្ថានជាតិស្ថិតិ សហការជាមួយ អង្គការ FAO និង EU ។

ទន្ទឹមគ្នានោះដែរ បណ្តាញសុវត្ថិភាពគ្រប់គ្រងគ្រោះមហន្តរាយសម្រាប់ការប្រកាសអាសន្ន ការត្រៀមបង្ការគ្រោះមហន្តរាយ និងការកាត់បន្ថយហានិភ័យ មិនទាន់រៀបចំបានល្អនៅឡើយ ។ រចនាសម្ព័ន្ធរបស់រដ្ឋាភិបាលរួមមាន: គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងបណ្តាញរបស់ខ្លួននៅតាមខេត្ត (គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត-ក្រុង គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ស្រុក-ខ័ណ្ឌនិងជាពិសេសគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ឃុំ-សង្កាត់) ត្រូវបានរៀបចំឡើងរួចហើយ ប៉ុន្តែតម្រូវឱ្យមានការគាំទ្រ និងការពង្រឹងសមត្ថភាពបន្ថែមទៀត ដើម្បីបំពេញមុខនាទីរបស់ខ្លួន ។ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ឃុំ-សង្កាត់ទើបតែត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ កាលពី ខែ មិថុនា ឆ្នាំ ២០០៦។

មានស្ថាប័នជាច្រើនបាន និងកំពុងធ្វើសកម្មភាពដើម្បីឆ្លើយតបនឹងគ្រោះមហន្តរាយ និងការស្តារឡើងវិញ ប៉ុន្តែស្ថាប័នទាំងនោះជាទូទៅខ្វះខាតធនធាន និងការសម្របសម្រួល ហើយពុំមានយុទ្ធសាស្ត្រច្បាស់លាស់សម្រាប់ផ្សារភ្ជាប់ទៅនឹងគម្រោង និងផែនការអភិវឌ្ឍន៍រយៈពេលវែង ។

ស្ថាប័នមិនមែនរដ្ឋាភិបាលជាច្រើន (ភ្នាក់ងារកាកបាទក្រហម អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល) ក៏បាននិងកំពុងធ្វើសកម្មភាពពាក់ព័ន្ធនឹងបណ្តាញសុវត្ថិភាពសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយ ក្នុងនោះរួមមាន: ប្រព័ន្ធប្រកាសអាសន្ន ការត្រៀមបង្ការគ្រោះមហន្តរាយ និងការកាត់បន្ថយហានិភ័យ ។ ការធ្វើសកម្មភាព និងនិរន្តរភាពនៃបណ្តាញសុវត្ថិភាពនៅមានកម្រិត ជាពិសេសនៅពេលអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល ។

**សកម្មភាពជាអាទិភាព**

- ពាក់ព័ន្ធទៅនឹងបណ្តាញសុវត្ថិភាពសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយចាំបាច់គួរតែពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធី ដែលមានស្រាប់ពង្រឹងការសម្របសម្រួលជាមួយដៃគូ និងពង្រឹងភាពជាដៃគូបន្ថែមទៀតជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលមានគុណសម្បត្តិក្នុងការផ្តល់សេវាកម្មបណ្តាញសុវត្ថិភាពគ្រប់គ្រងគ្រោះមហន្តរាយ ។
- រៀបចំបន្ថែមនូវរចនាសម្ព័ន្ធស្ថាប័ន និងពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងបណ្តាញរបស់ខ្លួននៅតាមខេត្ត (គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត-ក្រុង គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ស្រុក-ខ័ណ្ឌ និងជាពិសេសគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ឃុំ-សង្កាត់) ។
- ក្រសួងអភិវឌ្ឍន៍ជនបទ និងដៃគូអភិវឌ្ឍន៍ចាំបាច់គួរតែបង្កើនការងារតាមរដូវកាលក្នុងវិស័យសាធារណការជនបទនៅតាមសហគមន៍ដែលងាយនឹងរងគ្រោះដោយសារទឹកជំនន់ និងរាំងស្ងួត តាមរយៈគម្រោងស្បៀងពលកម្ម ឬថវិកាពលកម្ម។
- ពង្រីកសកម្មភាពរបស់រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ភ្នាក់ងារកាកបាទក្រហម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការត្រៀមបង្ការ ការកាត់បន្ថយ ការឆ្លើយតបនឹងគ្រោះមហន្តរាយ និងការស្តារឡើងវិញ ។
- បង្កើនការបណ្តុះបណ្តាល ការផ្សព្វផ្សាយ និងផ្តល់សម្ភារៈដល់សហគមន៍ងាយរងគ្រោះដើម្បីគ្រប់គ្រងគ្រោះមហន្តរាយដោយទឹកជំនន់ រាំងស្ងួត និងសត្វល្អិតបំផ្លាញដំណាំ ឱ្យបានល្អប្រសើរ តាមរយៈការ

បង្កើនកិច្ចសហប្រតិបត្តិការរវាងស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

- ជំរុញឱ្យគ្រួសារនីមួយៗប្រកបរបរច្រើនមុខសម្រាប់ចិញ្ចឹមជីវិត រួមមាន: ការប្រកបរបរកសិកម្ម និងសកម្មភាពក្រៅពីការងារកសិកម្ម ដូចជា: ការធ្វើជំនួញខ្នាតតូច និងការធ្វើពលកម្មរកកម្រៃក្នុងវិស័យមិនផ្លូវការ ។
- ថែទាំ ឬកែលម្អផលិតភាព និងលទ្ធភាពនៃការប្រើប្រាស់ធនធានរួមរបស់សហគមន៍ជនបទ ដែលធនធានទាំងនេះផ្តល់សារសំខាន់យ៉ាងខ្លាំងដល់ប្រជាពលរដ្ឋក្រីក្រ ក្នុងការដោះស្រាយគ្រោះភ័យ និងគ្រោះមហន្តរាយធម្មជាតិផ្សេងៗ (សូមមើលគោលបំណងទី១ នៃ សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ដែលនិយាយអំពីការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា) ។
- គាំទ្រការអនុវត្តសកម្មភាពជាអាទិភាពនានា ដែលមាននៅក្នុង កម្មវិធីជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA) ។
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយចាំបាច់គួរតែរៀបចំបង្កើតឱ្យមានគោលនយោបាយ និងនីតិវិធីនានាសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីដោះស្រាយការកើនឡើងនៃតម្លៃស្បៀងដែលអាចបណ្តាលមកពីឥទ្ធិពលទាំងឡាយនៃគ្រោះមហន្តរាយ ។ គោលនយោបាយ និងនីតិវិធីទាំងនេះរួមមាន: វិធានការក្នុងការធ្វើឱ្យមានស្ថេរភាពនៃតម្លៃស្បៀងក្នុងកំឡុងពេល និងក្រោយពេលគ្រោះមហន្តរាយ ។

### ៤.៤.២. ការបង្កើតបណ្តាញសុវត្ថិភាពសង្គមសម្រាប់ក្រុមជនងាយរងគ្រោះ

#### ស្ថានភាព និងសន្និទានភាព

នៅក្នុងប្រទេសដែលមានភាពក្រីក្រនិងអសន្តិសុខស្បៀង ហើយដែលទើបតែងើបពីសង្គ្រាម និងស្ថិតនៅក្នុងដំណាក់កាលនៃអន្តរកាលសេដ្ឋកិច្ចតម្រូវឱ្យមានបណ្តាញសុវត្ថិភាពសង្គមសម្រាប់ក្រុមជនងាយរងគ្រោះ ដូចជា: ការផ្តល់សេវាកម្មថែទាំសុខភាព សុខុមាលភាពសង្គម និងតម្រូវការជាមូលដ្ឋាន រួមមាន: ស្បៀង និងការងារធ្វើ ។

ក្រុមជនងាយរងគ្រោះដែលគេទទួលស្គាល់ជាទូទៅ រួមមាន: អ្នកមានជំងឺអេដស៍ឬអ្នកផ្ទុកមេរោគអេដស៍ អ្នកមានជំងឺធ្ងន់ធ្ងររ៉ាំរ៉ៃ ចាស់ជរាគ្មានទីពឹង ជនពិការ អ្នករងគ្រោះដោយសារសង្គ្រាម (ទាហានរំសាយ អតីតជនភៀសខ្លួន អ្នកគ្មានផ្ទះសំបែង និងជនរងគ្រោះដោយសារគ្រាប់មីនឬយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ) ជនជាតិភាគតិច (ជាពិសេសនៅតំបន់ខ្ពង់រាប) និងទុគ៌តជន។ បើនិយាយឱ្យចំទៅ នៅមានក្រុមជនងាយរងគ្រោះមួយចំនួនទៀត ដូចជា: អ្នកមានជំងឺផ្លូវចិត្ត ស្ត្រីនិងកុមារ ជនក្រីក្រនិងអសន្តិសុខស្បៀង អ្នកគ្មានការងារធ្វើ និងអ្នកក្រីក្រនៅតាមទីប្រជុំជន[៧៨] ត្រូវបានមើលរំលង។

អសន្តិសុខស្បៀងគឺជាកត្តាកំណត់នៃភាពងាយរងគ្រោះ ដែលក្រុមសង្គមទាំងអស់នេះជួបប្រទះនៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគាត់ ។ ជំងឺ ឬពិការភាព ភាពឯកោនៅក្នុងសង្គម វិសមភាព និងអសមត្ថភាពក្នុងការ

---

៧៨ រួមមាន: ក្រុមដែលបានកំណត់នៅក្នុង ឯកសារស្តីពី ការគ្រប់គ្រងហានិភ័យ និងភាពងាយរងគ្រោះនៅកម្ពុជា របស់ធនាគារពិភពលោក ឆ្នាំ ២០០៦

រកប្រាក់ចំណូលអាចនាំទៅរកកង្វះស្បៀងយ៉ាងឆាប់រហ័ស ។ កង្វះអាហារូបត្ថម្ភដែលជាលទ្ធផលនៃកង្វះស្បៀងធ្វើឱ្យក្រុមសង្គមទាំងនេះកាន់តែងាយរងគ្រោះថែមទៀត ។ ហេតុដូច្នេះ ការផ្តល់ជំនួយសង្គ្រោះផ្នែកសង្គមកិច្ចគឺជាកត្តាកំណត់យ៉ាងសំខាន់នៃបណ្តាញសុវត្ថិភាពសង្គមសម្រាប់ក្រុមជនងាយរងគ្រោះ ព្រោះថា វាគឺជាមធ្យោបាយធ្វើឱ្យជនងាយរងគ្រោះទាំងអស់នោះអាចមានភាពទទួលបានស្បៀង ឬមធ្យោបាយសម្រាប់ទិញស្បៀង ។ វិបត្តិនៃតម្លៃស្បៀងអាហារក្នុងពេលបច្ចុប្បន្នជះឥទ្ធិពលជាអវិជ្ជមានបន្ថែមទៀតទៅលើសន្តិសុខស្បៀងរបស់ក្រុមជនងាយរងគ្រោះ ។ ដូច្នេះ តម្រូវការក្នុងការបង្កើត ឬពង្រីកបណ្តាញសុវត្ថិភាពកាន់តែមានសារសំខាន់ ។

ទន្ទឹមគ្នានោះដែរ រដ្ឋាភិបាលពុំទាន់មានប្រភពធនធានគ្រប់គ្រាន់ដើម្បីផ្តល់មូលនិធិសម្រាប់ជំនួយសង្គ្រោះផ្នែកសង្គមកិច្ច ដូចជាៈ ការផ្តល់ស្បៀង ថវិកា ឥណទាន និងសេវាកម្ម ក្នុងទ្រង់ទ្រាយធំ ទៅដល់ក្រុមជនងាយរងគ្រោះ ។ ជាងនេះទៅទៀត នៅថ្នាក់មូលដ្ឋាន ក្រុមប្រឹក្សាឃុំ-សង្កាត់ពុំមានលទ្ធភាព និងធនធានគ្រប់គ្រាន់ក្នុងការកំណត់គោលដៅក្រុមជនងាយរងគ្រោះសម្រាប់ធ្វើអន្តរាគមន៍ផ្តល់ជំនួយសង្គ្រោះផ្នែកសង្គមកិច្ច ។ ទោះបីជាយ៉ាងណាក៏ដោយ ភាពប្រសើរឡើងនៃមូលដ្ឋានចំណូលរបស់រដ្ឋដែលរំពឹងថានឹងទទួលបានតាមរយៈការធ្វើអាជីវកម្មប្រេង និងធនធានធម្មជាតិនាពេលខាងមុខ អាចបង្កើនលទ្ធភាពក្នុងការផ្តល់ហិរញ្ញប្បទានដល់បណ្តាញសុវត្ថិភាពសង្គមសម្រាប់ជួយក្រុមរងគ្រោះ និងអសន្តិសុខស្បៀង ។ នីតិវិធី និងលក្ខណៈវិនិច្ឆ័យក្នុងការកំណត់ក្រុមគ្រួសារក្រីក្រនិងងាយរងគ្រោះតាមវិធីចូលរួមដែលមានលក្ខណៈជាស្តង់ដារ កំពុងតែត្រូវបានរៀបចំឡើង និងធ្វើការសាកល្បង ហើយនីតិវិធីនេះប្រហែលជាអាចជួយធ្វើសន្ទិទានកម្មនៃការប្រើប្រាស់មូលនិធិឱ្យបានសមស្របនិងជួយបង្កើនប្រសិទ្ធិភាពនៃបណ្តាញសុវត្ថិភាព ។

ក្នុងការអនុវត្តជាក់ស្តែង យើងមានរួចហើយនូវសមាសធាតុមួយចំនួននៃបណ្តាញសុវត្ថិភាពសង្គម ដូចជាៈ ការផ្តល់ជំនួយសង្គ្រោះជាស្បៀង ឬមធ្យោបាយសម្រាប់ទិញស្បៀងទៅដល់ក្រុមជនងាយរងគ្រោះ ក៏ប៉ុន្តែធ្វើឡើងតែក្នុងពេលចាំបាច់តែប៉ុណ្ណោះ ដោយមិនបានគ្រោងទុកជាមុន ។ ដូច្នេះ នៅពេលមានការចាំបាច់បន្ទាន់ ការផ្តល់ជំនួយសង្គ្រោះធ្វើឡើងមិនបានពេញលេញនិងមិនបានទៅដល់គ្រប់អ្នករងគ្រោះទាំងអស់ ហើយពឹងផ្អែកទាំងស្រុងលើជំនួយឧបត្ថម្ភពីអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ។

បណ្តាញសុវត្ថិភាព ដែលឧបត្ថម្ភដោយដៃគូអភិវឌ្ឍន៍បានបង្កើតឡើងនៅក្នុងខេត្តមួយចំនួន សម្រាប់ជួយខាងផ្នែកអនាម័យ និងសុខភាពដល់ជនរងគ្រោះក្នុងចំនួននៅមានកម្រិត ។ តាមរយៈការខិតខំប្រឹងប្រែងរបស់ក្រសួងសុខាភិបាល អង្គការសុខភាពពិភពលោក ដៃគូអភិវឌ្ឍន៍ និងដៃគូមិនមែនរដ្ឋាភិបាលនានា គម្រោងមូលនិធិសមធម៌សុខភាព និងការធានារ៉ាប់រងសុខភាពសម្រាប់ប្រជាពលរដ្ឋក្រីក្រត្រូវបានរៀបចំបង្កើតឡើង និងពង្រីកកាន់តែទូលំទូលាយថែមទៀត[៧៩] ។

គម្រោងអភិវឌ្ឍន៍ជនបទ គម្រោងអភិវឌ្ឍន៍សហគមន៍ និងគម្រោងកាត់បន្ថយភាពក្រីក្រនានាបានផ្តល់អត្ថប្រយោជន៍ដល់ក្រុមជនងាយរងគ្រោះ ដោយធ្វើការតម្រង់ឆ្ពោះទៅរកពួកគាត់ក្នុងការផ្តល់ជំនួយ និងតាមរយៈការបង្កើនសមត្ថភាពរបស់ពួកគាត់ក្នុងការផលិតស្បៀង និងរកប្រាក់ចំណូលបន្ថែម ។ គម្រោងស្បៀងពលកម្ម ឬថវិកាពលកម្មនៅក្នុងសហគមន៍ក្រីក្រ និងអសន្តិសុខស្បៀងបានជួយបង្កើនកាលានុវត្តភាពការងារនៅមូលដ្ឋាន ។

---

៧៩ របាយការណ៍វេទិកាមូលនិធិសមធម៌សុខភាព ឆ្នាំ ២០០៦ ភ្នំពេញ

កម្មវិធីផ្តល់អាហារដល់សិស្សនៅតាមសាលាបានជួយគាំទ្រឱ្យក្មេងៗក្រីក្រនៅតាមជនបទមករៀនបានទៀងទាត់ ពិសេសគឺក្មេងស្រី ។ អង្គការកម្មវិធីស្បៀងអាហារពិភពលោកនៃសហប្រជាជាតិ និងរដ្ឋាភិបាល ព្រមទាំងដៃគូអភិវឌ្ឍន៍នានាមានគម្រោងធំៗគួរសមមួយចំនួនកំពុងតែធ្វើការក្នុងវិស័យនេះ នៅក្នុងប្រទេសកម្ពុជា [៨០] ។

សម្រាប់រយៈពេលយូរអង្វែង យើងត្រូវធ្វើឱ្យមានវឌ្ឍនភាពក្នុងការបង្កើតឡើងនូវបណ្តាញសុវត្ថិភាពសង្គមដែលមានលក្ខណៈជាប្រព័ន្ធ និងមានវិសាលភាពទូលំទូលាយគ្របដណ្តប់ឱ្យបានទៅដល់ក្រុមជនងាយរងគ្រោះទាំងអស់ ដោយបញ្ចូលវិធានការមួយចំនួនក្នុងការបង្កើនសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។ សម្រាប់រយៈពេលខ្លីទៅមធ្យម យើងគួរផ្តោតលើការពង្រីកតំបន់គ្របដណ្តប់ សម្រាប់ការធ្វើអន្តរាគមន៍ជាក់លាក់ខាងផ្នែកបណ្តាញសុវត្ថិភាព។

**សកម្មភាពជាអាទិភាព**

- ពាក់ព័ន្ធទៅនឹងបណ្តាញសុវត្ថិភាពសង្គម រដ្ឋាភិបាលចាំបាច់គួរតែធ្វើឱ្យកម្មវិធីដែលមានស្រាប់កាន់តែមានប្រសិទ្ធភាព ពង្រឹងការសម្របសម្រួលជាមួយដៃគូ និងបង្កើតភាពជាដៃគូបន្ថែមទៀតជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលមានគុណសម្បត្តិក្នុងការផ្តល់សេវាកម្មខាងផ្នែកបណ្តាញសុវត្ថិភាពសង្គម។
- បន្ត និងពង្រីកប្រព័ន្ធផ្តល់ជំនួយសង្គ្រោះចំទិសដៅដោយសហការជាមួយភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា។
- ក្រសួងសុខាភិបាល អង្គការសុខភាពពិភពលោក និងដៃគូនានាដែលជាអង្គការមិនមែនរដ្ឋាភិបាលចាំបាច់គួរតែបន្តរៀបចំ និងពង្រីកគម្រោងមូលនិធិសមធម៌សុខភាព និងការធានារ៉ាប់រងសុខភាពសម្រាប់ជនក្រីក្រ និងអសន្តិសុខស្បៀង។
- ក្រសួងអភិវឌ្ឍន៍ជនបទ ចាំបាច់គួរតែបន្តគម្រោងស្បៀងពលកម្ម ឬថវិកាពលកម្មនៅតាមសហគមន៍ និងបន្តរិះរកគំនិតថ្មីៗសម្រាប់ការអនុវត្តគម្រោង។
- ក្រសួងអប់រំ យុវជននិងកីឡាចាំបាច់គួរតែពង្រីកកម្មវិធីផ្តល់អាហារដល់សិស្សសាលារបស់អង្គការកម្មវិធីស្បៀងអាហារពិភពលោក និងគម្រោងរបស់ដៃគូអភិវឌ្ឍន៍នានាដើម្បីជួយជំរុញឱ្យសិស្សក្រីក្រមករៀនបានទៀតទាត់ ។
- ក្រសួងមហាផ្ទៃចាំបាច់គួរតែផ្តល់ធនធាន និងបណ្តុះបណ្តាលក្រុមប្រឹក្សាឃុំ-សង្កាត់ឱ្យចេះរៀបចំគម្រោងស្បៀងពលកម្ម ឬថវិកាពលកម្ម ដោយផ្អែកលើគម្រោងសាធារណការនៅមូលដ្ឋាន។
- ពង្រីកសេវាកម្មថែទាំអ្នកជំងឺអេដស៍ ឬអ្នកផ្ទុកមេរោគអេដស៍នៅតាមផ្ទះ ដើម្បីជួយឧបត្ថម្ភគាំទ្រពួកគាត់ ដោយផ្តល់ស្បៀង និងប្រាក់ឧបត្ថម្ភ និងពង្រីកតំបន់ផ្តល់សេវាកម្ម។

---

៨០ កម្មវិធីប្រភេទនេះរបស់អង្គការ WFP រួមបញ្ចូលអ្នកដែលមានជំងឺជំងឺអេដស៍/មេរោគអេដស៍ អ្នកជំងឺរបេង និងកម្មវិធីផ្តល់អាហារតាមសាលា ។ សូមមើល ឯកសារឆ្នាំ ២០០៤ របស់អង្គការ WFP ស្តីពី ជំហានជាក់ស្តែងឆ្ពោះទៅកាន់សហស្សវត្សរ៍ រួចចាកពីភាពអត់ឃ្លាន ។

➢ ក្រសួងផែនការ និងដៃគូអភិវឌ្ឍន៍ចាំបាច់គួររៀបចំ និងអនុវត្តបន្ថែមទៀតនូវប្រព័ន្ធជាតិមួយដែលមានលក្ខណៈឯកភាព សម្រាប់ធ្វើការកំណត់គ្រួសារក្រីក្រ និងអសន្តិសុខស្បៀង ដើម្បីធ្វើការផ្តល់ជំនួយសង្គ្រោះ និងជំនួយអភិវឌ្ឍន៍ ឱ្យបានចំទិសដៅ ។

## ៤.៥. ការកែលម្អបរិស្ថានគោលនយោបាយ និងស្ថាប័នសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ

***គោលបំណងទី៥: កែលម្អបរិស្ថានគោលនយោបាយ និងស្ថាប័ន*** *ដើម្បីសម្រេចបានការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ។*

### ស្ថានភាពទូទៅ និងសន្និទានភាព

កង្វះស្បៀង និងកង្វះអាហារូបត្ថម្ភ ត្រូវបានទទួលស្គាល់ជាទូទៅថាជាបញ្ហាកង្វល់ខាងផ្នែកមនុស្សធម៌សម្រាប់រដ្ឋាភិបាល និងសង្គមស៊ីវិល ។ កំណែទម្រង់អភិបាលកិច្ចល្អក្នុងទស្សនវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភពាក់ព័ន្ធនឹងការលើកកម្ពស់សមត្ថភាពរបស់ស្ថាប័នរដ្ឋដើម្បីដោះស្រាយ និងជំនះបញ្ហាអសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភ ។ រដ្ឋាភិបាលបានផ្តួចផ្តើមគំនិតសំខាន់ៗជាច្រើនក្នុងការរៀបចំគោលនយោបាយ និងស្ថាប័នដើម្បីកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា និងដើម្បីពង្រឹងការសម្របសម្រួលក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់ ដូចដែលបានពិពណ៌នានៅក្នុងផ្នែក ២.២ ។

ទោះបីយ៉ាងនេះក្តី ក្នុងការត្រួតពិនិត្យមើលបរិស្ថានគោលនយោបាយ និងស្ថាប័នសម្រាប់ធ្វើឱ្យសម្រេចបាននូវវឌ្ឍនភាពក្នុងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ យើងរកឃើញឧបសគ្គសំខាន់ជាច្រើន ដែលចាំបាច់គួរតែដោះស្រាយ ដើម្បីសម្រេចឱ្យបាននូវវឌ្ឍនភាពឆ្ពោះទៅរកគោលដៅសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅក្នុងយុទ្ធសាស្ត្រចតុកោណ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។

យើងទទួលស្គាល់ថានៅក្នុងវិស័យកំណែទម្រង់រដ្ឋបាលសាធារណៈនិងវិមជ្ឈការ មានបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភជាអាទិភាពចំនួនបីដូចខាងក្រោម៖

➢ ការពង្រឹងសមត្ថភាព និងការកែលម្អការសម្របសម្រួលសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ
➢ ការបញ្ជ្រាប (ការបញ្ចូល) សន្តិសុខស្បៀង និងអាហារូបត្ថម្ភទៅក្នុងដំណើរការរៀបចំផែនការវិមជ្ឈការ
➢ ការកែលម្អការគ្រប់គ្រងព័ត៌មានពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការកំណត់គោលដៅអន្តរាគមន៍លើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីជួយដល់ជនក្រីក្រនិងអសន្តិសុខស្បៀងនៅកម្រិតថ្នាក់ជាតិ និងថ្នាក់សហគមន៍ ។

### ៤.៥.១. ការពង្រឹងសមត្ថភាព និងកែលម្អការសម្របសម្រួលសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ

#### ស្ថានភាព និងសន្និទានភាព

ទោះបីជាមកដល់បច្ចុប្បន្ននេះ យើងបានសម្រេចវឌ្ឍនភាពខ្លះៗយ៉ាងណាក៏ដោយ ក៏ការយល់ដឹងអំពីគោលគំនិតសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការបញ្ជ្រាបសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទៅក្នុងដំណើរការរៀបចំផែនការនៅតាមក្រសួងនៅមានកម្រិត ហើយក៏នៅមានចំណុចខ្សោយជាច្រើននៅក្នុងរចនាសម្ព័ន្ធថ្នាក់ជាតិសម្រាប់កែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។ នេះជាមូលហេតុ បណ្តាលឱ្យការទទួលស្គាល់បញ្ហាសន្តិសុខស្បៀង និង

អាហារូបត្ថម្ភមិនបានទូលំទូលាយ ហើយសមត្ថភាពរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការកំណត់អាទិភាព និងប្រតិបត្តិការគម្រោងអន្តរាគមន៍សន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅមានកម្រិត។ បញ្ហាខាងលើ បណ្ដាលមកពីពុំមានច្បាប់ ក្រឹត្យ គោលនយោបាយ បទបញ្ញត្តិ ឬគោលការណ៍ណែនាំនានាដើម្បីដោះស្រាយ បញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភឱ្យបានយល់ទូលំទូលាយ ។ ការងារជាអាទិភាព ដើម្បីដោះស្រាយ ឧបសគ្គទាំងនេះផ្ដោតជាសំខាន់ទៅលើការពង្រឹងសមត្ថភាពនៅតាមក្រសួង-ស្ថាប័នសំខាន់ៗ និងការកែលម្អ យន្តការសម្រាប់ការសម្របសម្រួលនៅកម្រិតថ្នាក់ជាតិ និងថ្នាក់វិមជ្ឈការ ។

នៅក្នុងឆ្នាំ ២០០៣ រាជរដ្ឋាភិបាលបានបង្កើតវេទិកាជាតិសន្តិស្បៀង ដែលមានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ជាប្រធាន ។ វេទិកាសន្តិសុខស្បៀងផ្ដល់ឱកាសឱ្យអ្នកពាក់ព័ន្ធទាំងអស់មកពីក្រសួង-ស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលបានជួបប្រជុំគ្នាជាទៀងទាត់ដើម្បីចែករំលែកព័ត៌មានចំណេះដឹង បទពិសោធន៍ និងមេរៀនល្អៗទាំងឡាយពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។ នៅក្នុងឆ្នាំ ២០០៤ ក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភត្រូវបានបង្កើតឡើងដើម្បីធ្វើការសម្របសម្រួលធ្វើសុខដុមនីយកម្ម និងតម្រែតម្រង់ការខិតខំប្រឹងប្រែងក្នុងកិច្ចអភិវឌ្ឍន៍ដែលមានគោលដៅធ្វើឱ្យប្រសើរឡើងនូវបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងប្រទេសកម្ពុជា ។ ក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលមានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងក្រសួងផែនការជាសហប្រធាន ហើយមានអង្គការកម្មវិធីស្បៀងអាហារពិភពលោក និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិជាអ្នកសម្របសម្រួលរួម មានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយដែលបានបង្កើតឡើងនៅឆ្នាំ២០០៥ ដើម្បីជួយសម្រួលដល់បណ្ដាញទំនាក់ទំនង និងការសម្របសម្រួលការងារអន្តរក្រសួង លើបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

**សកម្មភាពអាទិភាព:**

- កសាងសមត្ថភាពនៃលេខាធិកាដ្ឋានក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភដែលស្ថិតនៅក្នុងក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដើម្បីជួយសម្រួលដល់បណ្ដាញទំនាក់ទំនងនិងការសម្របសម្រួលការងារអន្តរក្រសួង លើបញ្ហាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។
- កសាងសមត្ថភាពបុគ្គលិកនៅតាមក្រសួង-ស្ថាប័ន ក្នុងការរៀបចំផែនការពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ : ពង្រីកការបណ្ដុះបណ្ដាលដល់បុគ្គលិកផែនការនៅតាមក្រសួង-ស្ថាប័ននានាអំពីគោលគំនិតជាមូលដ្ឋាននៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងអំពីការបញ្ជ្រាបបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភទៅក្នុងផែនការ ។ សិក្ខាកាមដែលមាន អាទិភាពសម្រាប់ កម្មវិធីបណ្ដុះបណ្ដាលនេះគឺបុគ្គលិកផែនការមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី ក្រសួងផែនការ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងពាណិជ្ជកម្ម និង ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ។
- បង្កើត ដំណើរការ និងគាំពារក្រុមគ្រូបង្គោលថ្នាក់ជាតិសម្រាប់បណ្ដុះបណ្ដាលសន្តិសុខស្បៀង និងអាហារូបត្ថម្ភ រៀបចំវគ្គបណ្ដុះបណ្ដាលគ្រូបង្គោល និងបង្កើតឱ្យមានកម្មវិធីបណ្ដុះបណ្ដាលស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភដល់បុគ្គលិកនៅតាមក្រសួង-ស្ថាប័ន។ គំនិតផ្ដួចផ្ដើមនេះគឺជាមធ្យោ-

បាយគន្លឹះសម្រាប់ពង្រឹងសមត្ថភាពខាងផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ហើយត្រូវបានរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទឯកភាពជាគោលការណ៍។

- ពង្រឹងរចនាសម្ព័ន្ធផែនការនៅតាមក្រសួង-ស្ថាប័នរដ្ឋដើម្បីកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ : អនុអង្គភាពផែនការសម្រាប់ការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភចាំបាច់គួរតែបង្កើតឡើងនៅក្នុងនាយកដ្ឋានផែនការដែលមានស្រាប់នៃក្រសួង-ស្ថាប័នរដ្ឋ ដែលមានតួនាទីសំខាន់ក្នុងការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភ រួមមានៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី ក្រសួងផែនការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងពាណិជ្ជកម្ម [៨១] ។
- បង្កើនកិច្ចសហប្រតិបត្តិការតាមក្រសួង-ស្ថាប័នដើម្បីបញ្ជ្រាបបញ្ហាយេនឌ័រឱ្យបានកាន់តែប្រសើរទៅក្នុងគម្រោងអន្តរាគមន៍លើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ : ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទត្រូវជួយសម្រួលកិច្ចសហប្រតិបត្តិការរវាងក្រសួងកិច្ចការនារីនិងក្រសួងដែលជាសមាជិករបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទផ្សេងៗទៀតដើម្បីដោះស្រាយឱ្យបានកាន់តែប្រសើរនូវសមាសធាតុយេនឌ័រនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

### ៤.៥.២. ការបញ្ជ្រាបបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភទៅក្នុងដំណើរការរៀបចំផែនការវិមជ្ឈការ

#### ស្ថានភាព និងសន្និទានភាព

នៅថ្នាក់ខេត្ត ស្រុក និងឃុំ បញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភមិនត្រូវបានបញ្ចូលឱ្យបានគ្រប់ជ្រុងជ្រោយទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍មូលដ្ឋានតាមបែបវិមជ្ឈការទេ ។ ទន្ទឹមនឹងនេះ រដ្ឋាភិបាលថ្នាក់ខេត្ត និងក្រុមប្រឹក្សាឃុំ-សង្កាត់ ជារឿយៗតែងតែព្យាយាមលើកឡើងអំពីបញ្ហាអសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភនៅក្នុងសហគមន៍របស់ខ្លួន (ឧ. ការអភិវឌ្ឍន៍វិស័យកសិកម្ម ការកសាងផ្លូវលំ ការជួសជុល ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ និងការកែលម្អការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ)។ ដូច្នេះ យើងចាំបាច់គួរតែធ្វើការឧបត្ថម្ភគាំទ្របន្ថែមទៀតដល់រដ្ឋាភិបាលថ្នាក់ខេត្ត និងក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីវាយតម្លៃ និងវិភាគស្ថានភាពសន្តិសុខស្បៀងឱ្យបានកាន់តែប្រសើរ នៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍មូលដ្ឋានតាមបែបវិមជ្ឈការ និងដើម្បីជួយណែនាំអំពីរបៀបធ្វើផែនការ និងការអនុវត្តគម្រោងអន្តរាគមន៍ផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

មានមូលហេតុមួយចំនួនដែលបណ្តាលឱ្យការបញ្ចូលបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍មូលដ្ឋានតាមបែបវិមជ្ឈការមិនបានគ្រប់គ្រាន់ គឺ : ទី១-សមត្ថភាពក្នុងការវិភាគ

---

[៨១] នេះមិនមានពាក់ព័ន្ធនឹងការបង្កើនចំនួនបុគ្គលិកផែនការ ប៉ុន្តែពាក់ព័ន្ធនឹងការបង្កើតអង្គភាពផែនការដែលមានតួនាទីច្បាស់លាស់ និងភារកិច្ចទទួលខុសត្រូវក្នុងការកែលម្អ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅក្នុងក្រសួងនានា ។ អង្គភាពនេះមានភារកិច្ច : ១-ពិនិត្យមើលឡើងវិញនូវផែនការរបស់ក្រសួង និងផ្តល់យោបល់ផ្សេងៗ ដើម្បីឱ្យសកម្មភាពទាំងឡាយមានឥទ្ធិពលដោយផ្ទាល់ទៅលើសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ២-រៀបចំអនុផែនការសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រាប់ក្រសួងនីមួយៗ ៣-ជួយក្រសួងក្នុងការកំណត់គោលដៅធ្វើសកម្មភាពដើម្បីជួយដល់គ្រួសារអសន្តិ-សុខស្បៀង ៤-ដើរតួនាទីជាកន្លែងសម្រាប់ទំនាក់ទំនងជាអចិន្ត្រៃយ៍សម្រាប់សម្របសម្រួលជាមួយអ្នកពាក់ព័ន្ធនឹង សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ហើយត្រួតពិនិត្យសកម្មភាពរបស់ក្រសួងឱ្យស្របតាមទស្សនទាន សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។

បញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការរៀបចំផែនការរបស់អាជ្ញាធរមូលដ្ឋានថ្នាក់ខេត្ត និងថ្នាក់ឃុំ-សង្កាត់នៅមានកម្រិត ។ ទី២-នីតិវិធី និងយន្តការក្នុងការបញ្ចូលបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភឱ្យបានទូលំទូលាយទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍មូលដ្ឋាននៅមានការខ្វះខាត ។ ទី៣-គណៈកម្មាធិការសម្របសម្រួលអាហារូបត្ថម្ភខេត្តមិនដំណើរការ និងមិនមានអាណត្តិគ្រប់គ្រាន់សម្រាប់ដោះស្រាយរាល់សមាសធាតុនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្រិតថ្នាក់ខេត្ត ។ សកម្មភាពជាអាទិភាពដើម្បីដោះស្រាយឧបសគ្គទាំងនេះផ្តោតលើការកសាងសមត្ថភាពនិងយន្តការនានា និងការបង្កើនការឧបត្ថម្ភគាំទ្រសម្រាប់រចនាសម្ព័ន្ធសម្របសម្រួលនានានៅថ្នាក់ខេត្ត ក្នុងការបញ្ចូលបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភឱ្យបានកាន់តែប្រសើរទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍មូលដ្ឋាន។

**សកម្មភាពអាទិភាព**

- កសាងសមត្ថភាព នីតិវិធី និងយន្តការដើម្បីបញ្ចូលបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ឱ្យបានកាន់តែទូលំទូលាយទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍មូលដ្ឋាន ៖ បញ្ហានេះអាចសម្រេចបាន តាមរយៈសហប្រតិបត្តិការរវាងក្រសួងមហាផ្ទៃ និងរដ្ឋបាលមូលដ្ឋានខេត្ត (គណៈកម្មាធិការប្រតិបត្តិខេត្ត មន្ទីរផែនការ គណៈកម្មាធិការខេត្តគ្រប់គ្រងគ្រោះមហន្តរាយ និងក្រុមប្រឹក្សាឃុំ-សង្កាត់) និងស្ថាប័ននានាដែលមានជំនាញខាងផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភ[៨២] ។
- ក្រសួងផែនការចាំបាច់គួរតែធ្វើឱ្យដំណើរការឡើងវិញនូវគណៈកម្មាធិការសម្របសម្រួលអាហារូបត្ថម្ភខេត្តនៅទូទាំងប្រទេស ហើយផ្តល់អាណត្តិឱ្យកាន់តែទូលំទូលាយបន្ថែមទៀត ដើម្បីដោះស្រាយរាល់បញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (ភាពមានស្បៀង ភាពទទួលបានស្បៀង ការប្រើប្រាស់ និងការបឺតស្រូបស្បៀង និងស្ថេរភាពស្បៀង) សម្រាប់ខេត្តនីមួយៗ។ ដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការបំពេញការងារ យើងចាំបាច់គួរតែពង្រឹងសមត្ថភាពរបស់សមាជិកគណៈកម្មាធិការសម្របសម្រួលអាហារូបត្ថម្ភខេត្ត តាមរយៈវិធានការបណ្តុះបណ្តាលសមស្រប[៨៣] ។
- ពង្រីកវគ្គបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅថ្នាក់ខេត្ត (ដោយផ្អែកលើកម្មវិធី និងសម្ភារៈបណ្តុះបណ្តាល ដែលរៀបចំដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងកម្មវិធីភាពជាដៃគូរវាងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ និងប្រទេស ហូឡង់) ឱ្យបាន

---

៨២ វឌ្ឍនភាពថ្មីៗក្នុងការគាំទ្រដល់ការកសាងសមត្ថភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ រួមមាន៖ វគ្គបណ្តុះបណ្តាលថ្នាក់ខេត្តស្តីពី សន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅតាកែវ និង ការបណ្តុះបណ្តាល បុគ្គលិកមកពីក្រសួង និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនសម្រាប់ធ្វើការបណ្តុះបណ្តាលបន្តនៅថ្នាក់មូលដ្ឋាន ។ គោលបំណងនៃវគ្គបណ្តុះបណ្តាល គឺដើម្បីផ្តល់ចំណេះដឹង និងគោលគំនិតជាមូលដ្ឋានដល់មន្ត្រីជាន់ខ្ពស់ (អ្នកធ្វើផែនការ និងអ្នកធ្វើការសម្រេចចិត្ត) មកពីមន្ទីរ កម្មវិធីនិងគម្រោងនានា នៅថ្នាក់ខេត្ត តាមរយៈ ៖ ១-បង្កើនការយល់ដឹងអំពីគោលគំនិត និងសារសំខាន់នៃបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភដែលជាបញ្ហាពហុវិស័យសម្រាប់ការកាត់បន្ថយ ភាពក្រីក្រនិងការអភិវឌ្ឍន៍ ២-គាំទ្រដល់អ្នកធ្វើការសម្រេចចិត្តក្នុងការអភិវឌ្ឍន៍សមត្ថភាព និង ការបញ្ជ្រាប សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទៅក្នុងផែនការអភិវឌ្ឍន៍មូល-ដ្ឋាន និង ៣-រៀបចំមូលដ្ឋានគ្រឹះសម្រាប់ការ សម្របសម្រួលបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅថ្នាក់ខេត្ត ។ ធនធានដ៏សំខាន់មួយទៀតគឺវគ្គបណ្តុះបណ្តាលពី ចម្ងាយស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភរៀបចំដោយកម្មវិធីសន្តិសុខស្បៀងរបស់អង្គការ EC/FAO ។

៨៣ វគ្គបណ្តុះបណ្តាលពីចម្ងាយស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ របស់កម្មវិធីសន្តិសុខស្បៀងរបស់អង្គការ EC/FAOគួរតែបន្ថែមម៉ូឌុល (មេរៀន) មួយទៀតស្តីពីការកំណត់គោលដៅ

ដល់ខេត្តមួយចំនួនបន្ថែមទៀត ដោយផ្តល់អាទិភាពទៅដល់ខេត្តមានបញ្ហាអសន្តិសុខស្បៀងជាងគេ។ រៀបចំមេរៀនជាពិសេសសម្រាប់ខេត្តនៅតាមតំបន់ខ្ពង់រាប ដែលមានជនជាតិភាគតិចរស់នៅច្រើន ហើយដែលមានបញ្ហាក្រីក្រនិងអសន្តិសុខស្បៀងជាងគេ ។ លើសពីនេះទៀត យើងចាំបាច់គួរតែជួយសម្រួលលទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតរបស់អ្នកពាក់ពន្ធ័នៅថ្នាក់ខេត្ត ដើម្បីឱ្យពួកគាត់អាចទទួលបានការបណ្តុះបណ្តាល ពីចម្ងាយស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ[៨៤] ។

### ៤.៥.៣. ការកែលម្អការគ្រប់គ្រងព័ត៌មានពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការកំណត់គោលដៅអន្តរាគមន៍លើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

**ស្ថានភាព និងសន្និទានភាព**

បច្ចុប្បន្ន រដ្ឋាភិបាលនៅខ្វះប្រព័ន្ធកំណត់គោលដៅដែលមានស្តង់ដារសម្រាប់កំណត់តំបន់ភូមិសាស្ត្រអសន្តិសុខស្បៀង និងក្រុមជនងាយរងគ្រោះនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់សហគមន៍ ។ ប្រព័ន្ធនេះនឹងជួយសម្រួលដល់ការកំណត់គោលដៅ និងការធ្វើផែនការសម្រាប់អន្តរាគមន៍លើផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។ នៅកម្រិតថ្នាក់ជាតិ មានវឌ្ឍនភាពខ្លះៗ នៅក្នុងការបង្កើតប្រព័ន្ធព័ត៌មាន និងផែនទីតំបន់អសន្តិសុខស្បៀង និងភាពងាយរងគ្រោះ (FIVIMS) ។ ប៉ុន្តែ FIVIMS ប្រឈមមុខនឹងឧបសគ្គមួយចំនួន ហើយមិនទាន់មានលទ្ធផលជាផ្លែផ្កានៅឡើងក្នុងការកំណត់គោលដៅសម្រាប់អន្តរាគមន៍លើផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅឡើយទេ។

ស្របពេលជាមួយគ្នានេះដែរ គម្រោងអន្តរាគមន៍អភិវឌ្ឍន៍របស់រដ្ឋាភិបាល ដែលទាក់ទងនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភត្រូវបានកំណត់គោលដៅដោយប្រើប្រាស់ប្រព័ន្ធកំណត់គោលដៅខុសៗគ្នា។ មានប្រព័ន្ធកំណត់គោលដៅរបស់ក្រសួង ដែលប្រើសម្រាប់តែបម្រើវិស័យផ្ទាល់របស់ក្រសួង ហើយជារឿយៗ ប្រព័ន្ធនេះបានមកពីការវិភាគលើស្ថិតិមិនគ្រប់ជ្រុងជ្រោយរបស់រដ្ឋាភិបាល ។ ជារឿយៗ ផលិតផលដែលជាប្រព័ន្ធកំណត់អត្តសញ្ញាណ និងកំណត់គោលដៅរបស់អង្គការសហប្រជាជាតិ [ដូចជាៈ ឯកសារផែនទីវាយតម្លៃនិងកំណត់ទីតាំងភាពងាយរងគ្រោះ (VAM) របស់អង្គការកម្មវិធីស្បៀងអាហារពិភពលោក (WFP)] ត្រូវបានប្រើប្រាស់ដោយក្រសួងនានា ដើម្បីជួយកំណត់គោលដៅសម្រាប់អន្តរាគមន៍ផ្សេងៗ ។ ក្នុងករណីខ្លះ ក្រសួងធ្វើអន្តរាគមន៍លើផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយគ្មានការកំណត់គោលដៅឱ្យមានលក្ខណៈជាប្រព័ន្ធទូវក្រុមប្រជាពលរដ្ឋអសន្តិសុខស្បៀង។

នៅកម្រិតបន្ទាប់ពីថ្នាក់ជាតិ ( ថ្នាក់ខេត្ត-ក្រុង) និងនៅកម្រិតសហគមន៍ ប្រព័ន្ធកំណត់គោលដៅសន្តិសុខស្បៀង និងអាហារូបត្ថម្ភតាមបែបវិមជ្ឈការមិនទាន់មានគ្រប់គ្រាន់នៅឡើយ នៅក្នុងតំបន់ភាគច្រើន នៃប្រទេស។ នេះគឺជាចំណុចដ៏សំខាន់មួយនៃបញ្ហាកង្វះខាតក្នុងការបញ្ចូលសន្តិសុខស្បៀង និងអាហារូបត្ថម្ភទៅក្នុងដំណើរការរៀបចំផែនការវិមជ្ឈការ ដូចដែលបានលើកឡើងខាងលើ ។ លើសពីនេះទៀត មានការលើកឡើងអំពីសារសំខាន់នៃការចូលរួមរបស់សង្គមស៊ីវិលនៅមូលដ្ឋាន ក្នុងការកំណត់អត្តសញ្ញាណ និងការកំណត់គោលដៅសម្រាប់កិច្ចខិតខំប្រឹងប្រែងកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងសហគមន៍ផ្ទាល់របស់ពួកគាត់ ។

---

[៨៤] ឧទាហរណ៍ៈ វគ្គបណ្តុះបណ្តាលដែលឧបត្ថម្ភដោយ អង្គការ EC/FAO

កិច្ចការជាអាទិភាពដើម្បីដោះស្រាយឧបសគ្គទាំងនេះ ផ្តោតសំខាន់ទៅលើការបង្កើតឡើងបន្ថែមទៀតនូវប្រព័ន្ធកំណត់អត្តសញ្ញាណ និងកំណត់គោលដៅនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានសម្រាប់ក្រុមប្រជាពលរដ្ឋអសន្តិសុខស្បៀង និងសម្រាប់ការឧបត្ថម្ភគាំទ្រនានាដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងសង្គមស៊ីវិលនៅថ្នាក់មូលដ្ឋាន ។

វឌ្ឍនភាពថ្មីៗរួមមាន : ការរៀបចំសិក្ខាសាលាជាតិមួយ នៅក្នុងឆ្នាំ២០០៦ ដើម្បីដោះស្រាយបញ្ហាប្រពន្ធ័គ្រប់គ្រងព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។ សិក្ខាសិលានោះបានធ្វើការសន្និដ្ឋានថា ភារកិច្ចសំខាន់ៗដែលត្រូវធ្វើ គឺការពង្រឹងសហប្រតិបត្តិការ និងការសម្របសម្រួលក្នុងចំណោមអ្នកពាក់ពន្ធ័នឹងប្រព័ន្ធព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ តាមរយៈក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីប្រើប្រាស់ប្រពន្ធ័គ្រប់គ្រងព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភដែលមានស្រាប់សម្រាប់ផលិតផលថ្មីៗ និងដើម្បីលើកកម្ពស់ ការកសាងសមត្ថភាព[៨៥] ។

ទន្ទឹមនឹងនេះ ក៏មានមានវឌ្ឍនភាពថ្មីៗផងដែរ នៅក្នុងការពង្រឹងប្រពន្ធ័កំណត់គោលដៅសម្រាប់កិច្ចអន្តរាគមន៍លើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅថ្នាក់ខេត្ត និងថ្នាក់សហគមន៍។ វគ្គបណ្តុះបណ្តាលថ្នាក់ខេត្តស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលរៀបចំឡើងដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទសហការជាមួយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ក្នុងក្របខ័ណ្ឌកម្មវិធីភាពជាដៃគូ រវាងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ និងប្រទេសហូឡង់នឹងជួយលើកកម្ពស់ការយល់ដឹងរបស់បុគ្គលិករដ្ឋាភិបាលថ្នាក់ខេត្តអំពីបញ្ហានានាពាក់ព័ន្ធនឹង ការកំណត់អត្តសញ្ញាណ និងការកំណត់គោលដៅ ។

បើនិយាយការកំណត់ភូមិសាស្ត្រនៃក្រុមប្រជាពលរដ្ឋអសន្តិសុខស្បៀងនៅតាមថ្នាក់ខេត្ត និងថ្នាក់ឃុំ-សង្កាត់ យើងចាំបាច់គួរតែធ្វើការសិក្សាស្រាវជ្រាវដល់មូលដ្ឋានបន្ថែមទៀត ដើម្បីប្រមូលទិន្នន័យបឋមស្តីពីបញ្ហាអសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភ។ នៅថ្នាក់ខេត្ត ការអង្កេតប្រជាសាស្ត្រនិងសុខភាព ឆ្នាំ ២០០០ និង ២០០៥ ដែលជាការធ្វើអង្កេតថ្នាក់ជាតិលើកដំបូង បានផ្តល់ជូននូវទិន្នន័យគួរឱ្យជឿទុកចិត្តសម្រាប់បណ្តាខេត្តដែលមានប្រជាពលរដ្ឋច្រើន។ ក៏ប៉ុន្តែ ដូចដែលបានចងក្រងនៅក្នុងរបាយការណ៍សង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ ២០០៥ សម្រាប់បណ្តាខេត្តដែលមានប្រជាពលរដ្ឋតិច លទ្ធផលមិនគួរឱ្យជឿទុកចិត្តប៉ុន្មានទេ ដោយហេតុថាវាអាចមានលទ្ធផលផ្សេងៗ គ្នាជាច្រើន[៨៦] ។

ចំណែកឯនៅថ្នាក់ឃុំ-សង្កាត់ ព័ត៌មានអំពីអត្រាប្រេវ៉ាឡង់នៃកង្វះអាហារូបត្ថម្ភបានមកពីឯកសារប៉ាន់ស្មានភាពក្រីក្រនៅថ្នាក់ឃុំ-សង្កាត់ ឆ្នាំ២០០០ របស់អង្គការកម្មវិធីស្បៀងអាហារពិភពលោក ។ ទិន្នន័យទាំងនេះ

---

៨៥ អ្នកចូលរួមសិក្ខាសាលារួមមាន: FIVIMS នៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ( បច្ចុប្បន្នទទួលការគាំទ្រពីកម្មវិធី"សកម្មភាពសន្តិសុខស្បៀងសម្រាប់ធ្វើសកម្មភាព" របស់អង្គការ EC/FAO ) អង្គភាពធ្វើផែនទី និងការវិភាគភាពងាយរងគ្រោះ(VAM) របស់អង្គការ WFP ប្រព័ន្ធ ព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ របស់ *កកជ* ( បច្ចុប្បន្នទទួលការគាំទ្រពីគម្រោង FNPP/FAO) និង វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ( បច្ចុប្បន្នទទួល ការគាំទ្រពីអង្គការ UNICEF និង GTZ ) ។

៨៦ នេះដោយសារតែទំហំគំរូនៃខេត្តទាំងនេះតូច ហើយការចងក្រងលទ្ធផលនៃការអង្កេតប្រជាសាស្ត្រនិងសុខភាពត្រូវបានបញ្ចូលទៅក្នុងខេត្តច្រើន ។ លើសពីនេះទៅទៀត បើតាមលទ្ធផលផ្អែកលើស្ទង់មតិដែលមាន វាហាក់បីដូចជា៖ថា ខេត្តតូចៗមានប្រជាពលរដ្ឋតិចទាំងនេះមានអត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភខ្ពស់ នៅក្នុងប្រទេស ។ ខេត្តទាំងនេះភាគច្រើននៅតាមតំបន់ខ្ពង់រាប និង តំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា ហើយជាខេត្តដែលមានជនជាតិដើមភាគតិចតំបន់ខ្ពង់រាបរស់នៅច្រើន ។

គឺជាការប៉ាន់ស្មានដែលមានលក្ខណៈមិនផ្ទាល់អំពីអត្រានៃភាពក្រីក្រ និងទម្ងន់ស្រាល[៨៧] ។ តាមពិតទៅ យើងចាំបាច់គួរតែមានព័ត៌មានពិសេសបន្ថែមទៀតពាក់ព័ន្ធនឹងអសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភនៅថ្នាក់ឃុំ-សង្កាត់ យ៉ាងហោចណាស់ក៏នៅក្នុងឃុំ-សង្កាត់ដែលមានបញ្ហាអសន្តិសុខស្បៀងជាងគេ ។

ចំពោះការកំណត់គោលដៅសម្រាប់ជំនួយសង្គមកិច្ច ក្រសួងផែនការបាននិងកំពុងបង្កើតអភិក្រមជាតិមួយសម្រាប់កំណត់អត្តសញ្ញាណប្រជាពលរដ្ឋក្រីក្រនៅតាមគ្រួសារនីមួយៗ។ សកម្មភាពនានាក្នុងការកសាងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងតំណាងភូមិ ដើម្បីអនុវត្តលក្ខណៈវិនិច្ឆ័យ និងនីតិវិធីរួមសម្រាប់ការកំណត់អត្តសញ្ញាណនៃក្រុមគ្រួសារក្រីក្រ និងអសន្តិសុខស្បៀងបានចាប់ផ្តើមធ្វើចាប់តាំងពីឆ្នាំ២០០៥មក។ អភិក្រមដែលមានលក្ខណៈចូលរួម និងមានស្តង់ដារត្រឹមត្រូវនេះត្រូវបានអនុវត្តនៅក្នុងឃុំ-សង្កាត់ក្នុងខេត្តចំនួនបីរួចហើយៗចាំបាច់គួរតែធ្វើការពង្រីកឱ្យបានទៅដល់ឃុំ-សង្កាត់ក្រីក្រ និងអសន្តិសុខស្បៀងដទៃទៀត ទូទាំងប្រទេស ។

វឌ្ឍនភាពថ្មីៗមួយទៀតក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើចំណាត់ថ្នាក់សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្រិតថ្នាក់ខេត្ត គឺការបញ្ចប់ជាស្ថាពរនៃការរៀបចំបង្កើត **គេហទំព័រកម្រងផែនទីសន្តិសុខស្បៀងនៅកម្ពុជា** របស់អង្គការកម្មវិធីស្បៀងអាហារពិភពលោក ដែលត្រូវបានបញ្ចូលទៅក្នុងវិបសាយប្រព័ន្ធពត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (http://www.foodsecurity.gov.kh) របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៅក្នុងឆ្នាំ២០០៦ និងការវិភាគលើការធ្វើចំណាត់ថ្នាក់សម្រាប់សន្តិសុខស្បៀង និងសម្រាប់ការផ្តល់ជំនួយមនុស្សធម៌នៅប្រទេសកម្ពុជា របស់អង្គការកម្មវិធីស្បៀងអាហារពិភពលោក។

**សកម្មភាពជាអាទិភាព**

- អនុវត្តគោលការណ៍ និងជំហានជាក់ស្តែងនានាដែលបានឯកភាពនៅក្នុងអង្គសិក្ខាសាលាជាតិ ស្តីពីប្រព័ន្ធផែនទីនិងព័ត៌មានពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភនិងភាពងាយរងគ្រោះកាលពីឆ្នាំ២០០៦ ដើម្បីពង្រឹងទំនាក់ទំនងនិងសហប្រតិបត្តិការសម្រាប់ការកែលម្អប្រពន្ធ័ព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅថ្ងៃអនាគត។ វិធានការទាំងនេះរួមមាន : ការបង្កើតក្រុមការងារមួយដែលដឹកនាំដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទដែលមានគោលបំណងជាក់លាក់ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការ ការកសាងសមត្ថភាពសម្រាប់ធ្វើការវិភាគទិន្នន័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការជំរុញការប្រើប្រាស់វិបសាយប្រព័ន្ធព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (http://www.foodsecurity.gov.kh)របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ជាច្រកសម្រាប់ប្រព័ន្ធព័ត៌មានពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហា-រូបត្ថម្ភដទៃទៀត។
- ធ្វើការស្រាវជ្រាវរិះរកមធ្យោបាយ និងអភិក្រមនានា ដើម្បីបង្កើនភាពញឹកញាប់ និងភាពត្រឹមត្រូវជាក់លាក់នៃការប្រមូលទិន្នន័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងដើម្បីបង្កើនចំណេះដឹងអំពី

[៨៧] ការប៉ាន់ស្មានភាពក្រីក្រនៅថ្នាក់ឃុំ-សង្កាត់ របស់ អង្គការ WFP និង Tomoko Fuji ឆ្នាំ ២០០៣។ ការប៉ាន់ស្មានបានមកពីការអង្កេតប្រជា-សាស្ត្រ និងសុខភាព ឆ្នាំ ២០០៥ និងទិន្នន័យជម្រឿនឆ្នាំ ១៩៩៨ដែលប្រើប្រាស់បច្ចេទេសប៉ាន់ស្មានលម្អិត ។ យោងតាមតម្រូវការវិធីសាស្ត្រសហ-គ្រាសខ្នាតតូចនិងមធ្យម ការធ្វើបច្ចុប្បន្នភាពប្រហែលជាមិនអាចធ្វើបានទេ នៅក្នុងជម្រឿន ឆ្នាំ ២០០៨ ។

បម្រែបម្រួលនៃលទ្ធផលសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងមូលហេតុផ្សេងៗ ទៅតាមតំបន់ភូមិសាស្ត្រ និងក្រុមសេដ្ឋកិច្ច-សង្គម នៅក្នុងប្រទេសកម្ពុជា។

- លេខាធិការដ្ឋានអន្តរក្រសួងសម្រាប់ FIVIMS ចាំបាច់គួរតែដោះស្រាយឧបសគ្គនានាដែលបានជួបប្រទះដើម្បីធ្វើការអភិវឌ្ឍបន្ថែមទៀតនូវប្រព័ន្ធព័ត៌មានសន្តិសុខស្បៀងនិងអាហារូបត្ថម្ភជាតិដូចដែលបានលើកឡើងនៅក្នុងសៀវភៅណែនាំ ១.០ របស់ FIVIMS ។
- វិទ្យាស្ថានជាតិស្ថិតិចាំបាច់គួរតែធ្វើបច្ចុប្បន្នភាពលើ **ការប៉ាន់ស្មានអំពីភាពក្រីក្រ និងកង្វះអាហារូបត្ថម្ភនៅឃុំ-សង្កាត់** កាលពីឆ្នាំ២០០០ ដោយផ្អែកលើជំរឿនថ្មីឆ្នាំ២០០៨ និងទិន្នន័យដែលបានមកពីការអង្កេតសេដ្ឋកិច្ច -សង្គមកម្ពុជា និងការអង្កេតប្រជាសាស្ត្រនិងសុខភាព ។
- វិទ្យាស្ថានជាតិស្ថិតិចាំបាច់គួរតែធ្វើការវិភាគលើការបរិភោគស្បៀងតាមគ្រួសារដោយផ្អែកលើទិន្នន័យដែលបានមកពីការអង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជាថ្មី ។
- ធ្វើបច្ចុប្បន្នភាព កម្រងផែនទីសន្តិសុខស្បៀង (របស់អង្គការស្បៀងអាហារពិភពលោក) ឱ្យបានជាប្រចាំ ហើយត្រូវជំរុញការប្រើប្រាស់កម្រងផែនទីនេះសម្រាប់ការវិភាគគោលនយោបាយ និងសម្រាប់ការកំណត់តំបន់គោលដៅ។
- ពង្រីកគម្រោងសាកល្បងរបស់ក្រសួងផែនការស្តីពីការកំណត់អត្តសញ្ញាណរូម នៃក្រុមគ្រួសារក្រីក្រ ហើយប្រើប្រាស់លទ្ធផលទាំងអស់នោះសម្រាប់កំណត់គោលដៅជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ នៅថ្នាក់សហគមន៍។

## ៥. ការត្រួតពិនិត្យ និងវាយតម្លៃនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

សមាសធាតុសំខាន់នៃការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺការត្រួតពិនិត្យលទ្ធផលដែលសម្រេចបានទៅតាមគោលដៅ និងសូចនាករពាក់ព័ន្ធនានា។ ដោយសារតែបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ជាបញ្ហាពហុវិស័យហើយមានកម្មវិធីជាច្រើនរួមចំណែកដល់ការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ការត្រួតពិនិត្យនឹងជួបប្រទះបញ្ហាប្រឈមនានាជាច្រើន។

ក្របខ័ណ្ឌត្រួតពិនិត្យ ដោយមានសូចនាករសំខាន់ៗសម្រាប់លទ្ធផលទូទៅនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងគោលបំណងទាំងប្រាំនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភត្រូវបានបង្ហាញជូននៅក្នុងតារាង១១ ។ ដូច្នេះ ការត្រួតពិនិត្យមើលវឌ្ឍនភាពនៃការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភមានលក្ខណៈសាមញ្ញ ហើយលទ្ធផលទាំងឡាយអាចត្រូវបានប្រមូលផ្តុំចងក្រងជារបាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំបានយ៉ាងងាយស្រួល ។ របាយការណ៍នេះនឹងត្រូវផ្ញើទៅគ្រប់ក្រសួង-ស្ថាប័ន និងក្រុមការងារបច្ចេកទេសពាក់ព័ន្ធទាំងអស់ ហើយនឹងត្រូវផ្សព្វផ្សាយតាមវិបសាយប្រព័ន្ធពត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

ក្របខ័ណ្ឌត្រួតពិនិត្យសម្រាប់ក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបានចងក្រងចេញពីប្រពន្ធ័ត្រួតពិនិត្យដែលមានស្រាប់ រួមមាន : ក្របខ័ណ្ឌត្រួតពិនិត្យទិសដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា គោលដៅធំៗ និងសូចនាករសំខាន់នៃ*ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* គោលដៅតាមវិស័យដែលមាននៅក្នុង*ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* ការសិក្សាអង្កេតជំនាញឯកទេសរបស់វិទ្យាស្ថានជាតិស្ថិតិ ដូចជា : ការអង្កេតប្រជាសាស្ត្រនិងសុខភាព និងការអង្កេតសេដ្ឋកិច្ច-សង្គម ព្រមទាំងប្រភពព័ត៌មានពាក់ព័ន្ធផ្សេងៗទៀតជាច្រើន (ដូចមានបង្ហាញជូននៅក្នុងតារាង ១០) ។

សូចនាករទាំងឡាយនៃក្របខ័ណ្ឌត្រួតពិនិត្យសម្រាប់ក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀងនិងអាហារូបត្ថម្ភធ្វើការតាមដានលើបម្រែបម្រួលនានានៅកម្រិតថ្នាក់ជាតិ និងនៅថ្នាក់ខេត្ត ដែលបម្រែបម្រួលទាំងនេះអាចបង្ហាញអំពីរូបភាពមួយនៃវឌ្ឍនភាពជាទូទៅក្នុងការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់ប្រជាពលរដ្ឋកម្ពុជា។ ការពង្រឹងបន្ថែមការត្រួតពិនិត្យក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភអាចសម្រេចបាន តាមរយៈការប្រើប្រាស់ទិន្នន័យនៅថ្នាក់មូលដ្ឋាន (ឃុំ-ភូមិ)[៨៨] និងតាមរយៈការធ្វើវិភាគឱ្យបានជាក់លាក់បន្ថែមទៀតទៅលើទិន្នន័យពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងក្របខ័ណ្ឌប្រព័ន្ធព័ត៌មានពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (FIVIMS) ។

---

[៨៨] មានទិន្នន័យតិចតួចនៅថ្នាក់មូលដ្ឋាន ហើយការប្រមូលទិន្នន័យដោយផ្ទាល់ពីមូលដ្ឋានអាចមានសុក្រឹត្យភាពជាង ប៉ុន្តែត្រូវចំណាយច្រើន ។ ទោះបីជាយ៉ាងណាក្តី យើងអាចប្រមូលចងក្រងទិន្នន័យស្តីពីស្ថានភាព សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅថ្នាក់ឃុំ តាមរយៈការបញ្ចូលទិន្នន័យដែលបានមកពីការអង្កេតសេដ្ឋកិច្ច-សង្គម កម្ពុជា ឬការអង្កេតប្រជាសាស្ត្រនិងសុខភាព ជាមួយនឹងទិន្នន័យដែលបានមកពីការធ្វើជំរឿន ។ លើសពីនេះទៀត មូលដ្ឋានទិន្នន័យដែលបានមកពីគម្រោង កំណត់អត្តសញ្ញាណក្រុមគ្រួសារក្រីក្រ នៅក្រសួងផែនការអាចជាប្រភពទិន្នន័យដ៏មានតម្លៃសម្រាប់ការត្រួតពិនិត្យមើលស្ថានភាព សន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅថ្នាក់ស្រុក និងឃុំ នានាពេលអនាគត ។

## តារាង ១០: ទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌឬប្រភពទិន្នន័យសម្រាប់ត្រួតពិនិត្យក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

| គោលដៅ/គោលបំណងនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ | ប្រពន្ធ័ត្រួតពិនិត្យ | សំគាល់ |
|---|---|---|
| ***គោលដៅក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភឆ្នាំ២០០៨ :*** ត្រឹមឆ្នាំ ២០១២ ប្រជាពលរដ្ឋកម្ពុជាក្រីក្រ និងអសន្តិសុខស្បៀងនឹងមានលទ្ធភាពល្អប្រសើរច្រើនទាំងផ្នែករូបវ័ន្ត និងផ្នែកសេដ្ឋកិច្ចក្នុងការទទួលបានស្បៀងអាហារមានសុវត្ថិភាព និងមានជីវជាតិគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការរបបអាហារនិងចំណង់ចំណូលចិត្តនៅគ្រប់ពេលវេលាទាំងអស់ សម្រាប់ជីវិតរស់នៅ យ៉ាងសកម្ម និងមានសុខភាពមាំមួន ។ | ក្របខ័ណ្ឌត្រួតពិនិត្យគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា<br>ការអង្កេតប្រជាសាស្ត្រនិងសុខភាព ឆ្នាំ២០០០, ២០០៥និង ២០១០<br>ចំណុចដៅវិស័យសុខាភិបាលក្នុង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាតិ* | គោលដៅ ១-៨<br>តារាង៤.៥នៃ *ផែនការយុទ្ធ-សាស្ត្រអភិវឌ្ឍន៍ជាតិ* |
| **គោលបំណងទី១:**<br>ក្រុមគ្រួសារអសន្តិសុខស្បៀង**បង្កើនភាពមានស្បៀង** តាមរយៈផលិតកម្មកសិកម្មនិងបសុសត្វ និងតាមរយៈធនធានជលផល និង អនុផលព្រៃឈើ ។ | ក្របខ័ណ្ឌត្រួតពិនិត្យគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា<br>គោលដៅធំៗនិងសូចនាករសំខាន់ៗនៃ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*<br>ចំណុចដៅវិស័យកសិកម្ម នៃ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*<br>ស្ថិតិកសិកម្មប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>ការអង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជាឆ្នាំ២០០៤ និងការអង្កេតក្រោយៗទៀត<br>ជំរឿនកសិកម្ម ឆ្នាំ ២០០៨ | គោលដៅ ១,២,៧ និង ៨<br>សូចនាករ *ផែនការយុទ្ធសាស្ត្រអភិ-វឌ្ឍន៍ជាតិ*៤,៥,៦,២៤,៤០និង៤១<br>តារាង ៤.២នៃ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*<br>មានការវិភាគលើតុល្យភាពស្រូវនៅថ្នាក់ឃុំ |
| **គោលបំណងទី២:** ក្រុមគ្រួសារអសន្តិសុខស្បៀង**បង្កើនភាពទទួលបានស្បៀង**តាមរយៈការបង្កើនប្រាក់ចំណូលក្នុងគ្រួសារ | ក្របខ័ណ្ឌត្រួតពិនិត្យគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា<br>គោលដៅធំៗនិងសូចនាករសំខាន់ៗនៃ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*<br>ចំណុចដៅវិស័យកសិកម្មនិងអភិវឌ្ឍន៍ជនបទនៃ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*<br>ការអង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជា ឆ្នាំ២០០៤ និងការអង្កេតក្រោយៗទៀត<br>ជំរឿនកសិកម្ម ឆ្នាំ២០០៨ | គោលដៅ ១ និង ៣<br>សូចនាករ *ផែនការយុទ្ធសាស្ត្រអភិ-វឌ្ឍន៍ជាតិ* ១,២,៣,២១, ៣២, ៣៣,៣៤ និង៤២<br>តារាង ៤.២ និង ៤.៣ នៃ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* |
| **គោលបំណងទី៣:** ក្រុមគ្រួសារអសន្តិសុខស្បៀង**កែលម្អការប្រើប្រាស់និងការបឺតស្រូបស្បៀង** ដើម្បីកាត់បន្ថយបញ្ហាកង្វះអាហារូបត្ថម្ភ ជំងឺដង្កាត់ និងមរណភាព ជាពិសេសក្នុងចំណោមស្ត្រី និងកុមារ ។ | ក្របខ័ណ្ឌត្រួតពិនិត្យគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា<br>គោលដៅធំៗ និងសូចនាករសំខាន់ៗនៃ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*<br>ចំណុចដៅវិស័យ កសិកម្ម អភិវឌ្ឍន៍ជនបទ អប់រំ និង សុខាភិបាលនៃ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*<br>ការអង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០០០,២០០៥ និង ការអង្កេតក្រោយៗទៀត | គោលដៅ២,៣,៤,៥ និង ៦<br>សូចនាករ *ផែនការយុទ្ធសាស្ត្រអភិ-វឌ្ឍន៍ជាតិ* ៧-១៥, ២២ និង២៣<br>តារាង ៤.៣, ៤.៤ និង៤.៥នៃ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* |
| **គោលបំណងទី៤:** ការកែលម្អបណ្តាញសុវត្ថិភាពសង្គម និងការលើកកម្ពស់សមត្ថភាពរបស់ក្រុមគ្រួសារអសន្តិសុខ-ស្បៀងក្នុងការដោះស្រាយហានិភ័យផ្សេងៗ នឹងជួយ**បង្កើនស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀង** ។ | ការអង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០០០,២០០៥ និង ការអង្កេតក្រោយៗទៀត<br>ស្ថិតិកសិកម្មប្រចាំឆ្នាំ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>ចំណុចដៅវិស័យកសិកម្ម នៃ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*<br>ការអង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជា ឆ្នាំ២០០៤ និងការអង្កេតក្រោយៗទៀត<br>ជំរឿនកសិកម្ម ឆ្នាំ ២០០៨ | |
| **គោលបំណងទី៥: កែលម្អបរិស្ថានគោលនយោបាយ និងស្ថាប័ន** ដើម្បីសម្រេចបានការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា។ | | |

## តារាង ១១: ក្របខ័ណ្ឌត្រួតពិនិត្យសម្រាប់ក្របខណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

| សូចនាករបង្ហាញពីលទ្ធផលទូទៅនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ * | ២០០៥ | ២០១០ | ចំណុចដៅ CMDG ឆ្នាំ២០១៥ |
|---|---|---|---|
| គោលដៅក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ឆ្នាំ២០០៨ : *ត្រឹមឆ្នាំ ២០១២ ប្រជាពលរដ្ឋកម្ពុជាក្រីក្រ និងអសន្តិសុខស្បៀងនឹងមានលទ្ធភាពល្អប្រសើរច្រើន ទាំងផ្នែករូបវ័ន្ត និងផ្នែកសេដ្ឋកិច្ចក្នុងការទទួលបានស្បៀងអាហារមានសុវត្ថិភាព និងមានជីវជាតិគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការរបបអាហារ និងចំណង់ចំណូលចិត្តនៅគ្រប់ពេលវេលាទាំងអស់ សម្រាប់ជីវិតរស់នៅ យ៉ាងសកម្ម និង មានសុខភាពមាំមួន ។* | | | |
| CMDG ១.៦: ភាពក្រិន ( កម្ពស់ធៀបនឹងអាយុ < -២SD ក្មេងអាយុក្រោម៥ឆ្នាំ )( % ) | ៣៧ | ២៨ | ២២ |
| CMDG ១.៤: ទម្ងន់ស្រាល ( កម្ពស់ធៀបនឹងអាយុ < -២SD ក្មេងអាយុក្រោម៥ឆ្នាំ )( % ) | ៣៦ | ២៩ | ២២ |
| CMDG ១.៧: ស្គមស្គាំង ( ទម្ងន់ធៀបនឹងកម្ពស់ < -២SD ក្មេងអាយុក្រោម៥ឆ្នាំ )( % ) | ៧ | ១០ | ៩ |
| CMDG ១.៨ គ្រួសារប្រើប្រាស់អំបិលអ៊ីយ៉ូដ ( % ) | ៧៣ | ៩០ | ៩០ |
| CDHS: អត្រាប្រេវ៉ាឡង់បញ្ហាស្លេកស្លាំងដោយសារកង្វះជាតិដែកនៃកុមារមានអាយុ ៦-៥៩ ខែ | ៦២ | | |
| CMDG ៤.៤: កុមារអាយុ ៦-៥៩ ខែ ទទួលគ្រាប់ថ្នាំជីវជាតិអា ( % ) | ៣៥ | ៨០ | ៩០ |
| CMDG ៤.៦: ទារកដែលទទួលទឹកដោះម្តាយតែមួយមុខ រហូតដល់អាយុ ៦ខែ ( % ) | ៦០ | ៣៤ | ៤០ |
| CMDG ៥.៧: ស្ត្រីមានអាយុ១៥-៤៩ឆ្នាំដែលមានសន្ទស្សន៍ម៉ាស់រាងកាយ (BMI)<១៨ គ.ក្រ/ | ២០ | ១២ | ៨ |
| CMDG ៥.៨: ស្ត្រីមានអាយុ ១៥-៤៩ឆ្នាំ ដែលមានបញ្ហាស្លេកស្លាំងដោយសារកង្វះជាតិដែក | ៤៧ | ៣២ | ១៩ |
| កម្មវិធីអាហារូបត្ថម្ភជាតិ : អត្រាប្រេវ៉ាឡង់នៃបញ្ហាស្លេកស្លាំងដោយសារកង្វះជាតិដែក ( % ) | ៦២ | ៥២* | ៤២* |
| គោលបំណងទី១: *ក្រុមគ្រួសារអសន្តិសុខស្បៀងបង្កើនភាពមានស្បៀង តាមរយៈផលិតកម្មកសិកម្មនិងបសុសត្វ និងតាមរយៈធនធានជលផល និងអនុផលព្រៃឈើ ។* | | | |
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:* ទិន្នផលស្រូវក្នុងមួយហិកតា (តោន) | ១៩.៧ | ២.៤ | |
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:* កំណែទម្រង់ដីធ្លី: ផ្តល់កម្មសិទ្ធិដីធ្លីជូនកសិករ (%នៃផ្ទៃដីកសិកម្មសរុប) | ១២ | ២៤ | |
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:* គម្របព្រៃឈើ ( %នៃផ្ទៃដីសរុប) | ៦០ | ៥៨ | ៦០ |
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:* ផ្ទៃដីដែលបានបោសសំអាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ( % ) | ៥៣.៣ | ៧៧ | ១០០ |
| CamInfo: %នៃគ្រួសារកសិករនៅជនបទគ្មានដីកសិកម្ម | ១៦ | | |
| CMDG ៧.៦: ឡូនេសាទកាត់ទៅឱ្យសហគមន៍មូលដ្ឋាន ( % ) | ៥៦ | ៦០ | ៦០ |
| CMDG ៧.៧: ចំនួនសហគមន៍នេសាទ | ៣៧៥ | ៤៦៤ | ៥៨៩ |
| CMDP ៧.៨ : ផ្ទៃក្រឡាតំបន់អភិរក្សត្រី ( ពាន់ ហ.ត) | អត់ព័ត៌មាន | ៥៨១ | ៥៨១ |
| គោលបំណងទី២: *ក្រុមគ្រួសារអសន្តិសុខស្បៀងបង្កើនភាពទទួលបានស្បៀង តាមរយៈការបង្កើនប្រាក់ចំណូលក្នុងគ្រួសារ ។* | | | |
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:* កម្រិតនៃភាពក្រីក្រ ( %នៃប្រជាពលរដ្ឋទាំងអស់) ឆ្នាំ ២០០៤<br>- ក្នុង ៩៩% នៃផ្ទៃប្រទេសដែលបានធ្វើការអង្កេត ឆ្នាំ ១៩៩៣/១៩៩៤ | ៣៤.៧ (២៨.០) | ២៥ | ១៩.៥ |
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:* កម្រិតនៃភាពក្រីក្រ ( %នៃប្រជាពលរដ្ឋនៅជនបទ) ឆ្នាំ ២០០៤<br>- ក្នុង ៩៩% នៃផ្ទៃប្រទេសដែលបានធ្វើការអង្កេត ឆ្នាំ ១៩៩៣/១៩៩៤ | ៣៩.២ ( ៣៣.៧) | | |
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:* ប្រជាពលរដ្ឋរស់នៅក្រោមបន្ទាត់ភាពក្រីក្រស្បៀង ( % ) ឆ្នាំ២០០៤<br>- ក្នុងតំបន់ដែលបានធ្វើការអង្កេត ឆ្នាំ ១៩៩៣/១៩៩៤ | ១៩.៧ (១៤.២) | ១៣ | ១០ |
| CMDG 1.2 : ចំណែកនៃគ្វីនថាយក្រីក្របំផុត ក្នុងការបរិភោគស្បៀងនៅកម្រិតថ្នាក់ជាតិ ( % ) | ៧ | ១០ | ១១ |
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:* ចំណែកនៃពលកម្មរកកម្រៃរបស់ស្ត្រី ( ក្នុងវិស័យកសិកម្ម ឧស្សាហកម្ម សេវាកម្ម ( % ) | ៥២.៩,៥៣.៣.២៧ .0 | ៥០,៥០,៣៧ | ៥០,៥០,៥០ |
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:* ផ្លូវលំជនបទទទួលការជួសជុល គិតជាគីឡូម៉ែត្រ ( ក្នុងចំនួនសរុប ២៨០០០គ.ម ) | ២២៧០០ | ២៥០០០ | ២៨០០០ |

| | | | |
|---|---|---|---|
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:* កំណើនផលទុនជាតិប្រចាំឆ្នាំសរុប ក្នុងតម្លៃថេរ (%) | ៧.០ | ៦.០ | |
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:* ផលទុនសរុបសម្រាប់មនុស្សម្នាក់១ (ពាន់រៀល) | ១.៨០០ | ២.២៤៣ | |
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:* អត្រាអតិផរណា (%) | ៦.២ | ៣.០ | |
| **គោលបំណងទី៣: *ក្រុមគ្រួសារអសន្តិសុខស្បៀងកែលម្អការប្រើប្រាស់និងការបឺតស្រូបស្បៀងដើម្បីកាត់បន្ថយកង្វះអាហារូបត្ថម្ភ ជំងឺរង្គាត់ និងមរណភាពជាពិសេសក្នុងចំណោមស្ត្រីនិងកុមារ ។*** | | | |
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:* អត្រាមរណភាពរបស់ទារក (ក្នុង ១.០០០ កំណើត) | ៦៦ | ៦០ | ៥០ |
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:* អត្រាមរណភាពរបស់កុមារអាយុក្រោម.៥ ឆ្នាំ (ក្នុង ១.០០០ កំណើត) | ៨៣ | ៧៥ | ៦៥ |
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:* អត្រាមរណភាពរបស់មាតា (ក្នុង ១០០,០០០ កំណើត) | ៤៧២ | ២៤៣ | ១៤០ |
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:* ការសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ(%) | ៤៤ | ៧០ | ៨០ |
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:* ការចុះឈ្មោះចូលរៀននៅអនុវិទ្យាល័យ (%នៃសិស្សស្រី) | ២៤.៨ | ៧៥ | ១០០ |
| CMDG ៥.៥: ស្ត្រីមានគភ៌ដែលបានទទួលសេវាកម្មថែទាំមុនពេលសម្រាល ២ដងឬច្រើនជាងដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ (គិតតែវិស័យសាធារណៈ) (%) | ៦០ | ៧៥ | ៩០ |
| CMDG ៥.៦: ស្ត្រីមានគភ៌ដែលមានបញ្ហាស្លេកស្លាំងដោយសារកង្វះជាតិដែក (%) | ៥៧ | ៣៩ | ៣៣ |
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:* ការទទួលបានទឹកស្អាតសម្រាប់ប្រើប្រាស់របស់ប្រជាពលរដ្ឋតាម ជនបទ (%) | ៤១.៦ | ៤៥ | ៥០ |
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:* ការទទួលបានអនាម័យរបស់ប្រជាពលរដ្ឋតាមជនបទ (%) | ១៦.៤ | ២៥ | ៣០ |
| **គោលបំណងទី៤: *ការកែលម្អបណ្តាញសុវត្ថិភាពសង្គម និងការលើកកម្ពស់ សមត្ថភាពរបស់ក្រុមគ្រួសារអសន្តិសុខស្បៀងក្នុងការដោះស្រាយហានិភ័យផ្សេងៗ នឹងជួយបង្កើនស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀង ។*** | | | |
| ចំនួនប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយគ្រោះទឹកជំនន់ | | | |
| ចំនួនប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយគ្រោះរាំងស្ងួត | | | |
| *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ:* ផ្ទៃដីស្រោចស្រពដោយរាប់បញ្ចូលការស្រោចស្រពបន្ថែម (%នៃផ្ទៃដីស្រែ) | ២០ | ២៥ | |
| **គោលបំណងទី៥: *កែលម្អបរិស្ថានគោលនយោបាយ និងស្ថាប័ន ដើម្បី សម្រេចបានការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ។*** | | | |
| នៅត្រឹមឆ្នាំ ២០១២ ក្រុមការងារសម្រាប់គ្រប់គ្រងព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភមានដំណើរការហើយប្រព័ន្ធ ព័ត៌មានពាក់ព័ន្ធនឹង សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ផ្សេងៗកាន់តែមាន លក្ខណៈប្រមូលផ្តុំល្អ ហើយធ្វើការកាន់តែមានប្រសិទ្ធភាព | | | |
| នៅត្រឹមឆ្នាំ ២០១២ ក្រសួង-ស្ថាប័ន និងក្រុមការងារបច្ចេកទេស ពាក់ព័ន្ធកាន់តែច្រើនឡើងៗ នឹងប្រើប្រាស់ក្របខ័ណ្ឌយុទ្ធសាស្ត្រ សន្តិសុខស្បៀង និងអាហារូបត្ថម្ភជាឯកសារយោងសម្រាប់បញ្ហាពហុវិស័យ | | | |
| នៅត្រឹមឆ្នាំ ២០១២ ការសម្របសម្រួលនៅថ្នាក់ខេត្ត និងការបញ្ចូលបញ្ហាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍មូលដ្ឋានតាមបែបវិមជ្ឈការ មានការកើនឡើង | | | |

* **<u>ចំណាំ:</u>** សូចនាករ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* មួយចំនួន ដែលបានបង្ហាញនៅទីនេះ ក៏ជាសូចនាករគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាផងដែរ ។

## ឧបសម្ព័ន្ធ ១: ឯកសារយោង

### ១. ឯកសារយុទ្ធសាស្ត្រ និងគោលនយោបាយ

សម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា, ការធ្វើបច្ចុប្បន្នភាពរបស់ក្រសួងផែនការ ឆ្នាំ២០០៥

របាយការណ៍ស្តីពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា របស់ក្រសួងផែនការ ឆ្នាំ ២០០៣

ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម លើកទី២ ២០០១-២០០៥ របស់រាជរដ្ឋាភិបាល ឆ្នាំ ២០០១

យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ២០០៣-២០០៥ ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គម នៃរាជរដ្ឋាភិបាលកម្ពុជា ខែធ្នូ ឆ្នាំ ២០០២

សេចក្តីព្រាងយុទ្ធសាស្ត្រកសិកម្ម និងទឹក ២០០៦-២០១០ ដោយក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ឆ្នាំ ២០០៦។

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០០៤

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ ដោយក្រសួងផែនការ ឆ្នាំ២០០៦

សារាចរ លេខ០៥ ស្តីអំពីសន្តិសុខស្បៀង និងអាហារូបតម្ភនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា

សារាចរ លេខ០៣ ស្តីអំពីសន្តិសុខស្បៀងនិងអាហារូបតម្ភនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាលកម្ពុជា

យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក ២០០៦-២០១០ ដោយក្រុមការងារបច្ចេកទេស កសិកម្ម និងទឹក ឆ្នាំ ២០០៧

ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ២០០៣-២០០៧ របស់ក្រសួងសុខាភិបាល ឆ្នាំ ២០០៣

សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ២០០៦-២០១០ របស់ក្រសួងធនធានទឹក និងឧតុនិយម ឆ្នាំ ២០០៦

កម្មវិធីជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA) របស់ក្រសួងបរិស្ថាន ឆ្នាំ ២០០៦

គោលនយោបាយវិស័យជលផល និងច្បាប់ជលផល ឆ្នាំ ២០០៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

យុទ្ធសាស្ត្រនៃក្របខ័ណ្ឌគោលនយោបាយដីធ្លី ដោយក្រុមប្រឹក្សាគោលនយោបាយដីធ្លី ឆ្នាំ ២០០២

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៦-២០១០ របស់ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០០៦

យុទ្ធសាស្ត្ររយៈពេល ១០ឆ្នាំ (២០០១-២០១១) ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ របស់ក្រសួងអភិវឌ្ឍន៍ ឆ្នាំ ២០០១។

ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ របស់រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០០៥

គោលនយោបាយជាតិប្រជាជន ឆ្នាំ២០០៣ ដោយគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍន៍

## ២. ឯកសារសំខាន់ៗផ្សេងៗ

ចំណែកស្មើគ្នាសម្រាប់ស្ត្រីភេទ : ការវាយតម្លៃយែនឌ័រនៅប្រទេសកម្ពុជា របស់ក្រសួងកិច្ចការនារី ឆ្នាំ២០០៤

របាយការណ៍វិភាគវិស័យកសិកម្មកម្ពុជា រៀបចំសម្រាប់អង្គការ AusAID តាមរយៈក្រុមហ៊ុន Agrifood Consulting International/ CamConsult ឆ្នាំ ២០០៦

ការអង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជាឆ្នាំ ២០០៣/២០០៤ ដោយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ឆ្នាំ ២០០៤

ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ ២០០៥ ដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គការ ORC Macro ឆ្នាំ ២០០៧

ផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា ២០០៣-២០០៧ របស់ក្រសួងផែនការ ឆ្នាំ ២០០៣

ការវាយតម្លៃអសន្តិសុខស្បៀងឆ្នាំ២០០៧ របស់វិទ្យាស្ថានជាតិស្ថិតិ ដោយផ្អែកលើស្ថិតិនៃការបរិភោគស្បៀង ដែលបានមកពីការអង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជា ឆ្នាំ ២០០៣/២០០៤។ របាយការណ៍ដំបូង ខែមិនា ឆ្នាំ២០០៧ ដោយវិទ្យាស្ថានជាតិស្ថិតិ សហការជាមួយអង្គការ FAO និង EU

ការកាត់បន្ថយអត្រាភាពក្រីក្រឱ្យបានពាក់កណ្តាល ត្រឹមឆ្នាំ២០១៥: ការវាយតម្លៃលើភាពក្រីក្រនៅកម្ពុជា ដោយធនាគារពិភពលោក ឆ្នាំ ២០០៦

ការសិក្សាអំពីការវាយតម្លៃ និងការធ្វើមូលដ្ឋានីយកម្មនៃគោលដៅអភិវឌ្ឍន៍សហស្សវត្ស ស្តីពីការកាត់បន្ថយភាពក្រីក្រ និងភាពអត់ឃ្លាន ដោយអង្គការ FAO និង UNDP ឆ្នាំ ២០០៥

យុទ្ធសាស្ត្រសម្រាប់កែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលរៀបចំដោយក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅឆ្នាំ ២០០៥ សម្រាប់ដាក់ជូនលេខាធិការដ្ឋានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្នុងកំឡុងពេលដំណើរ រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាតិ ឆ្នាំ២០០៦-២០១០

ការវិភាគលើការធ្វើចំណាត់ថ្នាក់សម្រាប់សន្តិសុខស្បៀង និងសម្រាប់ការផ្តល់ជំនួយមនុស្សធម៌នៅប្រទេសកម្ពុជា របស់អង្គការកម្មវិធីស្បៀងអាហារពិភពលោក ឆ្នាំ២០០៧

ការគ្រប់គ្រងហានិភ័យនិង ភាពងាយរងគ្រោះនៅកម្ពុជា: ការវាយតម្លៃនិង យុទ្ធសាស្ត្រសម្រាប់ការគាំពារសង្គម ដោយធនាគារពិភពលោក ឆ្នាំ២០០៦

វិបសាយកម្រងផែនទីសន្តិសុខស្បៀង របស់អង្គការស្បៀងអាហារពិភពលោក ឆ្នាំ២០០៦ ( http://www.foodsecurity.gov.kh )

## ឧបសម្ព័ន្ធ ២ : ផែនទីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា

**សំគាល់ :** **ផែនទីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា**ត្រូវបានផលិតឡើងវិញពីកម្រងផែនទីសន្តិសុខស្បៀងនៅកម្ពុជា ឆ្នាំ ២០០៦ របស់អង្គការកម្មវិធីស្បៀងអាហារពិភពលោកដែលមានផែនទីជាច្រើនទៀតទាក់ទងនឹងសន្តិសុខស្បៀង ហើយដែលត្រូវបានធ្វើបច្ចុប្បន្នភាពឡើងវិញ ។ សូមមើលផែនទីសំខាន់ៗមួយចំនួនដែលមានភ្ជាប់ជូននៅក្នុងឯកសារជាភាសាអង់គ្លេសនៃសៀវភៅនេះ ។ ចំពោះព័ត៌មានលម្អិតនៃ **ផែនទីសន្តិសុខស្បៀងនៅកម្ពុជា** សូមមើលវិបសាយ : http://www.foodsecurity.gov.kh ។